អង្គរ ជេនេរ៉ាល់ អ៊ិនសួរេន ម.ក

吴哥大众保险 | ANGKOR GENERAL INSURANCE PLC.

បណ្ណសន្យា

Policy Wording

ធានារ៉ាប់រងយានយន្ត

Motor Vehicle Insurance

2026 © Angkor General Insurance
UW-MVI-001

ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន ជម្រាបសួរ!

Angkor General Insurance, Chomreab Sou!

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្នុងការជ្រើសរើស ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន ម.ក ជាដៃគូការពារប្រកបដោយទំនុកចិត្តរបស់លោកអ្នក។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ចំពោះទំនុកចិត្តរបស់លោកអ្នកមកលើសេវាកម្មធានារ៉ាប់រងរបស់យើងខ្ញុំហើយយើងខ្ញុំនៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់ជូននូវបទដ្ឋានខ្ពស់បំផុតនៃសេវាកម្មថែទាំ ភាពជឿជាក់ និងសុវត្ថិភាពសម្រាប់រាល់អ្វីៗដែលមានតម្លៃបំផុតចំពោះលោកអ្នក។

Thank you for choosing Angkor General Insurance as your trusted protection partner. We sincerely appreciate your confidence in us and remain firmly committed to delivering the highest standards of care, reliability, and security for what matters most to you.

អតិថិជននឹងទទួលបានព័ត៌មានគ្រប់យ៉ាងអំពីបណ្ណសន្យារ៉ាប់រងយានយន្តឯកជនរបស់ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន មានដូចជា៖

1. **តារាងសង្ខេបបណ្ណសន្យារ៉ាប់រង**
2. **លក្ខខណ្ឌបណ្ណសន្យារ៉ាប់រង**
3. **នីតិវិធីទាមទារសំណង**
4. **វិញ្ញាបនបត្រធានារ៉ាប់រង**
5. **លតាបត្រ**
6. **ស្ទីកគ័ធានារ៉ាប់រង**
7. **វិក្កយបត្រ**

ចំពោះលតាបត្រ លោកអ្នកត្រូវបិទនៅក្នុងកញ្ចក់មុខខាងស្តាំនៃរថយន្ត។ រីឯស្ទីកគ័ធានារ៉ាប់រង លោកអ្នកអាចបិទនៅខាងក្រោយយានយន្ត ដើម្បីមានភាពងាយស្រួលក្នុងការទំនាក់ទំនងពេលមានអាសន្នណាមួយកើតឡើង។

Insured customer will find everything you need to know about what is covered under your Motor Vehicle Insurance policy with Angkor General Insurance included:

1. Policy Schedule
2. Policy Wordings
3. Claim Procedure
4. Insurance Sticker
5. Certificate of Insurance
6. Yellow Label
7. Invoice

Please attach the Yellow Label to the right side of your windscreen, and attach the Insurance Sticker on the rear of your vehicle for your ease of use during emergencies.

ពេលមានគ្រោះថ្នាក់សូមទំនាក់ទំនងមកកាន់ក្រុមការងារដោះស្រាយសំណង២៤ម៉ោងដោយឥតគិតថ្លៃពីគ្រប់ប្រព័ន្ធ៖ ១៨០០ ២០ ២៤ ២៤

សម្រាប់ព័ត៌មានផ្សេងៗសូមទំនាក់ទំនងផ្នែកសេវាកម្មអតិថិជនតាមរយៈលេខទូរស័ព្ទ ០៧៨ ២៤ ២៤ ២៤ ឬ ០៨៧ ២៤ ២៤ ២៤
អ៊ីម៉ែលcustomerservice@agi.com.kh
ក្នុងម៉ោងធ្វើការ ថ្ងៃច័ន្ទ-អាទិត្យ ពីម៉ោង ៩:០០ ព្រឹក ដល់ ៥:៣០ ល្ងាច។

For accident-related matters
Please call our 24/7 Claims Toll Free Line: **1800 20 24 24**

For general enquiries:
Please call our customer center at 078 24 24 24 / 087 24 24 24 or email us at customerservice@agi.com.kh (Mon to Sat, 8:30am to 5:30pm).

មាតិកា
Table Of Contents

1	**និយមន័យ** Definition	3
2	**កម្មវត្ថុនៃការធានា** Interest Insured	8
3	**វិសាលភាពធានារ៉ាប់រង** Coverage	12
4	**អត្ថប្រយោជន៍នៃការធានា** Policy Benefits	14
5	**ការបង់បុព្វលាភធានារ៉ាប់រង** Premium Payment	15
6	**ករណីមិនធានា** Exclusion	16
7	**ទីតាំងភូមិសាស្ត្រនៃការធានា** Geographical Limit	17
8	**លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង** Qualification Of Claimants	18
9	**ការកែប្រែកិច្ចសន្យាធានារ៉ាប់រង** Amendment	19
10	**ការបន្តកិច្ចសន្យាធានារ៉ាប់រង** Renewal Policy	23
11	**ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង** Termination	24
12	**ការលុបចោលកិច្ចសន្យាធានារ៉ាប់រង** Cancellation	25
13	**ការទាមទារសំណង** Claims	26
14	**ការរក្សាព័ត៌មានសម្ងាត់** Confidentiality	27
15	**នីតិវិធីនៃការផ្សះផ្សាវិវាទ** Dispute Resolution	28
16	**ច្បាប់និងយុត្តាធិការ** Law And Jurisdiction	29
17	**លក្ខខណ្ឌនានាអនុវត្តគ្រប់ចំណុចធានាទាំងអស់** Conditions Applicable To All Sections	30
18	**នីតិវិធីប្តឹងតវ៉ា** Complaint Procedure	31
19	**ព័ត៌មានទំនាក់ទំនង** Contact Information	32

បណ្ណសន្យាធានារ៉ាប់រងយានយន្ត
Motor Vehicle Insurance Policy Wording

ដោយហេតុថាលោកអ្នក (ដែលហៅថា "អ្នកធានារ៉ាប់រង") បានដាក់ពាក្យសុំដើម្បីធានារ៉ាប់រងលើយានយន្តរបស់លោកអ្នកមកកាន់ ក្រុមហ៊ុនអង្គរ ជេនឺរ៉ល អ៊ិនស្សួរេន(ដែលបន្តបន្ទាប់ទៅនេះហៅថា "ក្រុមហ៊ុន") តាមរយៈទម្រង់បែបបទស្នើសុំធានារ៉ាប់រង និងការអះអាងរបស់លោកអ្នក ដែលត្រូវក្លាយជាមូលដ្ឋាននៃបណ្ណសន្យារ៉ាប់រងនេះនិងដោយហេតុថាលោកអ្នកបានបង់ឬយល់ព្រមបង់នូវបុព្វលាភធានារ៉ាប់រងដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ស្របតាមបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
អាស្រ័យហេតុនេះ បណ្ណសន្យារ៉ាប់រងនេះបញ្ជាក់ថា ផ្អែកទៅលើលក្ខខណ្ឌ ការលើកលែង បញ្ញត្តិ និងការធានាអះអាងទាំងឡាយ ដែលមានចែងនៅក្នុង ឬត្រូវបានកែសម្រួលបន្ថែមលើបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងជូនលោកអ្នក ចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវតាមផ្លូវច្បាប់ ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះដែលកើតឡើងនៅក្នុងអំឡុងពេលនៃការធានារ៉ាប់រងនិងនៅក្នុងតំបន់ភូមិសាស្ត្រដែលបានកំណត់។

Whereas the insured has submitted to angkor general insurance (hereinafter referred to as “the company”) a proposal and declaration, which shall form the basis of and be deemed incorporated into this contract of insurance, and has paid or agreed to pay the premium specified in the policy schedule as consideration for the insurance provided herein, in accordance with the applicable laws and regulations of the kingdom of cambodia; Now therefore, in consideration of the foregoing and subject to the terms, conditions, exclusions, limitations, and endorsements contained herein or endorsed hereon, the company agrees to indemnify the insured against loss, damage, or legal liability as insured under this policy, arising during the period of insurance and within the geographical limits specified in the policy schedule.

1 និយមន័យ
Definition

គ្រឿងបន្ទាប់បន្សំ
Accessories

រាល់ឧបករណ៍សំឡេងវីដេអូនិងឧបករណ៍បន្ទាប់បន្សំតាមស្តង់ដាដើមនៃយានយន្តផ្សេងៗ ដែលបំពាក់ជាប់ជាមួយយានយន្តពីរោងចក្រផលិតយានយន្តតាំងពីមុនពេលដែល យានយន្តត្រូវបានដាក់លក់ជាលើកដំបូង។ គ្រឿងបន្ទាប់បន្សំតាមស្តង់ដាទាំងនេះ ត្រូវបានធានាក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។ ក្រុមហ៊ុននឹងមិនធានាទៅលើគ្រឿងបន្ទាប់បន្សំផ្សេងបន្ថែមទៀតដែលមិនមែនជាគ្រឿងបន្ទាប់បន្សំដើមរបស់យានយន្តទេ លើកលែងតែអ្នកត្រូវបានធានារ៉ាប់រងបានប្រាប់ជាព័ត៌មានទៅក្រុមហ៊ុន ហើយក្រុមហ៊ុនបានយល់ព្រម។ លោកអ្នកអាចនឹងត្រូវបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់គ្រឿងបន្ទាប់បន្សំទាំងនេះ។
All standard equipment fitted into the vehicle by the manufacture or distributor at the time your vehicle was originally bought. These standard fittings are covered under the Policy. The Company will not cover any further additions unless you tell the Company about them, and the Company agrees. You may have to pay an extra premium for these additional accessories.

គ្រោះថ្នាក់
Accident

សំដៅទៅលើព្រឹត្តិការណ៍ភ្លាមៗដែលមិនបានឃើញទុកជាមុន និងដោយចៃដន្យ។
Refers to a sudden, unforeseen, and accidental event.

ការស្លាប់ដោយចៃដន្យ / ការស្លាប់
Accidental Death / Death

មានន័យថា ការស្លាប់ដោយសារគ្រោះថ្នាក់។
means death resulting from an accident.

អ្នកវាយតម្លៃហានិភ័យធានារ៉ាប់រង
Adjuster

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករធានារ៉ាប់រងកម្ពុជា (IRC) ហើយត្រូវបានចាត់តាំងដោយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីស៊ើបអង្កេតអំពីមូលហេតុ និងកាលៈទេសៈនៃការខាតបង់ ក៏ដូចជាវាយតម្លៃលើទំហំនៃទឹកប្រាក់នៃការខាតបង់។
An individual or entity licensed by the Insurance Regulatory of Cambodia (IRC) and appointed by the Company to investigate the cause and circumstances of a loss and assess the amount of the loss.

អ្នកបើកបរដែលមានការអនុញ្ញាត
Authorized Drivers

រូបុគ្គលណាម្នាក់ដែលបើកបរយានយន្តរបស់អ្នក តាមការបញ្ជារបស់អ្នក ឬដោយមានការអនុញ្ញាតពីអ្នក ប៉ុន្តែបុគ្គលនោះចាំបាច់ត្រូវមានបណ្ណបើកបរដែលមានសុពលភាពបើកបរនៅក្នុងប្រទេសកម្ពុជាហើយមិនស្ថិតនៅក្រោមការតាមដាន ឬដកហូតសិទ្ធិក្នុងការបើកបរទេ។
Any person driving your vehicle on your order or with your permission but only if the person has a valid license to drive in Cambodia and is not under suspension or disqualification from driving.

យានយន្តអាជីវកម្ម
Commercial Vehicle

សំដៅដល់យានយន្តដែលត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពអាជីវកម្ម ដូចជា ដឹកជញ្ជូនទំនិញ ឬដឹកជញ្ជូនមនុស្សដើម្បីទទួលបានប្រាក់កម្រៃ ការជួល ដែលប្រភេទការប្រើប្រាស់របស់វាត្រូវបានក្រសួងសាធារណការ និងដឹកជញ្ជូនបានចែងក្នុងបណ្ណសម្គាល់យានយន្តថាជាប្រភេទយានយន្តដឹកអ្នកដំណើរ ឬប្រភេទយានយន្តដឹកទំនិញ។

Refers to any vehicle used for business activities such as transporting goods or people in exchange for money, hire or reward and which its type of usage is registered as passenger carrying vehicle or goods carrying vehicle by the Ministry of Public Works & Transport.

កំណត់សំអាង
Cover Note

សំដៅដល់ឯកសារបណ្តោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬ អន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់បណ្ណធានារ៉ាប់រង ជំនួសបណ្ណសន្យារ៉ាប់រងនៅក្នុងករណីចាំបាច់និងបន្ទាន់ដែលក្រុមហ៊ុនធានារ៉ាប់រង ឬអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់មិនអាចចុះកិច្ចសន្យា និងចេញបណ្ណសន្យារ៉ាប់រងបាន។

Refers to a temporary document issued by an insurance company or insurance intermediary authorized to sell insurance policies, Replace the insurance policy in necessary and urgent cases where the insurance company or insurance intermediary authorized to sell is unable to sign the contract and issue the insurance policy.

បទល្មើសរំលោភលើទំនុកចិត្ត
Criminal Breach of Trust

ត្រូវបានបកស្រាយដោយយោងតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឬមានន័យថាៈជនណាមួយដែលត្រូវបានគេផ្ញើទំនុកចិត្តឲ្យមើលថែទ្រព្យអ្វីមួយ ទោះតាមរបៀបណាក៏ដោយ ឬដែលមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមួយ ទោះបីជាតែម្នាក់ឯង ឬរួមគ្នាជាមួយបុគ្គលផ្សេងក៏ដោយ បន្លំយកដោយទុច្ចរិតនូវទ្រព្យនោះ ឬបង្វែរទ្រព្យនោះមកជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ចាត់ចែងទ្រព្យនោះដោយទុច្ចរិត ដោយរំលោភលើវិធានច្បាប់ ដែលបញ្ញត្តិពីរបៀបដោះបន្ទុកលើការផ្ញើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ឬដោយតុណ្ហភាពដែលអនុញ្ញាតឲ្យខ្លួនរួចបន្ទុកពីការផ្ញើទុកនោះ ឬដោយចេតនាបង្កឲ្យបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្ត។

Shall have the meaning as defined either under article 391 of the Criminal Code of the Kingdom of Cambodia or follows the meaning as defined as follows: Whoever, being in any manner entrusted with property, or with any dominion over property either solely or jointly with any other person, dishonestly misappropriates, or converts to his own use, that property, or dishonestly uses or disposes of that property in violation of any direction of law prescribing the mode in which such trust is to be discharged, or of any legal contract, express or implied, which he has made touching the discharge of such trust, or willfully suffers any other person so to do, commits "Criminal Breach of Trust".

ការឆបោក
Cheating

ត្រូវបានបកស្រាយដោយយោងតាមមាត្រា៣៧៧នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឬមានន័យថាៈ បុគ្គលណាមួយដែលបោកប្រាស់អ្នកដទៃទៅជាការបោកប្រាស់នោះជាកត្តាតែមួយគត់ឬកត្តាចម្បាប់ដែលបណ្តាលឱ្យៈ

ក. ជនរងគ្រោះដោយការបោកប្រាស់ប្រគល់ទ្រព្យសម្បត្តិណាមួយឱ្យបុគ្គលណាមួយ ឬយល់ព្រម ឱ្យបុគ្គលណាមួយកាន់កាប់ទ្រព្យសម្បត្តិណាមួយដោយចេតនាឆបោក ឬមិនស្មោះត្រង់ ឬ

ខ. ជនរងគ្រោះដោយការបោកប្រាស់ធ្វើសកម្មភាព ឬ អសកម្មដែលបុគ្គលនោះនឹងមិនធ្វើ ឬមិនធ្វើ ប្រសិនបើមិនត្រូវបានបោកប្រាស់ ហើយសកម្មភាព ឬអសកម្មនោះបណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានការខូចខាតដល់រូបរាងការផ្លូវចិត្តកិត្តិយស ឬទ្រព្យសម្បត្តិរបស់បុគ្គលណាមួយ។ នោះគឺជា ការឆបោក។

Shall have the meaning as defined either under article 377 of the Criminal Code of the Kingdom of Cambodia or as follows:

a. Fraudulent or dishonest means, induces the person deceived to deliver any property to any person, or to agree that any property shall be retained by any person; or
b. Intentionally induces a person deceived to do an act or omission which the person would not do or omit if he had not been deceived, and such act or omission causes or is likely to cause damage to the body, mind, reputation or property is said to "cheat".

កម្រិតមិនធ្វើសំណង
Deductible

ជាចំនួនទឹកប្រាក់ដែលលោកអ្នកត្រូវបង់នៅពេលមានគ្រោះថ្នាក់ម្តងៗ។ កម្រិតមិនធ្វើសំណងត្រូវបានកំណត់ក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង ឬ វិញ្ញាបនបត្រធានារ៉ាប់រង។

The amount of the claim you will have to pay for each accident. The excess is shown in your Policy Schedule or Certificate of Insurance. The deductible is also known as the excess.

ការទាមទារសំណងនីមួយៗ
Each and every Claim

សំដៅដល់ការទាមទារសំណងមួយ ឬសំណងជាបន្តបន្ទាប់ដែលបណ្តាលមកពីមូលហេតុដើមដូចគ្នា។

Refers any one claim or series of claims arising out of one originating cause.

បដិលេខ
Endorsement

សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនជូនលោកអ្នក ដើម្បីបញ្ជាក់នៅក្នុងបញ្ជីលក្ខខណ្ឌបណ្ណសន្យារ៉ាប់រង។

Refers to the document that We issue to You to confirm any changes or extensions of the coverage to the basic Policy.

សមាជិកគ្រួសារ
Household

សំដៅលើសមាជិកទាំងអស់នៃគ្រួសាររបស់អ្នក ឬអ្នកបើកបរដែលមានការអនុញ្ញាតរបស់អ្នក ពោលគឺ ប្តីប្រពន្ធ កូនរួមទាំងកូនចិញ្ចឹម ស្របច្បាប់ ឪពុកម្តាយ បងប្អូនប្រុសស្រី ដែលស្នាក់នៅក្រោមដំបូលតែមួយជាមួយអ្នក ក្នុងករណីគ្រួសារជិតស្និទ្ធរបស់អ្នក ឬជាមួយអ្នកបើកបរដែលមានការអនុញ្ញាតរបស់អ្នកក្នុងករណីគ្រួសារជិតស្និទ្ធរបស់គាត់។
Refers to all members of Your or Your Authorized Driver's immediate family i.e., spouse, children including legally adopted children, parents, brother(s) and sister(s) staying under one roof with You in the case of Your immediate family, or with Your Authorized Driver, in the case of his immediate family.

កិច្ចសន្យាធានារ៉ាប់រង
Insurance Contract

សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលយកហានិភ័យជាក់លាក់ណាមួយដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកត្រូវបានធានារ៉ាប់រង។
Refers to a written agreement between the insurer and the insured in which the insurer agrees to accept any specific risk, and in return receives premium paid by the insured.

ឧប្បត្តិវហេតុ
Incident

សំដៅទៅលើព្រឹត្តិការណ៍ណាមួយដែលអាចនាំឱ្យមានការទាមទារសំណងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។
Refers to any event which could lead to a claim under this Policy.

របួស
Injury

មានន័យថារបួសរាងកាយដែលបង្កឡើងដោយឧបទ្ទវហេតុនិងដោយផ្ទាល់ ដោយមិនគិតពីមូលហេតុផ្សេង ទៀត។
Means bodily Injury caused solely and directly by an Accident, independent of any other cause.

សោរ
Key

សំដៅដល់សោរឬឧបករណ៍ណាមួយដែលផលិតដោយក្រុមហ៊ុនផលិតយានយន្ត សម្រាប់ចាក់សោរ បញ្ជោះ និងអនុញ្ញាតឱ្យយានយន្តដំណើរការ។
Means any Key or device made by the manufacturer of Your Vehicle to secure, gain access to, and enable Your Vehicle to be started and driven.

តម្លៃទីផ្សារ
Market Value

តម្លៃនៃការផ្លាស់ប្តូរយានយន្តរបស់លោកអ្នកជាមួយនឹងយានយន្តមួយទៀតដែលមានម៉ាក ឆ្នាំផលិត និងលក្ខខណ្ឌស្រដៀងគ្នាទៅនឹងយានយន្តរបស់លោកអ្នក និងអាចរកទិញបានមុនពេលកើតហេតុ។
The cost of replacing your vehicle with one of the same make and model which is in a similar condition and age as your motor vehicle was, and which is currently available immediately before the date of loss or accident.

ម្ចាស់បណ្ណសន្យារ៉ាប់រង
Policyholder

សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានកម្មសិទ្ធស្របច្បាប់ចំពោះបណ្ណសន្យារ៉ាប់រង។
Refers to a natural person or a legal entity who has legal title to the insurance policy.

បុព្វលាភធានារ៉ាប់រង
Premium

សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងតាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង។
The amount paid by an insured to an insurer under an insurance policy as consideration for the obligations assumed by the insurer.

អ្នកត្រូវបានធានារ៉ាប់រង
The Insured

សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណធានារ៉ាប់រងហើយក្នុងករណីខ្លះ អ្នកត្រូវបានធានារ៉ាប់រងអាចជាម្ចាស់បណ្ណធានារ៉ាប់រងផង និងជាអ្នកត្រូវបានធានារ៉ាប់រងផងដែរ។
Refers to a natural person or a legal entity that purchases an insurance policy, and in some cases an insured can be a policyholder as well as an insured person.

សកម្មភាពភេរវកម្ម
Terrorist acts

សំដៅដល់ រាល់សកម្មភាពហិង្សា ឬការប្រើកម្លាំងបាយ ឬការគំរាមកំហែងដោយប្រើអំពើហិង្សា ឬកម្លាំងបាយ ដែលប្រព្រឹត្តដោយបុគ្គលឬក្រុមណាមួយទោះជាធ្វើឡើងដោយឯករាជ្យឬក្នុងនាមឬមានទំនាក់ទំនងជាមួយអង្គការ ឬរដ្ឋាភិបាលណាមួយ ដោយមានគោលបំណងផ្នែកនយោបាយ សាសនា មនោគមវិជ្ជា ពូជសាសន៍ ឬគោលបំណងផ្សេងៗទៀតរួមទាំងការប៉ុនប៉ងធ្វើអោយមានឥទ្ធិពលលើសកម្មភាពរបស់រដ្ឋាភិបាល និង/ឬ បង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬផ្នែកណាមួយនៃសាធារណជន។
Means any act of violence or force, or the threat of violence or force, committed by any individual or group, whether independently or on behalf of or in connection with any organization or government, with political, religious, ideological, racial or other motives, including attempts to influence government behavior and/or to cause the public or sections of the public to be terrorized.

វិសាលភាពដែនដី
Geographical Area

សំដៅដល់ដែនកំណត់ភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រង។
Refers to the territory of the Kingdom of Cambodia as stated in the Policy Schedule.

យានដ្ឋានដៃគូរ
Panel Workshop/Garage

សំដៅដល់យានដ្ឋានជួសជុលយានយន្តដែលបានអនុម័តដោយយើងហើយអាចប្រើប្រាស់សម្រាប់ការទាមទារសំណង។
Refers to motor repair workshops approved by Us for a claim.

អ្នកដំណើរ
Passenger

សំដៅដល់បុគ្គលណាមួយដែលស្ថិតនៅក្នុងយានយន្តរបស់លោកអ្នក កំពុងឡើងឬចុះឬកំពុងត្រូវបានដឹកជញ្ជូននៅក្នុងយានយន្តក្នុងពេលកើតមានព្រឹត្តិការណ៍។ លក្ខខណ្ឌនេះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌនៃប័ណ្ណ សន្យារ៉ាប់រងនេះ។
Means any person who is in, getting in or out of your vehicle, or being transported in your vehicle at the time of the incident. Subject to the terms and conditions of this policy.

ការខូចខាតទាំងស្រុង/ ការខូចខាតស្ទើរទាំងស្រុង
Total Loss/Constructive Total Loss

ប្រសិនបើយានយន្តរបស់អ្នករងការខូចខាត ឬបំផ្លិចបំផ្លាញ រហូតដល់កម្រិតមួយដែលមិនអាចជួសជុលដោយដូចស្ថានភាពដើមវិញបាន នោះនឹងត្រូវបានចាត់ទុកថា ការខូចខាតទាំងស្រុង។ បើសិនជាការខូចខាតយានយន្តរបស់អ្នកអាចជួសជុលបានប៉ុន្តែការចំណាយការជួសជុលលើពី ៨០% នៃតម្លៃទីផ្សារនៃយានយន្តរបស់អ្នកនៅពេលបាត់បង់ នោះនឹងត្រូវបានចាត់ទុកថា ការខូចខាតស្ទើរទាំងស្រុង។
If Your Vehicle has been damaged or destroyed to an extent that it cannot be repaired or restored to its pre- loss condition, then it is deemed as Total Loss. If the damage to Your Vehicle is repairable but the repair cost is more than 80% of the Market Value of the Your Vehicle at the time of loss, then it is considered as Constructive Total Loss.

បណ្ណសន្យារ៉ាប់រង
Policy Wording

សំដៅដល់ឯកសារមួយនៃ កិច្ចសន្យាធានារ៉ាប់រងជាក់លាក់ដើម្បីប្រើប្រាស់ជាភស្តុតាងសម្រាប់បង្កើតកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងត្រូវចុះហត្ថលេខា ឬប្រថាប់ត្រាដោយក្រុមហ៊ុនធានារ៉ាប់រង ឬដោយអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់ផលិតផលធានារ៉ាប់រង។
It is a legal binding document issued by an insurer stipulating major substance and detailed terms and conditions that are agreed between the insurer and the insured in the insurance contract. This Policy shall be attached with insurance certificate and/or other related documents.

តារាងសង្ខេបបណ្ណសន្យារ៉ាប់រង
Policy Schedule / Certificate of Insurance

សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងលើសេចក្តីសង្ខេបពីខសន្យា លក្ខខណ្ឌនានា ករណីមិនធានា និងបុព្វលាភធារ៉ាប់រង ដែលត្រូវបានកំណត់ថ្លៃនិងផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រង។
A document issued by an insurance company for a summary of terms, conditions, exclusions and premium which is charged and provided to the Insured.

រយៈពេលនៃការធានារ៉ាប់រង
Period of Insurance

រយៈពេលនៃការធានាដែលបង្ហាញនៅលើកាលវិភាគបណ្ណធានារ៉ាប់រងរបស់អ្នកនិងសម្រាប់រយៈពេលបន្ទាប់ណាមួយដែលការធានាត្រូវបានបន្តដោយកិច្ចព្រមព្រៀងទៅវិញទៅមក។
The period of cover shown on Your Policy Schedule, and for any following period for which cover is extended by mutual agreement.

យានយន្តឯកជន
Private Vehicle

សំដៅដល់យានយន្តដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរធម្មតាសម្រាប់ទីសង្កេតម គ្រួសារសម្រាប់ប្រើប្រាស់ពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកដែលត្រូវបានធានារ៉ាប់រងដូចដែលត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង (មិនរាប់បញ្ចូលសម្ភាពអាជីវកម្ម ឬការប្រើប្រាស់ណាមួយដែលទាក់ទងនឹងការជួល, ការដឹកជញ្ជូនមនុស្ស ឬទំនិញដើម្បីទទួលបានប្រាក់កំរៃ)។
Refer to vehicle being used for social domestic, pleasured purpose and in connection with the insured business as described in the certificate of insurance (excepting business activities such as hire and reward, transporting goods or people in exchange for money).

កូដកម្ម កុប្បកម្ម និងការបះបោរ
Strike, Riot, Civil Commotion

ជាអំពើរបស់បុគ្គលណាមួយដែលបានចូលរួមក្នុងសកម្មភាពចលាចលសង្គមណាមួយទោះបីជាមានឬមិនមានការពាក់ព័ន្ធជាមួយនឹងសកម្មភាពកូដកម្ម ឬ LOCK-OUT (ការចាក់សោរមិនឱ្យកម្មករចូលក្នុងរោចក្រ)។
The act of any person taking part in any disturbance of the public peace whether in connection with a strike or lock-out.

ទឹកប្រាក់ធានារ៉ាប់រង
Sum Insured

ទឹកប្រាក់អតិបរិមាដែលក្រុមហ៊ុននឹងត្រូវសងក្នុងការទាមទារសំណងចំពោះការបាត់បង់ ឬ ខូចខាតទៅលើយានយន្តរបស់លោកអ្នក។
The maximum amount we will pay for a claim for loss or damage to your vehicle.

តតិយជន
Third Parties

ជាបុគ្គលដែលមិនមែនជាភាគីនៃកិច្ចសន្យាធានារ៉ាប់រងនេះ។
Anyone else who is not part of this Policy.

ការដឹកជញ្ជូន
Transit

សំដៅដល់ការដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត(រួមបញ្ចូលទាំងអំឡុងពេលលើកដាក់ទំនិញ/យានយន្តឡើង និងចុះ) នៃយានយន្តរបស់លោកអ្នក ដោយស្ថិតក្រោមលក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រង។
Means being carried from one place to another (including during loading and unloading) of Your Vehicle subject to the Policy terms, conditions and exclusions.

យើង / OURS / ក្រុមហ៊ុនធានារ៉ាប់រង
We/Us/Our / Insurance Company / Insurer

សំដៅដល់ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន ម.ក
Refers to ANGKOR GENERAL INSURANCE PLC.

អ្នក / ខ្លួនអ្នក / របស់អ្នក
You / Yourself / Your

សំដៅដល់អ្នកត្រូវបានធានារ៉ាប់រងឬម្ចាស់បណ្ណសន្យារ៉ាប់រងដែលបានកំណត់នៅក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង។
Refers to the Policyholder and/or the Insured shown in the Policy Schedule.

យានយន្តរបស់លោកអ្នក
Your Vehicle

សំដៅដល់យានយន្តដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងរួមបញ្ចូលគ្រឿងបន្សំដែលបំពាក់ចេញពីស្តង់ដារបស់រោងចក្រផលិតនិងគ្រឿងបន្សំដែលបំពាក់បន្ថែមផ្សេងទៀតដូចដែលបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
Means the motor vehicle described in the Schedule to the Policy including original factory standard accessories and any additional accessories specifically listed in the Schedule to the Policy.

2 កម្មវត្ថុនៃការធានា
Interest Insured

កម្មវត្ថុនៃការធានាដែលត្រូវយកមកអនុវត្តស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះមាន៖
The Interest Insured of this policy are:

- **យានយន្តឯកជន**
  Private Vehicle
- **យានយន្តអាជីវកម្ម**
  Commercial Vehicle

3 វិសាលភាពធានារ៉ាប់រង
Coverage

ចំណុចទី១៖ ការទំនួលខុសត្រូវចំពោះភាគីតតិយជន
Section I: Liability To Third Parties

ក្រុមហ៊ុននឹងផ្តល់សំណងចំពោះការបាត់បង់អាយុជីវិត ឬរបួសរាងកាយ និង/ឬ ការខូចខាតទ្រព្យសម្បត្តិរបស់ភាគីតតិយជនដែលបង្កឡើងដោយគ្រោះថ្នាក់ដែលកើតចេញពីការប្រើប្រាស់យានយន្តដែលត្រូវបានធានា ហើយដែលអ្នកត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចទទួលខុសត្រូវ។
The Company shall pay for the loss of life or bodily injuries and/or damage of property to the Third Party caused by accident arising out of the use of the Insured Vehicle and shall be legally liable by the Insured.

ក្រុមហ៊ុននឹងផ្តល់សំណងដូចខាងក្រោម៖
The Company will indemnify:

- **មរណភាព ឬរបួសរូវរាងកាយលើបុគ្គលណាមួយ លើកលែងតែបុគ្គលដែលត្រូវបានដាក់បញ្ចូលក្នុងករណីមិនធានា ដូចមានចែងក្នុងករណីមិនធានាក្នុងចំណុចទីមួយ។**
  Death or bodily injury to any person except those specifically excluded under exceptions to Section I.
- **ការខូចខាតទ្រព្យសម្បត្តិរបស់បុគ្គលណាមួយលើកលែងតែទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលត្រូវបានបញ្ចូលក្នុងករណីមិនធានាក្នុងចំណុចទីមួយ។**
  Property damage of any person except property belonging to any person specifically excluded under Exceptions to Section I.

ដោយត្រូវគោរពលក្ខខណ្ឌថា អ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកត្រូវអនុវត្ត និងគោរពតាមគ្រប់ខសន្យា និងលក្ខខណ្ឌនានានៃកិច្ចសន្យាធានារ៉ាប់រងនេះ ដូចដែលលោកអ្នកត្រូវគោរពតាម និងមិនត្រូវបានមានសិទ្ធិទទួលបានការធានាក្រោមកិច្ចសន្យាធានារ៉ាប់រងណាមួយផ្សេងក្រៅពីនេះទៀតទេ។

Provided your authorized driver also complies with all the terms and conditions of the policy that you are subject to and must not be entitled to cover under any other policy.

ចំណុចទី២៖ ការធានារ៉ាប់រងយានយន្តរបស់អ្នក
Section II: Insurance On Your Vehicle

ក្នុងអំឡុងពេលធានារ៉ាប់រងប្រសិនបើយានយន្តរបស់លោកអ្នករងការខូចខាតឬបាត់បង់ដោយសារហេតុការណ៍ដូចខាងក្រោមនេះយើងនឹងទូទាត់សំណង៖

We will indemnify You if Your Vehicle is damaged or lost during Period of Insurance arising from the following circumstances:

(ក) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់យានយន្តជាយថាហេតុ។
By Accidental collision or overturning,

(ខ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់ដែលបណ្តាលមកពីបញ្ហាម៉ាស៊ីន។
By collision or overturning caused by mechanical breakdown,

(គ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់ដែលបណ្តាលមកពីការទ្រុឌទ្រោម និងចាស់។
By collision or overturning caused by wear and tear,

(ឃ) ការខូចខាតដែលបណ្តាលមកពីការប៉ះទង្គិចដោយវត្ថុដែលធ្លាក់មកពីលើប៉ុន្តែមិនរាប់បញ្ចូលការខូចខាតដែលរួមចំណែកបង្កដោយទឹកជំនន់ , ខ្យល់ព្យុះ, ព្យុះភ្លៀង, បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។
By impact damage caused by falling objects excluding flood, typhoon, hurricane, storm, tempest, volcanic eruption, earthquake, landslide, landslip, subsidence or sinking of the soil/earth or other convulsion of nature is involved,

(ង) អគ្គិភ័យ, ការផ្ទុះ ឬរន្ទះ។
By fire, explosion or lightning.

(ច) អំពើចោរកម្ម
By burglary, housebreaking or theft,

(ឆ) ដោយសារអំពើព្យាបាទ
By malicious act,

(ជ) នៅពេលដែលយានយន្តរបស់លោកអ្នកត្រូវបានដឹកជញ្ជូន (រួមទាំងការលើកដាក់ទំនិញ/យានយន្តឡើង និង ចុះ) ដោយវិធីសាស្ត្រដូចខាងក្រោម៖
whilst in Transit (including during loading and unloading) by:

- ការដឹកជញ្ជូនតាមផ្លូវគោក។
  Road
- ការដឹកជញ្ជូនតាមផ្លូវដែក។
  Rail
- ការដឹកជញ្ជូនតាមផ្លូវទឹក ដូចជាទន្លេ ប្រឡាយជាដើម
  Inland waterway i.e. across a river or canal etc.
- ការដឹកជញ្ជូនឆ្លងកាត់សមុទ្រតាមរយៈ ដូចជាសាឡាង, កប៉ាល់ ឬមធ្យោបាយដឹកជញ្ជូនតាមសមុទ្រផ្សេងទៀត។
  Across the sea by ferry or ship or any sea faring vessels etc.

ការខូចខាត ឬ បាត់បង់កើតឡើងក្នុងអំឡុងពេលធានារ៉ាប់រង ចំពោះយានយន្តដែលត្រូវបានធានា រួមទាំងគ្រឿងបន្លាស់ គ្រឿងតុបតែង ឬបរិក្ខារផ្សេងៗដែលជាស្តង់ដារចេញពីរោងចក្រ ក៏ដូចជាគ្រឿងបន្លាស់ ឬគ្រឿងតុបតែងបន្ថែមណាមួយដែលអ្នកត្រូវបានធានារ៉ាប់រងបានដាក់ធានា។

Occurred during the insurance period, to the Insured Vehicle, including equipment, accessories or fixtures which are standard from the car factory as well as any additional equipment, accessories which the Insured has declared.

នៅពេលដែលមានការខូចខាតទៅដល់យានយន្តដែលត្រូវបានធានានៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងផ្តល់សំណងសម្រាប់៖
When there is damage to the Insured Vehicle covered under this policy, the Company shall indemnify for:

- **ការជួសជុលយានយន្តរបស់អ្នកត្រូវបានធានារ៉ាប់រង ឬធ្វើឲ្យដូចសភាពដើមវិញ ឬផ្លាស់ប្តូរយានយន្ត។**
  Repairing, Reinstate or replace the insured's Vehicle.
- **ទូទាត់ជូនអ្នកត្រូវបានធានារ៉ាប់រងនូវថ្លៃចំណាយសមស្របសម្រាប់ការជួសជុលយានយន្ត ឬ**
  Pay the Insured the reasonable cost of repair, or
- **ថ្លៃចំណាយការការពារ និងសណ្តោងយានយន្ត ចាប់ពីថ្ងៃកើតមានគ្រោះថ្នាក់រហូតដល់ការជួសជុលត្រូវបានបញ្ចប់ ឬសំណងត្រូវបានទូទាត់ ប៉ុន្តែមិនលើសពី ៣០០ ដុល្លារអាមេរិកឡើយ។**
  The cost of care and removal of the Vehicle from the date of the accident until the repair is completed or compensation is paid but not exceeding 300 USD.

ការទទួលខុសត្រូវរបស់ក្រុមហ៊ុន មិនត្រូវលើសពីកម្រិតនៃទំហំទទួលខុសត្រូវ ដែលបានបញ្ជាក់នៅក្នុងតារាងអត្ថប្រយោជន៍នៃបណ្ណសន្យារ៉ាប់រងឡើយ។
The liability of the Company shall not exceed the limit of liability as specified in the Schedule of Benefits.

នៅពេលមានការបាត់បង់ ឬ ការខូចខាតកើតឡើង ប្រសិនបើចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងរបស់យានយន្តដែលត្រូវបានធានា មានតម្លៃតិចជាង ៨០% នៃតម្លៃទីផ្សារ នោះក្រុមហ៊ុននឹងទូទាត់សំណងតែតាមសមាមាត្រនៃតម្លៃជួសជុលរវាងចំនួនទឹកប្រាក់ធានារ៉ាប់រង បើធៀបនឹងតម្លៃទីផ្សារជាក់ស្តែងនៃយានយន្តនោះតែប៉ុណ្ណោះ។
At the time of loss, if the sum Insured of the Insured Vehicle is less than 80% of the Market Value, then the Company will pay only such proportion of the repaired costs as the sum Insured bears to the market value of the Insured Vehicle.

ចំណុចទី៣៖ ធានារ៉ាប់រងបន្ថែមដោយស្វ័យប្រវត្តិ
Section III: Automatic Coverages

សេវាផ្នែកច្បាប់
Legal Fee

គឺជាការចំណាយសមស្របលើសេវាផ្នែកច្បាប់ដែលបានកើតឡើងប្រសិនបើអ្នកបើកបរនៃយានយន្តដែលត្រូវបានធានារ៉ាប់រងត្រូវបានចោទប្រកាន់ពីបទបើកបរដោយ ខ្វះការប្រុងប្រយ័ត្នដែលបណ្តាលឱ្យមានមនុស្សស្លាប់។ក្រុមហ៊ុននឹងមិនទូទាត់លើសពី ២,០០០ ដុល្លារអាមេរិក ឡើយសម្រាប់គ្រោះថ្នាក់នីមួយៗ។
Reasonable costs of legal happened if the insured's driver is charged with careless driving causing death. The Company will not pay more than **USD 2,000** in respect of any one accident.

ការធានាលើកញ្ចក់មុខក្រោយ កញ្ចក់បង្អួច និងកញ្ចក់ដំបូល
Cover for Windscreens, Windows and Sunroof

ក្រុមហ៊ុននឹងបន្ថែមការធានាដែលផ្តល់ជូននៅក្នុងចំណុចទី ២ នៃបណ្ណសន្យារ៉ាប់រងនេះ ចំពោះការទាមទារសំណងរបស់លោកអ្នក សម្រាប់ការចំណាយលើការជួសជុល ឬការផ្លាស់ប្តូរ កញ្ចក់មុខក្រោយ កញ្ចក់បង្អួច និងកញ្ចក់ដំបូល នៃយានយន្តរបស់អ្នកបន្ទាប់ពីមានការប្រេះស្រាំ ឬបែកបាក់ (ក្នុងលក្ខខណ្ឌដែលមិនមានការខូចខាតផ្សេងទៀតដល់យានយន្តនោះឡើយ)។ លោកអ្នកអាចធ្វើការទាមទារសំណងមួយដងក្រោមអត្ថប្រយោជន៍នេះក្នុងអំឡុងពេលនៃការធានា ដោយមិនបាត់បង់នូវសិទ្ធិទទួលបានការបញ្ចុះតម្លៃក្នុងករណីមិនធ្លាប់ទាមទារសំណង ឬ ដោយត្រូវបង់កម្រិតមិនធ្វើសំណង។ក្រោយពីក្រុមហ៊ុនបានទូទាត់សំណងលើកទីមួយរួចហើយអត្ថប្រយោជន៍នេះនឹងត្រូវបញ្ចប់លើកលែងតែលោកអ្នកបន្តសុពលភាពវាឡើងវិញ និងបង់នូវបុព្វលាភធានារ៉ាប់រងបន្ថែម។
We will extend the cover provided by Section II of this Policy to **any claim you make for the cost of repairing or replacing any glass in the windscreen or in the windows of your vehicle after it is hipped or broken** (as long as there is no further damage to the motor vehicle). You can make one claim under this benefit during the period of insurance without losing your No Claim Discount or paying the Deductible. After we have settled the first claim, this benefit will end unless you decide to reinstate it and pay an extra premium.

ម៉ាស៊ីនត្រជាក់ ម៉ាញ៉ែ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត
Air Conditioning Unit, Car Radio, Cassette Player and CD Player

ក្រុមហ៊ុននឹងបន្ថែមការធានាដែលផ្តល់ជូននៅក្នុងចំណុចទី ២ នៃបណ្ណសន្យារ៉ាប់រងនេះ។ ការប៉ាន់ស្មានតម្លៃទីផ្សាររបស់យានយន្តរបស់លោកអ្នករួមបញ្ចូលទាំងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំដូចដែលមានចែងក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រងនិងបូកបញ្ចូលនូវតម្លៃរបស់ម៉ាស៊ីនត្រជាក់ , ម៉ាស៊ីនចាក់កាសែត ឬ ម៉ាស៊ីនចាក់ស៊ីឌី។ ចំពោះការបាត់បង់ ឬការខូចខាតទៅលើឧបករណ៍ទាំងអស់នេះ ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងជូននូវតម្លៃជួសជុល ឬតម្លៃផ្លាស់ប្តូរ។ លោកអ្នកអាចធ្វើការទាមទារសំណងមួយដងក្រោមអត្ថប្រយោជន៍នេះក្នុងអំឡុងពេលនៃការធានា ដោយមិន

បាត់បង់នូវសិទ្ធិទទួលបានការបញ្ចុះតម្លៃក្នុងករណីមិនធ្លាប់ទាមទារសំណង ឬដោយត្រូវបង់កម្រិតមិនធ្វើសំណង។ ក្រោយពីក្រុមហ៊ុនបានទូទាត់សំណងលើកទីមួយរួចហើយ អត្ថប្រយោជន៍នេះនឹងត្រូវបញ្ចប់ លើកលែងតែលោកអ្នកបន្តសុពលភាពវាឡើងវិញ និងបង់នូវបុព្វលាភធានារ៉ាប់រងបន្ថែម។

We will extend the cover provided by Section II of this Policy. Your estimate of the market value of your vehicle, including accessories and spare parts shown in the Policy Schedule will include the air-conditioning unit and the built-in radio, cassette or CD player. For loss or damage to these items, we will pay up to the actual cost of repair or the full replacement value. You can claim once under this benefit during any one period of insurance without losing your No Claim Discount or paying the Deductible. After we have settled the first claim, this benefit will end unless you decide to reinstate it and pay an extra premium.

សេវាស្ទូច និងដឹកជញ្ជូនដោយឥតគិតថ្លៃ
Free Towing and Transport

ប្រសិនបើយានយន្តរបស់លោកអ្នកមិនអាចធ្វើដំណើរបានដោយសារមូលហេតុណាមួយដែលកើតឡើងក្នុងចំងាយ២០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ យើងនឹងទូទាត់នូវថ្លៃចំណាយសមស្របក្នុងការផ្លាស់ទីយានយន្តរបស់លោកអ្នក ទៅកាន់យានដ្ឋានដែលជាដៃគូសហការរបស់យើងដែលនៅជិតបំផុត។

If your vehicle is disabled as a result of any caused within 20Km of the Phnom Penh City, we will pay the reasonable costs of removing your vehicle to the nearest our Panel Workshop/Garage.

សេវាកម្មអ្នកបើកបរជំនួសដោយឥតគិតថ្លៃ (១ ដង ក្នុងអំឡុងពេលសុពលភាពបណ្ណសន្យារ៉ាប់រង)
Free Designated Driver Service (1 time per period of insurance)

ក្នុងរង្វង់ ១០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ក្នុងករណីដែលអ្នកធានារ៉ាប់រង ឬអ្នកបើកបររបស់អ្នក មិនមានលទ្ធភាពបើកបរយានយន្តដែលត្រូវបានធានាយើងនឹងផ្តល់ជូននូវសេវាកម្មអ្នកបើកបរជំនួស។យើងនឹងផ្តល់ជូនសេវាកម្មអ្នកបើកបរជំនួសដើម្បីបើកបរយានយន្តរបស់អ្នកទៅកាន់លំនៅដ្ឋានរបស់អ្នកត្រូវបានធានារ៉ាប់រង ឬ ទៅកាន់ទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ដោយមិនមានគិតកម្រៃសេវាឡើយ។

Within 10km of Phnom Penh city, in the event that the insured or an authorized driver is unable to operate the insured vehicle, we shall provide a designated driver service. We will provide designated driver service to drive your vehicle to the insured's residence or a designated safe location without any service charge.

ចំណុចទី៤៖ ជម្រើសធានារ៉ាប់រងបន្ថែម
Section IV: Optional Coverages

ការរួមបញ្ចូលនៃហានិភ័យពិសេស
Inclusion of Special Perils

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះ យើងយល់ព្រមផ្តល់ការធានាបន្ថែមនៃចំណុចទី២ នៃបណ្ណសន្យារ៉ាប់រងនេះក្រុមហ៊ុននឹងធ្វើសំណងចំពោះការបាត់បង់ឬខូចខាតយានយន្តរបស់អ្នកដែលបណ្តាលមកពីទឹកជំនន់,ខ្យល់ព្យុះ,ព្យុះភ្លៀង , បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។

In consideration of the additional Premium that You paid Us for this Endorsement, We agree that the insurance provided under Section II of this Policy will cover loss or damage to Your Vehicle caused by flood, typhoon, hurricane, storm, tempest, volcanic eruption, earthquake, landslide, landslip, subsidence or sinking of the soil/earth or other convulsions of nature.

កូបកម្ម កុប្បកម្ម និង ការបះបោរ
Strike, Riot and Civil Commotion Extension

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះ យើងយល់ព្រមផ្តល់ការធានាបន្ថែមនៃចំណុចទី២ នៃបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុននឹងធ្វើសំណងចំពោះការបាត់បង់ ឬខូចខាតដែលបណ្តាលមកពីៈ

In consideration of the additional Premium that You paid Us for this Endorsement, We agree that the insurance provided under Section II of this Policy will pay a claim under this extension for loss or damage caused by:

ក. កូដកម្ម កុប្បកម្ម និង ការបះបោរ ឬ
Strike, riot and civil commotion; or

ខ. អំពើរបស់អាជ្ញាធរស្របច្បាប់ក្នុងការបង្ក្រាប ឬព្យាយាមបង្ក្រាបនូវការចលាចលទាំងនេះ។
The action of any legal authority to suppress or try to suppress this disturbance

ផលប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល
Personal Accident Benefits Coverage

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះក្រុមហ៊ុននឹងធ្វើសំណងជូនលោកអ្នកឬអ្នកដែលមានសិទ្ធិបើកបរ ឬ អ្នករួមដំណើរ ក្នុងករណី មរណភាព ឬ ការរងរបួសរូបរាងកាយ ឬ ពិការភាពអចិន្ត្រៃយ៍ ដូចដែលបានកំណត់នៅក្នុង តារាងនៃការទូទាត់សំណង ខាងក្រោមដែលបណ្តាលមកពីគ្រោះថ្នាក់ដោយសារយានយន្តរបស់លោកអ្នកដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖
In consideration of the additional Premium that You paid Us for this Endorsement; we will pay you or your passenger or your Authorized Driver compensation for death or bodily injury set out in the Scale of Compensation below as a result of an accident involving your vehicle but only if:

ក. **មរណភាពឬការរងរបួសរូបរាងកាយឬពិការភាពអចិន្ត្រៃយ៍គឺបណ្តាលមកពីការគ្រោះថ្នាក់ខាងក្រៅដែលអាចមើលឃើញបានហើយដែលមិនទាក់ទងនឹងមូលហេតុផ្សេងទៀត (លើកលែងករណីដែលទាក់ទងនឹងការព្យាបាល និងការវះកាត់)។**
Death or bodily injury is caused by violent, accidental, external and visible means and be independent of any other cause (except associated medical and surgical treatment);

ខ. **មរណភាព ឬ ការរងរបួសរូបរាងកាយ ឬ ពិការភាពអចិន្ត្រៃយ៍ ដែលកើតឡើងក្នុងរយៈពេល៣០ថ្ងៃក្រោយពីគ្រោះថ្នាក់។**
Death or bodily injury occurs within 30 days after the accident;

គ. **មរណភាព ឬការរងរបួសរូបរាងកាយ ឬពិការភាពអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពី អំពើបង្ករបួសស្នាមដោយខ្លួនឯង, អំពើអត្តឃាតកម្ម ឬការប៉ុនប៉ងធ្វើអត្តឃាត, ការធ្វើឱ្យខូចខាតដល់រាងកាយ, ពិការភាព ទោះបីដោយផ្ទាល់ ឬមិនផ្ទាល់។**
Death or bodily injury does not arise directly or indirectly out of intentional self-injury, suicide or attempted suicide, physical defect or infirmity;

ឃ. **គ្រោះថ្នាក់មិនត្រូវបានកើតឡើង នៅពេលដែលលោកអ្នកស្ថិតក្រោមឥទ្ធិពលនៃជាតិស្រវឹង ឬគ្រឿងញៀន។**
The accident must not have happened when you are under the influence of intoxicating liquor or drugs;

4 អត្ថប្រយោជន៍នៃការធានា
Policy Benefits

ចំណុចទី១៖ ការទំនួលខុសត្រូវចំពោះភាគីតតិយជន
Section I: Liability To Third Parties

ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើការធានារ៉ាប់រងជូនអ្នក លើគ្រោះថ្នាក់ដែលបណ្តាលមកពី ឬ កើតមាន ឡើងដោយការប្រើប្រាស់យានយន្តរបស់អ្នក ដែលរួមបញ្ចូលទាំងការទាមទារឱ្យបង់ និងចំណាយផ្សេងៗ ដែលអ្នកត្រូវសងស្របតាមច្បាប់សម្រាប់ ៖
Our Company will insure you for an accident caused by or arising out of using your motor vehicle against all amounts, including claimant's cost and expenses you legally have to pay for:

១. **មរណភាព ឬ របួសលើរូបរាងកាយក្នុងកម្រិតអតិបរមាចំនួន ១០ ០០០ (ដប់ពាន់)ដុល្លារ អាម៉េរិកចំពោះបុគ្គលម្នាក់ក្នុងគ្រោះថ្នាក់មួយករណី។**
Death or Bodily Injury maximum limit is USD 10,000 (Ten thousand US Dollars) per person in an accident.

២. **ការខូចខាតទ្រព្យសម្បត្តិ ក្នុងកម្រិតអតិបរមាចំនួន ១០ ០០០ (ដប់ពាន់)ដុល្លារអាម៉េរិក ចំពោះបុគ្គលម្នាក់ក្នុងគ្រោះថ្នាក់មួយករណី។**
Damage to Property maximum limit is USD 10,000 (Ten thousand US Dollars) per person in an accident.

៣. **ថ្លៃសេវាផ្នែកច្បាប់ យើងខ្ញុំនឹងបង់ថ្លៃសេវាផ្នែកច្បាប់ដោយកំណត់ក្នុងកម្រិតអតិបរមាចំនួន ២ ០០០ (ពីរពាន់) ដុល្លារអាម៉េរិក ដើម្បីការពារពីការចោទប្រកាន់ណាមួយ ដោយរួមបញ្ចូលទាំងការចោទប្រកាន់ពីបទធ្វើឱ្យបាត់បង់ជីវិតដោយសារការបើកបរយានយន្ត (ប៉ុន្តែមិនរាប់បញ្ចូលពីបទមនុស្សឃាត)ប្រសិនបើទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីយើងខ្ញុំ។**
Legal Fee: We will pay legal costs with a maximum limit is USD 2,000 (Two thousand US Dollars) for defense of any charge including the charge of causing death by driving the Motor Vehicle (excluded murder) if our prior written agreement had been secured.

គោលការណ៍នេះត្រូវបានកំណត់សម្រាប់ការទទួលខុសត្រូវសរុបរបស់ក្រុមហ៊ុនយើងខ្ញុំដែលមានកម្រិតអតិបរមាចំនួន ១០០ ០០០ (មួយរយពាន់) ដុល្លារអាម៉េរិក ចំពោះគ្រោះថ្នាក់មួយ ឬ គ្រោះថ្នាក់បន្តបន្ទាប់គ្នាដែលកើតចេញពីហេតុការណ៍តែមួយ។
Subject to maximum aggregate limit USD 100,000 (One hundred thousand US Dollars) per accident or series of accident.

ចំណុចទី២៖ ការធានារ៉ាប់រងយានយន្តរបស់លោកអ្នក
Section II: Insurance On Your Vehicle

នេះជាជម្រើសរបស់អ្នកយើងខ្ញុំអាចធ្វើសំណងជាសាច់ប្រាក់សម្រាប់ការខូចខាតទាំងស្រុង ការខូចខាត ឬ អាចនឹងធ្វើការជួសជុលឱ្យដូចដើមវិញ ឬ ផ្លាស់ប្តូរយានយន្ត ឬ ផ្នែកណាមួយនៃយានយន្ត ឬ គ្រឿងបន្លាស់។

At its own option, We may pay in cash the amount of the constructive total loss or damage or may repair, reinstate or replace the Motor Vehicle or any part thereof or its accessories or spare parts.

ការទទួលខុសត្រូវរបស់យើងខ្ញុំមិនអាចលើសពីតម្លៃនៃផ្នែកណាមួយរបស់យានយន្តដែលបានបាត់បង់ឬខូចខាតជាមួយនឹងការសងត្រលប់ស្មើនឹងតម្លៃសមរម្យមួយដូចគ្នានឹងផ្នែកទាំងនោះ។ តម្លៃយានយន្តដែលបុគ្គលត្រូវបានធានារ៉ាប់រង ធ្វើការប៉ាន់ស្មាន និងត្រូវបានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង គឺជាតម្លៃអតិបរមា សម្រាប់ការធ្វើសំណង របស់ក្រុមហ៊ុនយើងខ្ញុំ ក្នុងករណីបណ្តឹងទាមទារសំណងសម្រាប់ការខូចខាតទាំងស្រុង ឬ ការខូចខាតណាមួយ។

The liability of Us shall not exceed the values of the parts lost or damaged and the reasonable cost of fitting such parts. The Insured's estimate of value stated in the Schedule shall be the maximum amount payable by Our Company in respect of any one claim for constructive total loss or damage.

ក្នុងលក្ខខណ្ឌដែលតម្លៃនៃការជួសជុលមិនតិចជាង ៨០% នៃតម្លៃយានយន្តនៅក្នុងអំឡុង ពេលនៃការធានារ៉ាប់រង ក្រុមហ៊ុនយើងខ្ញុំនឹងចាត់ទុកករណីនោះ ជាករណី "យានយន្តខូចខាតទាំងស្រុង" ។ បុគ្គលត្រូវបានធានារ៉ាប់រងត្រូវធ្វើការផ្ទេរសិទ្ធិក្នុងភាពជាម្ចាស់នៃយានយន្ត ជូនមកក្រុមហ៊ុនយើងខ្ញុំជាបន្ទាន់ ហើយការធានារ៉ាប់រងចំពោះយានយន្តនេះត្រូវអស់សុពលភាព។

In the event the repairing cost of the Motor Vehicle is not less than 80% of the value of the Motor Vehicle at the time of insuring, Our Company will be considered that case as Constructive Total Loss. The Insured shall transfer rights of ownership to Our Company immediately and shall be deemed coverage on that Motor Vehicle lapses.

ចំណុចទី៣៖ ធានារ៉ាប់រងបន្ថែមដោយស្វ័យប្រវត្តិ
Section III: Automatic Coverages

សេវាផ្នែកច្បាប់
Legal Fee

គឺជាការចំណាយសមស្របលើសេវាផ្នែកច្បាប់ដែលបានកើតឡើងប្រសិនបើអ្នកបើកបរនៃយានយន្តដែលត្រូវបានធានារ៉ាប់រងត្រូវបានចោទប្រកាន់ពីបទបើកបរដោយខ្វះការប្រុងប្រយ័ត្នដែលបណ្តាលឱ្យមានមនុស្សស្លាប់។ ក្រុមហ៊ុននឹងមិនទូទាត់លើសពី ២,០០០ ដុល្លារអាមេរិកឡើយ សម្រាប់គ្រោះថ្នាក់នីមួយៗ។

Reasonable costs of legal happened if the insured's driver is charged with careless driving causing death. The Company will not pay more than USD 2,000 in respect of any one accident.

ការធានាលើកញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល
Cover for Windscreens, Windows and Sunroof

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុល ឬ តម្លៃផ្លាស់ប្តូរកញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល។

The company will pay compensation for the repair or replacement cost of the Windscreens, Windows and Sunroof.

ម៉ាស៊ីនត្រជាក់ ម៉ាញ៉ែ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត
Air Conditioning Unit, Car Radio, Cassette Player and CD Player

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុល ឬ តម្លៃផ្លាស់ប្តូរម៉ាស៊ីនត្រជាក់ ម៉ាញ៉ែ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត រហូតដល់តម្លៃជួសជុលជាក់ស្តែង ឬក៏តម្លៃនៃការផ្លាស់ប្តូរ។

The company will pay compensation for the repair or replacement cost of the air-conditioning unit and the built-in radio, cassette or CD player up to the actual cost of repair or the full replacement value.

សេវាស្ទូច និងដឹកជញ្ជូនដោយឥតគិតថ្លៃ
Free Towing and Transport

យើងនឹងទូទាត់នូវថ្លៃចំណាយសមស្របក្នុងការបម្លាស់ទីយានយន្តរបស់លោកអ្នកទៅកាន់យានដ្ឋានដែលជាដៃគូសហការរបស់យើងដែលនៅជិតបំផុត។

We will pay the reasonable costs of removing your vehicle to the nearest our Panel Workshop/Garage.

សេវាកម្មអ្នកបើកបរជំនួសដោយឥតគិតថ្លៃ (១ ដង ក្នុងអំឡុងពេលសុពលភាពបណ្ណសន្យារ៉ាប់រង)
Free Designated Driver Service (1 time per period of insurance)

យើងនឹងផ្តល់ជូនសេវាកម្មអ្នកបើកបរជំនួស ដើម្បីបើកបរយានយន្តរបស់អ្នកទៅកាន់លំនៅដ្ឋានរបស់អ្នកត្រូវបានធានារ៉ាប់រង ឬទៅកាន់ទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ដោយមិនមានគិតកម្រៃសេវាឡើយ។
We will provide designated driver service to drive your vehicle to the insured's residence or a designated safe location without any service charge.

ចំណុចទី៤៖ ជម្រើសធានារ៉ាប់រងបន្ថែម
Section IV: Optional Coverage

ការរួមបញ្ចូលនៃហានិភ័យពិសេស
Inclusion of Special Perils

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុលឬតម្លៃផ្លាស់ប្តូរយានយន្តហើយកម្រិតអតិបរមាក្នុងការធ្វើសំណងផ្អែកលើតម្លៃយានយន្តដែលបានប្រកាសក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
The company will pay compensation for the repair or replacement cost of the vehicle, and the maximum payable limitation stated in the Policy Schedule.

កូបកម្ម កុប្បកម្ម និងការបះបោរ
Strike, Riot and Civil Commotion Extension

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុលឬតម្លៃផ្លាស់ប្តូរយានយន្តហើយកម្រិតអតិបរមាក្នុងការធ្វើសំណងផ្អែកលើតម្លៃយានយន្តដែលបានប្រកាសក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
The company will pay compensation for the repair or replacement cost of the vehicle, and the maximum payable limitation stated in the Policy Schedule.

ផលប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល
Personal Accident Benefits Coverage

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងក្នុងចំណោមចំណុចទី១រហូតដល់ចំណុចទី៧ដែលមានចែងក្នុងតារាងនៃការទូទាត់សំណងខាងក្រោមក្នុងរយៈពេលនៃការធានារ៉ាប់រង គឺមិនលើសពី ១០ ០០០ ដុល្លារអាម៉េរិកក្នុងម្នាក់នៅក្នុងគ្រោះថ្នាក់តែមួយ ឬ គ្រោះថ្នាក់តៗគ្នាក្តី ហើយចំនួន សរុបនៃទឹកប្រាក់ត្រូវផ្អែកតាមចំនួនកៅអីដែលបានបំពាក់តាមស្តង់ដារពីក្រុមហ៊ុនផលិតដើមដំបូងសម្រាប់អ្នករួមដំណើរ។ ទឹកប្រាក់អតិបរមាសម្រាប់អ្នកបើកបរគឺ ១០ ០០០ ដុល្លារអាម៉េរិក។
The maximum amount we will pay in total from item 1) to 7) under the Scale of Compensation below during the period of insurance is no more than USD 10,000 per person per accident or series of accident and the aggregate limit is subject to the original number of seats equipped by the manufacturer for your passengers. The maximum amount for your Authorized Driver is USD 10,000.

ល.រ / No.	តារាងនៃការទូទាត់សំណង / Scale of Compensation	ទឹកប្រាក់ទូទាត់សំណង / Amount (USD)
១	**មរណភាព** Death	**១០០០០ ដុល្លារអាម៉េរិក** USD 10,000
២	**ការបាត់បង់ទាំងស្រុងនៃការមើលឃើញរបស់ភ្នែកទាំងគូ** Total and irrecoverable loss of all sight in both eyes	**១០០០០ ដុល្លារអាម៉េរិក** USD 10,000
៣	**ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃ ឬកជើងទាំងសងខាង ឬកដៃម្ខាងនិងកជើងម្ខាង** Total loss by physical severance at or above the wrist or ankle of both hands or both feet or of one hand together with one foot	**១០០០០ ដុល្លារអាម៉េរិក** USD 10,000
៤	**ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃនៃដៃម្ខាង ឬកជើងនៃជើងម្ខាងរួមគ្នាជាមួយនឹងការបាត់បង់ការមើលឃើញនៃភ្នែកម្ខាង** Total loss by physical severance at or above the wrist or ankle of one hand or one foot together with the total and irrecoverable loss of all sight in one eye	**១០០០០ ដុល្លារអាម៉េរិក** USD 10,000

៥	ការបាត់បង់ទាំងស្រុងនៃការមើលឃើញរបស់ភ្នែកម្ខាង Total and irrecoverable loss of all sight in one eye	១០០០០ ដុល្លារអាម៉េរិក USD 10,000
៦	ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃនៃដៃម្ខាង ឬកជើងនៃជើង Total loss by physical severance at or above the wrist or ankle of one hand or foot	១០០០០ ដុល្លារអាម៉េរិក USD 10,000
៧	ចំណាយលើថ្លៃព្យាបាល Medical expenses	១០០០ ដុល្លារអាម៉េរិក USD 1,000

5 ការបង់បុព្វលាភធានារ៉ាប់រង
Premium Payment

របៀប និងមធ្យោបាយបង់បុព្វលាភ
Method and Mode of Premium Payment

បុព្វលាភធានារ៉ាប់រងត្រូវបង់ជាលក្ខណៈប្រចាំឆ្នាំ (បង់សរុបសម្រាប់រយៈពេលមួយឆ្នាំ ឬ សម្រាប់រយៈពេលទាំងមូលនៃកិច្ចសន្យាធានារ៉ាប់រងនិមួយៗ) និងតាមរយៈមធ្យោបាយណាមួយដូចខាងក្រោម៖
Insurance Premium shall be paid on annual basis with the following mode of payment:

ក. **តាមរយៈមូលប្បទានប័ត្រទៅកាន់ «ANGKOR GENERAL INSURANCE PLC.»**
By cheque made payable to "ANGKOR GENERAL INSURANCE PLC."

ខ. **ការផ្ទេរតាមធនាគារដែលមានព័ត៌មានដូចខាងក្រោម៖**
Bank Transfer:

ឈ្មោះគណនី៖ Account Name:	**ANGKOR GENERAL INSURANCE PLC.**
លេខគណនី៖ Account Number:	**016-006-555**
រូបិយបណ្ណ៖ Currency:	**ដុល្លារអាមេរិក / USD**
ឈ្មោះធនាគារ៖ Bank Name:	**ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ / Advanced Bank of Asia Ltd.**

ការធានាអះអាងលើការបង់បុព្វលាភធានារ៉ាប់រង
Premium Payment Warranty

ជាលក្ខខណ្ឌដាច់ខាតស្ថិតក្រោមបណ្ណសន្យារ៉ាប់រងនេះ តម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងក្នុងអំឡុងពេល៣០ថ្ងៃឬតាមចំនួនថ្ងៃកំណត់ក្នុងបណ្ណសន្យារ៉ាប់រងដោយរាប់ពីថ្ងៃដែលបណ្ណសន្យារ៉ាប់រងការធ្វើបដិលេខបន្ថែមវិញ្ញាបនបត្របន្តឡើងវិញចាប់ផ្តើមមានសុពលភាព។ ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពតាម ដូច្នេះបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានលុបចោល ដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបាននូវបុព្វលាភសមាមាត្រទៅតាមរយៈពេលដែលក្រុមហ៊ុនបានធ្វើការធានារ៉ាប់រងលើហានិភ័យ។នៅពេលដែលបុព្វលាភធានារ៉ាប់រងដែលបានបង់តាមលក្ខខណ្ឌមួយនេះត្រូវបានទទួលយក ដោយអន្តរការីធានារ៉ាប់រង ដែលត្រូវបានផ្តល់ជូនសិទ្ធិពីក្រុមហ៊ុន ការបង់បុព្វលាភនេះត្រូវបានចាត់ទុកថាបានទទួលដោយក្រុមហ៊ុនតាមលក្ខខណ្ឌនេះហើយបន្ទុកក្នុងការបញ្ជាក់ថាបុព្វលាភដែលបានបង់នេះបានទទួលពីបុគ្គលម្នាក់ឬមបញ្ចូលអន្តរការីធានារ៉ាប់រង ដែលមិនត្រូវបានផ្តល់ ជូនសិទ្ធិក្នុងការទទួលយកនូវបុព្វលាភនេះគឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន។ យោងទៅតាមលក្ខខណ្ឌ និងខចែងនានាក្រោមបណ្ណសន្យារ៉ាប់រងនេះ។
It is fundamental and absolute special condition of this contract of insurance that the premium due must be paid and received by Us within thirty (30) days or numbers of days stated in the Schedule from the inception date of this Policy / Endorsement / Renewal Certificate. Where the premium payable pursuant to this warranty is received by Our authorized intermediary, the payment shall be deemed to be received by Us for the purposes of this warranty and the onus of proving that the premium payable was received by a person including an insurance intermediary who was not authorized to receive such premium shall lie on Us. Subject otherwise to the terms and conditions of this Policy.

6 ករណីមិនធានា
Exclusion

ករណីមិនធានាក្នុងចំណុចទី១
Exclusions Applicable To Section I

យើងនឹងមិនទទួលខុសត្រូវចំពោះករណីដូចខាងក្រោម៖
We will not be liable for any:

ក. **មរណភាព ឬរបួសរាងកាយ ទៅដល់អ្នកជួមដំណើរ ដែលត្រូវបានដឹកក្នុងគោលបំណងទទួលបានប្រាក់កម្រៃ។**
Death or bodily Injury to any Passenger being carried for hire or reward;

ខ. **មរណភាព ឬរបួសរាងកាយ ទៅដល់បុគ្គលណាម្នាក់ ដែលមរណភាព ឬរបួសកើតឡើងក្នុងកំឡុងពេលនិងក្នុងពេលបំពេញការងារអោយអ្នក ឬអោយអ្នកបើកបររបស់អ្នក។**
Death or bodily Injury to any person where such Death or Injury arises out of and in the course of the employment of such person by You or by Your Authorized Driver;

ចំណាំ៖ ក្នុងពេលបំពេញការងារ ៖ សំដៅដល់បុគ្គលណាដែលរងរបួស ឬមរណភាព (ទោះជាអ្នកជួមដំណើរ ឬក្នុងស្ថានភាពផ្សេងទៀត) ខណៈពេលកំពុងបំពេញការងារ ហើយស្ថិតក្នុងយានយន្ត ដែលជាផ្នែកនៃតួនាទីការងាររបស់គេ។
NOTE: In the course of employment Any person who is injured / dies (whether as Passenger or otherwise) while on the job and is in or on the said Vehicle as part of his/ her employment.

គ. **ការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិណាមួយដែលជាកម្មសិទ្ធិរបស់របស់លោកអ្នកស្ថិតក្រោមការគ្រប់គ្រងនិងមើលការខុសត្រូវដោយអ្នក ឬ អ្នកបើកបរដែលមានការអនុញ្ញាតិពីអ្នក ឬសមាជិកណាមួយនៃសមាជិកគ្រួសាររបស់អ្នក។**
Damage to property belonging to or in the custody of or control of or held in trust by You or Your Authorized Driver or any member of Your Household.

ឃ. **ភារៈទទួលខុសត្រូវណាមួយដែលបង្កឡើងដោយ អ្នកជួមដំណើរនៅក្នុងយានយន្ត ឬ កំពុងបើកបរយានយន្តរបស់អ្នក។**
Liability caused by a Passenger travelling in or alighting from Your Vehicle.

ង. **រាល់ការទាមទារសំណងណាមួយប្រឆាំងនឹងអ្នក ដោយអ្នកបើកបរយានយន្តរបស់អ្នក ទោះបីជាអ្នកបើកបរនោះបានអនុញ្ញាត ឬមិនបានអនុញ្ញាតក៏ដោយ។**
Any claims brought against You by any driver of Your Vehicle, whether authorized or not;

ច. **រាល់ការទាមទារសំណងណាមួយប្រឆាំងនឹងបុគ្គលណាម្នាក់ នៅក្នុងប្រទេសណាមួយ តាមរយៈតុលាការក្រៅប្រទេសកម្ពុជា។**
Any claims brought against any person in any country in court outside Cambodia.

ឆ. **រាល់ការចំណាយផ្នែកច្បាប់ទាំងឡាយណាដែលមិនបានកើតឡើងនៅក្នុងប្រទេសសកម្ពុជាឬមិនអាចទាមទារបាននៅក្នុងប្រទេសកម្ពុជា។**
All legal costs and expenses which are not incurred in or recoverable in Cambodia.

ករណីមិនធានាក្នុងចំណុចទី២
Exclusions Applicable To Section II

យើងនឹងមិនទទួលខុសត្រូវចំពោះករណីដូចខាងក្រោម៖
We will not be liable for any:

ក. **ការជួសជុលទាំងឡាយណាដែលត្រូវបានធ្វើឡើងក្រៅពីយានដ្ឋានដៃគូរបស់ក្រុមហ៊ុន ឬដោយមិនបានយល់ព្រមជាមុនពីខាងក្រុមហ៊ុន**
Repairs carried out without our prior consent.

ខ. **ការចុះតម្លៃ ការសឹករេចរឹល ការខូចខាតប្រព័ន្ធមេការនិច (ម៉ាស៊ីន) ការខូចខាតប្រព័ន្ធភ្លើង។**
Depreciation, wear and tear to your vehicle

គ. **ការខូចមេកានិច ឬអគ្គិសនី ការមិនដំណើរការ ឬការខូចខាតប្រព័ន្ធដែលបណ្តាលមកពីមេរោគ។**
Mechanical or electrical breakdown, failures or breakages caused by malware

ឃ. **ការខូចមេកានិច ឬអគ្គិសនី ការមិនដំណើរការ ឬការខូចខាតប្រព័ន្ធដែលមិនបណ្តាលមកពីគ្រោះថ្នាក់។**
Mechanical, electrical or electronic breakdown, failures or breakages to your vehicle that was not caused by or during the Accident.

ង. ការខូចខាតទៅលើកង់យានយន្ត លើកលែងតែយានយន្តរបស់លោកអ្នកទទួលរងការខូចខាតនៅពេលជាមួយគ្នា។
Damage to tires or rims unless other parts of your vehicle are damaged at the same accident.

ច. ការមិនបានប្រើប្រាស់ ឬផលវិបាកផ្សេងៗដែលបណ្តាលមកពីគ្រោះថ្នាក់។
Loss of use of your vehicle or any other indirect or consequential loss.

ឆ. ការបាត់បង់ឬខូចខាតទៅលើគ្រឿងបន្លាស់ឬគ្រឿងបន្ទាប់បន្សំដែលមិនស្ថិតនៅក្នុងឬបំពាក់ក្នុងយានយន្តក្នុងអំឡុងពេលមានគ្រោះថ្នាក់។
Loss of or damage to accessories when the accessories are not on/in the vehicle at the time of accident.

ជ. ការបាត់បង់ ឬខូចខាតទៅលើគ្រឿងបន្លាស់ ឬគ្រឿងបន្ទាប់បន្សំដោយសារអំពើចោរកម្ម ឬការគាស់ផ្ទះដោយមានការជួយ ឬផ្សំគំនិតពីសមាជិកណាមួយរបស់លោកអ្នកឬអ្នកដែលមានសិទ្ធិបើកបរ បុគ្គលិករបស់លោកអ្នក ឬសមាជិកគ្រួសាររបស់ម្ចាស់ផ្ទះ ឬអ្នកបំរើនៅផ្ទះ។
Loss of or damage to the vehicle as a result of burglary, housebreaking or theft directly or indirectly caused by or with the collusion of any member of your or authorized drivers, business staff or household member of the owner or servant.

ឈ. រាល់ការបាត់បង់តម្លៃនៃយានយន្តរបស់អ្នក ក្នុងពេលកំពុងរក្សាទុក ស្ថិតក្រោមការត្រួតពិនិត្យរបស់ប៉ូលីសចរាចរណ៍ មុនពេលជួសជុល ខណៈពេលដែលការជួសជុលត្រូវបានអនុវត្ត ឬប្រសិនបើយានយន្តត្រូវបានចាត់ទុកថាជាការខូចខាតទាំងស្រុងមិនអាចជួសជុលបាន ឬបាត់បង់ទាំងស្រុង។
Any loss of value of your vehicle whilst in storage, under traffic police's custody, before repairs, whilst the repairs are carried out or if the Vehicle is treated as a Constructive Total Loss or a total loss.

ញ. ការប្រព្រឹត្តមិនត្រឹមត្រូវដោយចេតនារបស់លោកអ្នក ឬ អ្នកដែលមានសិទ្ធិបើកបរ ឬបុគ្គលិករបស់លោកអ្នក ឬ អ្នកបំរើនៅផ្ទះ។
Deliberate misconduct of the owner or authorized drivers or any employee or household member of the owner or servant.

ដ. ការខូចខាត ឬបាត់បង់ ឬការលួចរបស់បរ ឬរបស់ផ្ទាល់ខ្លួនណាមួយនៅក្នុងយានយន្តរបស់អ្នក ដែលមិនមែនជាគ្រឿងបន្លាស់ មិនថានៅពេលមានគ្រោះថ្នាក់ ឬមិនមានក៏ដោយ។
Any damage to or loss or Theft of any items or personal belongings in Your Car, whether at the time of the Accident or otherwise, which do not constitute Accessories.

ថ. ក្រុមហ៊ុននឹងមិនធ្វើសំណងចំពោះ កម្រិតមិនធ្វើសំណង ប្រសិនបើត្រូវបានអនុវត្ត និងមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
Deductible specified in the Policy Schedule.

ករណីមិនធានាអនុវត្តគ្រប់ចំណុចធានាទាំងអស់
Exclusions Applicable To All Sections

ដែនកំណត់ភូមិសាស្ត្រ និងដែនកំណត់ក្នុងការប្រើប្រាស់
Geographical Limits And Limitations As To Use

ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះករណីគ្រោះថ្នាក់ការបាត់បង់, ការខូចខាត, ការរងរបួសឬការទទួលខុសត្រូវដែលបណ្តាលមកពីឬកើតឡើងដោយ៖
We will not be liable for any accident, loss, damage, injury or liability caused, sustained or incurred:

ក. ការប្រណាំងការប្រណាំងដើម្បីដាក់ទីឱ្យគេការសាកល្បងពីភាពអាចជឿទុកចិត្តបានរបស់យានយន្តការសាកល្បងល្បឿនរបស់យានយន្ត
Use for racing, pace making, reliability trial or speed testing;

ខ. ក្រៅពីវិសាលភាពដែនដីនៃប្រទេសកម្ពុជា
Use outside the Geographical Area of Cambodia.

គ. នៅពេលដែលយានយន្តរបស់លោកអ្នកត្រូវបាន៖
When your vehicle is being:

i. បើកបរដោយបុគ្គលដែលមិនត្រូវបានអនុញ្ញាតឱ្យ បើកបរ
Driven by any person who is not an Authorized Driver;

ii. បើកបរដោយបុគ្គលដែលស្ថិតក្រោមក្នុងឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន។ ការកំណត់ពីបទល្មើសរបស់បុគ្គលនេះនឹងត្រូវផ្អែកទៅតាមមាត្រា៧៧នៃច្បាប់ចរាចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧។ ការកំណត់របស់ច្បាប់នេះគឺជាមូលដ្ឋានក្នុងការអនុវត្តការលើកលែងមិនធ្វើសំណងនៅពេលដែលបុគ្គលនោះបានប្រព្រឹត្តបទល្មើសនៅពេលគ្រោះថ្នាក់ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលបង្កឱ្យមានការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

Driven by any person under the influence of intoxicating liquor or drugs. A conviction against such person for an offence under Article 77 of the amendment of Cambodian Traffic Law 26/01/2017 shall be conclusive evidence for the application of this Exclusion where the offence is committed at the time of an accident or other event giving rise to a claim under this Policy;

ii. **ត្រូវបានប្រើឬបើកបរយានយន្តកែច្នៃដោយមិនមានការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា ដោយយោងទៅតាមច្បាប់ចរាចរណ៍នៃ ព្រះរាជាណាចក្រកម្ពុជា ឬពេលដែលការចុះបញ្ជីរបស់យានយន្តក្រោមច្បាប់ចរាចរណ៍ នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានលុបចោល។**

Used or driven with modifications that have not been approved by the Ministry of Public Works & Transport in Cambodia in accordance with the Cambodian Traffic Law or when its registration under the Cambodian Traffic Law has been cancelled.

***ការយោងទៅតាមបទប្បញ្ញត្តិនៃច្បាប់មួយនឹងត្រូវរាប់បញ្ចូលទាំងការធ្វើវិសោធនកម្មនច្បាប់នេះ ឬច្បាប់ជំនួសរបស់វា។**

Reference to a legislation shall be deemed to include any amendment thereof or any corresponding provision in any law in substitution.

ឃ. អ្នកបើកបរដែលមិនមានអាជ្ញាប័ណ្ណ មិនត្រូវបានធានានៅក្រោមធានារ៉ាប់រងនេះទេ ប្រសិនបើអ្នក ឬអ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកមិនមានប័ណ្ណបើកបរដែលមានសុពលភាព (រួមទាំងថ្នាក់ដែលពាក់ព័ន្ធ) ដើម្បីឱ្យអ្នកបើកបរយានយន្តរបស់អ្នកស្ថិតនៅក្រោម ច្បាប់អាជ្ញាប័ណ្ណ ឬបទប្បញ្ញត្តិដែលមានស្រាប់ណាមួយ។ នេះក៏នឹងអនុវត្តផងដែរចំពោះអ្នក ឬ អ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកស្ថិតនៅក្រោមការព្យួរ ឬ ដកសិទ្ធិក្នុងការបើកបរ។

Unlicensed Drivers there is no cover under this policy if You or Your Authorized Driver does not have a valid driving license (including the relevant classes) to drive Your Vehicle under any existing laws, licensing or regulations. This will also apply to if You or Your Authorized Driver is under suspension or disqualification from driving.

ការក្លែងបន្លំ ឬការទាមទារសំណងហួសពីការពិត
Fraud and Exaggerated Claims

ប្រសិនបើការទាមទារសំណងណាមួយមានលក្ខណៈបន្លំឬត្រូវបានធ្វើឱ្យលើសពីការពិតឬប្រសិនបើអ្នកឬបុគ្គលណាម្នាក់ដែលធ្វើសកម្មភាពក្នុងនាមអ្នកប្រើប្រាស់មធ្យោបាយក្លែងបន្លំដើម្បីទទួលបានអត្ថប្រយោជន៍ណាមួយក្រោមបណ្ណសន្យានេះនោះរាល់ការទាមទារសំណងទាំងមូលនឹងមិនត្រូវបានទូទាត់ឡើយ។ ប្រសិនបើយើង ត្រូវបានតម្រូវអោយទូទាត់សំណងទៅកាន់ភាគីតតិយជន យើងមានសិទ្ធិក្នុងការទាមទារសំណងមកវិញ នូវចំនួនទឹកប្រាក់ដែលបានបង់ និងរួមទាំងការចំណាយនានាដែលបានកើតឡើងពីអ្នក។

If any claim is in any part fraudulent or exaggerated, or if You or anyone acting on Your behalf, uses fraudulent means to get any benefit under this Policy, the entire claim will not be paid or payable. If We are required to make payment of any such claim to a Third Party, We shall be entitled to recover the sum paid and any costs incurred from You.

គោលបំណងខុសច្បាប់
Unlawful Purpose

មិនមានការធានា នៅក្រោមបណ្ណសន្យានេះទេ ប្រសិនបើអ្នក ឬអ្នកបើកបរដែលទទួលបានការអនុញ្ញាតពីអ្នក ប្រើប្រាស់យានយន្តរបស់អ្នកក្នុងគោលបំណងខុសច្បាប់ ឬការរួមគំនិតគ្នា ឬការប្រើប្រាស់ ការកាន់កាប់ ឬការដឹកជញ្ជូនសារធាតុវិទ្យុសកម្ម។

There is no cover under this Policy if You or Your Authorized Driver use Your Vehicle for an unlawful or fusion, or the use, handling or transportation of radioactive material.

គ្រោះធម្មជាតិ
Convulsions of Nature

មិនមានការធានា (លើកលែងតែត្រូវបានទិញបន្ថែម) ចំពោះរាល់ការខាតបង់ ការខូចខាត ឬការទទួលខុសត្រូវដែលបង្កឡើងដោយសារ ទឹកជំនន់, ខ្យល់ព្យុះ, ព្យុះភ្លៀង, បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។

There is no cover (unless specifically purchased) for any loss, damage or liability caused by flood, typhoon, hurricane, storm, tempest, volcanic eruption, earthquake. landslide, landslip, subsidence or sinking of the soil/ earth or other convulsions of nature.

ការទទួលខុសត្រូវតាមកិច្ចសន្យា
Contractual Liability

យើងនឹងមិនផ្តល់សំណងចំពោះរាល់ការៈទទួលខុសត្រូវណាមួយដែលកើតឡើងដោយសារឥទ្ធិពលនៃកិច្ចព្រមព្រៀងប៉ុន្តែជាករណីដែលយើងនឹងមិនជាប់កាតព្វកិច្ចទទួលខុសត្រូវឡើយ ប្រសិនបើគ្មានកិច្ចព្រមព្រៀងបែបនោះ។
We will not pay for any liability that arises by virtue of an agreement but for which We would not have been liable in the absence of such agreement.

ប្រាក់ពិន័យការផាក
Fines, Penalties

យើងនឹងមិនផ្តល់សំណងចំពោះ ប្រាក់ពិន័យការផាក ឬការសងជំងឺចិត្តដែលត្រូវបានបង្គាប់ឱ្យអនុវត្តលើអ្នក ឬលើអ្នកបើកបរដែលទទួលបានការអនុញ្ញាតពីអ្នកឡើយ។
We will not pay for any fines, penalties, or aggravated, exemplary or punitive damages imposed on You or Your Authorized Driver.

ករណីមិនធានាលើសង្គ្រាមនិងសង្គ្រាមស៊ីវិល (LIRMA G51)
War and Civil War Exclusion (LIRMA G51)

កិច្ចសន្យាធានារ៉ាប់រងនេះមិនធានាលើទំនួលខុសត្រូវដែលត្រូវទទួលដោយអ្នកត្រូវបាន ធានារ៉ាប់រងសម្រាប់ការបាត់បង់ ឬខូចខាតដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដែលកើត ឡើងដោយ ឬតាមរយៈ ឬជាផលវិបាកនៃសង្គ្រាម ការលុកលុយ ការឈ្លានពានពីសត្រូវ បរទេស ការវាយប្រយុទ្ធ ឬរាល់សកម្មភាពដែលស្រដៀងនឹងសង្គ្រាម(ទោះបីជាសង្គ្រាមនោះត្រូវបានប្រកាសក្តីឬមិនបានប្រកាសក្តី)។សង្គ្រាមស៊ីវិល,សង្កបកម្ម,ការចលាចលស៊ីវិលដែលមានការរីបម្រះ,ការបះបោរយោធា,ចលនាបះបោរបដិវត្តន៍,អំណាចយោធាឬការដណ្តើមអំណាចច្បាប់អាជ្ញាសឹក,ការព័ទ្ធចាប់ចលនាជាតិនិយម, ការឡោមព័ទ្ធ, ការបំផ្លាញទ្រព្យសម្បត្តិដោយសារ ឬក្រោមការបញ្ជារបស់រដ្ឋាភិបាល ឬសាធារណៈ ឬអាជ្ញាធរមូលដ្ឋាន។
This Policy does not cover any liability assumed by the Insured for loss or damage directly or indirectly occasioned by, happening through or in consequence of war, invasion, acts of foreign enemies, hostilities or war-like operations (whether war be declared or not), civil war, mutiny, civil commotion assuming the proportions of or amounting to popular rising, military rising, insurrection, rebellion, revolution, military or usurped power, martial law, confiscation or nationalization or requisition or destruction of or damage to property by or under the order of any Government or public or local authority, all as may be defined in the original policies.

ការវាយប្រហារតាមអិនធឺណែត (CL380)
Cyber Attack Exclusion Clause (CL380)

ក. យោងតាមចំណុច "ខ" ខាងក្រោម គ្មានករណីណាមួយដែលការធានារ៉ាប់រងនេះត្រូវផ្តល់សំណងលើការបាត់បង់ ការខូចខាត ទំនួលខុសត្រូវ ឬការចំណាយដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តីដោយសារ ឬចូលរួមដោយ ឬកើតឡើងពី ការប្រើឬប្រតិបត្តិការ ដែលជាមធ្យោបាយធ្វើឱ្យមានផលប៉ះពាល់ចេញពីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ, កម្មវិធីសូហ្វវែរកុំព្យូទ័រ, កូដដែលធ្វើឱ្យខូចប្រព័ន្ធ មេរោគកុំព្យូទ័រ ឬដំណើរការឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត។

Subject only to clause b. below, in no case shall this insurance cover loss, damage, liability, or expense directly or indirectly caused by, or contributed to by, or arising from, the use or operation, as a means for inflicting harm, of any computer, computer system, computer software program, malicious code, computer virus or process or any other electronic system.

ខ. នៅពេលដែលចំណុចនេះត្រូវបានកែប្រែលើកិច្ចសន្យាធានារ៉ាប់រងដើម្បីធានាលើហានិភ័យសង្គ្រាម, សង្គ្រាមស៊ីវិល, បដិវត្តន៍, ចលនាបះបោរ, ការរីបម្រះ, ជម្លោះស៊ីវិល, អំពើអរិភាពដោយប្រើអំណាច ឬ គេវកម្ម ឬសកម្មភាពរបស់បុគ្គលណាមួយដើម្បីនយោបាយ ដោយសកម្មភាពទាំងនោះកើតចេញពីការប្រើកុំព្យូទ័រ, ប្រព័ន្ធកុំព្យូទ័រ, កម្មវិធីសូហ្វវែរកុំព្យូទ័រ ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀតនៅក្នុងប្រព័ន្ធបើកដំណើរការ និង/ឬ ប្រព័ន្ធ ណែនាំ និង/ឬយន្តការនៃការបាញ់អាវុធ ឬមីស៊ីល។

Where this clause is endorsed on policies covering risks of war, civil war, revolution, rebellion, insurrection, or civil strife arising therefrom, or any hostile act by or against a belligerent power, or terrorism or any person acting from a political motive, Clause 1.1 shall not operate to exclude losses (which would otherwise be covered) arising from the use of any computer, computer system or computer software program or any other electronic system in the launch and/or guidance system and/or firing mechanism of any weapon or missile.

ANGKOR
GENERAL INSURANCE

ករណីមិនធានាលើភេរវកម្ម (NMA 2921)
Terrorism Exclusion Clause (NMA 2921)

ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិលេខណាមួយក៏ដោយ ក៏ការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាម លក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នាឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ។ ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិលេខណាមួយក៏ដោយក៏ការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាម លក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេង ទៀតដែលចូលរួមក្នុងពេលដំណាលគ្នាឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ។

ក្នុងគោលបំណងនៃបដិលេខនេះ អំពើភេរវកម្មសំដៅដល់ការប្រើកម្លាំង ឬហិង្សា និង/ឬ ការគំរាមកំហែងពីបុគ្គលណាម្នាក់ ឬក្រុមណាមួយ មិនថាធ្វើតែឯង ឬក្នុងនាមជាតំណាង ឬពាក់ព័ន្ធនឹងស្ថាប័ន ឬរដ្ឋាភិបាលក្តី ដែលធ្វើឡើងក្នុងគោលបំណង នយោបាយ, សាសនា , មនោគម ឬគោលបំណងដែលស្រដៀងនេះ រួមទាំងចេតនាដើម្បីមានឥទ្ធិពលលើរដ្ឋាភិបាលនិង/ឬធ្វើឱ្យសាធារណជនឬផ្នែកណាមួយនៃសាធារណៈ ឱ្យមានការភ័យខ្លាច។

បដិលេខនេះក៏មិនធានាលើការបាត់បង់ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬ ពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រង ការពារ បង្ក្រាប ឬវិធីណាមួយទាក់ទងនឹង អំពើភេរវកម្ម Edison។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងត្រូវបានចោទប្រកាន់ដោយហេតុផល បដិលេខនេះ ការបាត់បង់ ការខូចខាត ថ្លៃចំណាយមិនត្រូវបានធានាដោយបណ្ណសន្យា រ៉ាប់រងនេះទេ នោះបន្ទុកនៃការអះអាងផ្ទុយពីនេះត្រូវធ្លាក់លើអ្នកត្រូវបានធានារ៉ាប់រង។ក្នុងករណីដែលផ្នែកណាមួយនៃបដិលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន នោះផ្នែកដែលនៅសល់នៅតែមានសុពលភាព និងមានប្រសិទ្ធភាព។

Not with standing any provision to the contrary within this insurance or any endorsement thereto it is agreed that this insurance excludes loss, damage, cost or expense of whatsoever nature directly or indirectly caused by, resulting from or in connection with any act of terrorism regardless of any other cause or event contributing concurrently or in any other sequence to the loss.

For the purpose of this endorsement an act of terrorism means an act, including but not limited to the use of force or violence and/or the threat thereof, of any person or group(s) of persons, whether acting alone or on behalf of or inconnection with any organisation(s) or government(s), committed for political, religious, ideological or similar purposes including the intention to influence any government and/or to put the public, or any section of the public, in fear.

This endorsement also excludes loss, damage, cost or expense of whatsoever nature directly or indirectly caused by, resulting from or in connection with any action taken in controlling, preventing, suppressing or in any way relating to any act of terrorism. If the insurers allege that by reason of this exclusion, any loss, damage, cost or expense is not covered by this insurance the burden of proving the contrary shall be upon the Insured. In the event any portion of this endorsement is found to be invalid or unenforceable, the remainder shall remain in full force and effect.

ករណីមិនធានាលើនយោបាយ
Political Risks Exclusion Clause

ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិលេខណាមួយក៏ដោយ ការ ធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាមលក្ខណៈ ណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬ ពាក់ព័ន្ធនឹងអំពើឬសកម្មភាពដូចខាងក្រោម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នាឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ៖
“ការរឹបអូស ការដកហូត ជាតិនិយម ការបញ្ជាពីមេបញ្ជាការ ការឡោមព័ទ្ធ ការបំផ្លាញ ឬ ការខូចខាតដល់ទ្រព្យសម្បត្តិដោយសារការបញ្ជារបស់រដ្ឋាភិបាល ឬសិទ្ធិអំណាច ឬសាធារណៈ អាជ្ញាធរក្រុង ឬមូលដ្ឋានដែលទ្រព្យសម្បត្តិនោះស្ថិតនៅក្នុងតំបន់នោះ ការចាប់ ឬការ បំផ្លាញក្រោមបទបញ្ជាគយ ឬការដាក់ឱ្យនៅដាច់ដោយឡែកពីគេ”។

Notwithstanding any provision to the contrary within this insurance or any endorsement thereto it is agreed that this insurance excludes loss, damage, cost or expense of whatsoever nature directly or indirectly caused by, resulting from or in connection with the following regardless of any other cause or event contributing concurrently or in any other sequence to the loss;
“Confiscation, expropriation, nationalization, commandeering, requisition or destruction of or damage to property by order of the Government de jure or de facto or any public, municipal or local authority of the country or area in which the property is situated; seizure or destruction under quarantine or customs regulation”.

បដិលេខនេះក៏មិនធានាលើការបាត់បង់ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រង ការពារ បង្ក្រាប ឬវិធីណាមួយទាក់ទងនឹងអំពើខាងលើ។

This endorsement also excludes loss, damage, cost or expense of whatsoever nature directly or indirectly caused by, resulting from or in connection with any action taken in controlling, preventing, suppressing or in any way relating to the above.

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងត្រូវបានចោទប្រកាន់ដោយហេតុផលនៃបដិលេខនេះការបាត់បង់ការខូចខាតថ្លៃចំណាយមិនត្រូវបានធានាដោយបណ្ណសន្យារ៉ាប់រងនេះទេនោះបន្ទុកនៃការអះអាងផ្តួយពីនេះត្រូវធ្លាក់លើអ្នកត្រូវបានធានារ៉ាប់រង។
ក្នុងករណីដែលផ្នែកណាមួយនៃបដិលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាពឬមិនអាចអនុវត្តបាននោះផ្នែកដែលនៅសល់នៅតែមានសុពលភាព និងមានប្រសិទ្ធភាព។

If the underwriters allege that by reason of this exclusion, any loss damage, cost or expense is not covered by this insurance the burden of proving the contrary shall be upon the Assured.
In the event any portion of this endorsement is found to be invalid or unenforceable, the remainder shall remain in full force and effect.

ការបញ្ជាក់អំពីគ្រោះថ្នាក់នៃព័ត៌មានវិទ្យា (NMA2912)
Information Technology Hazards Clarification Clause (NMA2912)

ការបាត់បង់ដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតចេញពី៖
- ការបាត់បង់ ឬការខូចខាត ឬ ការលុបទិន្នន័យនៃប្រព័ន្ធកុំព្យូទ័រ។
- ការកាត់បន្ថយមុខងារ ភាពអាចរកបាន ឬប្រតិបត្តិការនៃប្រព័ន្ធកុំព្យូទ័រ ផ្នែករឹង កម្មវិធី សុវត្ថិភាព ទិន្នន័យ ឃ្លាំងព័ត៌មានមីក្រូឈីប សៀគ្វីរួមបញ្ចូលគ្នា ឬឧបករណ៍ស្រដៀងគ្នា ក្នុងឧបករណ៍ កុំព្យូទ័រ ឬឧបករណ៍មិនមែនកុំព្យូទ័រ ទោះបីជាទ្រព្យសម្បត្តិរបស់អ្នកកាន់ បណ្ណសន្យារ៉ាប់រងក្តី ឬមិនមែនក្តី មិននៅក្នុង និងខ្លួនឯងបង្កើតជាហេតុការណ៍មួយ លុះ ត្រាតែកើតចេញពីហានិភ័យមួយ ឬច្រើនដូចតទៅ៖ អគ្គិភ័យ, រន្ទះ, ការផ្ទុះ,ការធ្លាក់យន្តហោះឬការប៉ះទង្គិចដោយយានយន្តការធ្លាក់របស់លើ ខ្យល់ព្យុះ, ភ្លៀងទឹកកក, ព្យុះកំបុតត្បូង, ព្យុះសីក្លូន, ព្យុះហ៊ែរីឃេន រញ្ជួយផែនដី, ផ្ទុះភ្នំភ្លើង, ស៊ូណាមិ, ទឹកជំនន់, ទឹកកក ឬធ្លាក់ព្រិល។

Losses arising, directly or indirectly, out of:
- loss of, alteration of, or damage to or a reduction in the functionality, availability or operation of a computer system
- hardware, programme, software, data, information repository, microchip, integrated circuit or similar device in computer equipment or non-computer equipment, whether the property of the policy holder of the insurer or not, do not in and of themselves constitute an event unless arising out of one or more of the following perils : fire, lightning, explosion, aircraft or vehicle impact, falling objects, windstorm, hail, tornado, cyclone, hurricane, earthquake, volcano, tsunami, flood, freeze or weight of snow.

ការមិនរាប់បញ្ចូលហានិភ័យថាមពលនុយក្លេអ៊ែរ
Nuclear Energy Risk Exclusion Clause

រាល់ការខាតបង់ ការខូចខាត ឬការទទួលខុសត្រូវក្នុងរូបភាពណាក៏ដោយ ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ឬមានចំណែកបង្កដោយ ឬកើតចេញពី៖ អាវុធ និងសម្ភារៈនុយក្លេអ៊ែរ, កាំរស្មីអ៊ីយ៉ូដ ឬការបំពុលដោយវិទ្យុសកម្មពីឥន្ធនៈនុយក្លេអ៊ែរណាមួយ ឬពីសំណល់នុយក្លេអ៊ែរណាមួយ ដែលកើតចេញពីការឆេះ (រួមទាំងដំណើរការស្វ័យបំភាយនៃប្រតិកម្មបំបែកនុយក្លេអ៊ែរ) នៃឥន្ធនៈនុយក្លេអ៊ែរ។

If loss, damage, or liability of whatsoever nature is directly or indirectly caused by or contributed to or arising from nuclear weapon and materials, ionizing radiations, or contamination by radioactivity from any nuclear fuel or from any nuclear waste from the combustion (including any self-sustaining process of nuclear fission) of nuclear fuel.

ការដាក់ទណ្ឌកម្ម ការដាក់កំហិត និងករណីមិនធានា (LMA3100)
Sanctions Limitation and Exclusion Clause (LMA3100)

ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានសន្មត់មិនផ្តល់ការធានានិងមិនធ្វើសំណងដល់ការទាមទារ ឬ ផ្តល់អត្ថប្រយោជន៍ ប្រសិនបើជាការផ្តល់ការធានានេះ ការធ្វើសំណងនេះ ឬការផ្តល់អត្ថប្រយោជន៍នេះ នឹងបណ្តាលឱ្យក្រុមហ៊ុនធានារ៉ាប់រងប្រឈមនឹងការដាក់ទណ្ឌកម្ម ការហាមឃាត់ ការរឹតត្បិតក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬទណ្ឌកម្មសេដ្ឋកិច្ច ឬ ពាណិជ្ជកម្ម ច្បាប់ ឬបញ្ញត្តិកម្មរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

The Company shall not be deemed to provide cover and not be liable to pay any claim or provide any benefit hereunder to the extent that the provision of such cover, payment of such claim or provision of such benefit would expose that insurer to any sanction, prohibition or restriction under United Nations resolutions or the trade or economic sanctions, laws or regulations or the European Union, United Kingdom or United States of America.

ករណីមិនធានាលើជំងឺរាតត្បាត / កូវីដ១៩
Infectious Diseases / Covid-19 Exclusion

ទោះបីជាមានប្រការណាមួយចែងផ្ទុយពីការធានារ៉ាប់រងនេះក៏ដោយ ការធានារ៉ាប់រងនេះមិនផ្តល់សំណងលើការបាត់បង់ការខូចខាតទំនួលខុសត្រូវ ថ្លៃចំណាយ ប្រាក់ពិន័យ ការផាក ឬចំនួនណាមួយដែលបណ្តាលមកពីជាប់ពាក់ព័ន្ធនឹង ឬទាក់ទងជាមួយឬកើតចេញដោយផ្ទាល់ឬដោយប្រយោលក្តីពីករណីណាមួយខាងក្រោមរួមបញ្ចូលទាំងការភ័យខ្លាចណាមួយ ឬទទួលគំរាមកំហែងពីការឆ្លងនោះ មិនថាឆ្លងពិតមែនក្តី ឬជាការយល់ ឃើញក្តី)៖

- ជំងឺឆ្លងរាតត្បាត មេរោគ បាក់តេរី ឬសារពាង្គកាយផ្សេង ឬបម្រែបម្រួលណាមួយមិនថា វាមានជីវិតក្តី ឬគ្មានក្តី និងអតិសុខុមប្រាណ (មិនថាគ្មានរោគសញ្ញា ឬមានក្តី) ឬ
- មេរោគកូវីដ១៩ រួមទាំងការបំប្លែងខ្លួន ឬបម្រែបម្រួលរូបរាងថ្មីរបស់វា ឬ
- ជំងឺរាតត្បាតដែលប្រកាសដោយអង្គការសុខភាពពិភពលោក ឬអាជ្ញាធររដ្ឋាភិបាល។

Notwithstanding any provision to the contrary, this insurance excludes any loss, damage, liability, expense, fines, penalties or any other amount directly or indirectly caused by, in connection with, or in any way involving or arising out of any of the following – including any fear or threat thereof, whether actual or perceived:

- Any infectious disease, virus, bacterium or other microorganism (whether asymptomatic or not); or
- Coronavirus (COVID-19) including any mutation or variation thereof; or
- Pandemic or epidemic, as declared as such by the World Health Organization or any governmental Authority.

ករណីមិនធានាលើការផ្ទុកលើសចំនួនអ្នករួមដំណើរ
Seating Capacity

បណ្ណសន្យារ៉ាប់រងមិនធានាសម្រាប់គ្រោះថ្នាក់ណាមួយ ការបាត់បង់ ការខូចខាត របួស ឬ ការទទួលខុសត្រូវផ្លូវច្បាប់ ប្រសិនបើចំនួនមនុស្ស (រួមទាំងអ្នកបើកបរ) នៅក្នុងយានយន្ត របស់អ្នកនៅពេលមានឧបទ្ទេវហេតុផ្ទុកលើសពីចំនួនកំណត់សម្រាប់អង្គុយដែលត្រូវបាន អនុញ្ញាតនៅក្រោមច្បាប់ អាជ្ញាប័ណ្ណ ឬបទប្បញ្ញត្តិដែលមានស្រាប់។

For any accident, loss, damage, injury or legal responsibility if the number of people (including the driver) in your vehicle at the time of the accident is more than its legal seating capacity allowed under any existing laws, licensing or regulations.

ករណីមិនធានាលើខ្វះការប្រុងប្រយ័ត្ន
Failure To Take Precaution

ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះការចំណាយបន្ថែមលើការខូចខាត ដែលបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រង និងអ្នកដែលមានសិទ្ធិបើកបរយានយន្តរបស់អ្នកបន្ទាប់ពីមាន គ្រោះថ្នាក់ដោយហេតុថា៖

- ទុកចោលដោយគ្មានការមើលថែឱ្យបានត្រឹមត្រូវ
- ការខកខានក្នុងការប្រុងប្រយ័ត្ន ដើម្បីការពារការបាត់បង់ ឬការខូចខាតបន្ថែមទៀត
- បន្តការបើកបរយានយន្តរបស់អ្នកដែលកំពុងស្ថិតក្នុងស្ថានមិនសក្តិសមមុនពេលទទួលបានការ ជួសជុល
- ទាក់ទងនឹងការខូចខាត ការខាតបង់ ឬការចំណាយដែលកើនឡើងពីការខកខានរបស់អ្នកក្នុងការថែរក្សាសមហេតុផលដើម្បីរក្សាសុវត្ថិភាព និងសុវត្ថិភាពយានយន្តរបស់អ្នក។នេះក៏នឹងរួមបញ្ចូលផងដែរប៉ុន្តែមិនកំណត់ចំពោះការទុកយានយន្តរបស់អ្នកដោយមិន មានការប្រុងប្រយ័ត្ន ឬដោះសោរ និង/ឬទុករថយន្តរបស់អ្នកក្នុងរបៀបបើកបរ ឬការបើកបរបញ្ច្រាស់។

We will not pay for any additional damage caused by you and your authorized driver after an accident by

- Leaving Your Car unattended
- Failure to take precautious to prevent further loss or damage
- Continue to drive your car in an unroadworthy condition prior to any repair being carried out
- In respect of any damages, losses or expenses rising from Your failure to take reasonable care to keep your car safe and secured.
- This also shall include but not limited to leaving Your car unattended or unlocked and/or leaving your car in the drive or reverse mode.

7 ទីតាំងភូមិសាស្ត្រនៃការធានា
Geographical Limit

ទីតាំងភូមិសាស្ត្រនៃការធានានៃកិច្ចសន្យាធានារ៉ាប់រងនេះគឺនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
The geographical limit of this Policy is Kingdom of Cambodia.

8 លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង
Qualification Of Claimants

អ្នកទទួលផល ឬអ្នកទទួលសំណងធានារ៉ាប់រងអាចជាម្ចាស់បណ្ណសន្យារ៉ាប់រង និង/ ឬ ភាគី ម្ចាស់បំណុលដែលជាស្ថាប័នហិរញ្ញវត្ថុស្របច្បាប់ក្នុងករណីយានយន្តដែលបានដាក់ធានារ៉ាប់រងពាក់ព័ន្ធកម្ចីតែប៉ុណ្ណោះដែលមានសិទ្ធិក្នុងការទទួលផលឬសំណងពីក្រុមហ៊ុនយើងខ្ញុំដោយគោរពតាមបញ្ញត្តិ និងលក្ខខណ្ឌនានា ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ សម្រាប់ករណីមានការបង្កគ្រោះថ្នាក់ដល់តតិយជន ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងជូនដល់តតិយជនផ្ទាល់ ដោយត្រូវមានការព្រមព្រៀងគ្នាផងដែរពីភាគីពាក់ព័ន្ធ ក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។

ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ តតិយជនបាត់បង់អាយុជីវិត ក្រុមហ៊ុនយើងនឹង ខ្ញុំផ្តល់សំណងទៅឱ្យក្រុមគ្រួសាររបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ភាគីតតិយជន និង/ឬ ទៅឱ្យអ្នកទទួលផលណាម្នាក់ដែលមានសិទ្ធិទទួលស្របច្បាប់តាមរយៈឯកសារបញ្ជាក់ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។

Only you and/or any lender who are a legal financial institution in term of insured vehicle related with any mortgagee that have the rights to receive any compensation from us regarding to all terms and conditions in this policy. Our Company would pay compensation to the third party directly in terms of claims regarding to have any agreement from related party in this policy.

In terms of has any death of insured and/or third party, we would pay compensation to relative of insured, third party and/or any beneficiary who authorized with related formal documentation.

9 ការកែប្រែកិច្ចសន្យាធានារ៉ាប់រង
Amendment

ក្នុងករណីដែលកិច្ចសន្យាធានារ៉ាប់រងមានការកែប្រែឬមានការបន្ថែមលើបណ្ណសន្យារ៉ាប់រងដើមក្នុងលក្ខខណ្ឌណាមួយគឺតម្រូវឱ្យមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគី ទាំងសងខាង (ក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នកត្រូវបានធានារ៉ាប់រង) ដោយធ្វើការជូនដំណឹងអំពីការកែប្រែនេះតាមរយៈប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិច ឬ ធ្វើជាលិខិតជូនដំណឹងទៅកាន់ភាគីដែលត្រូវបានស្នើឱ្យមានការកែប្រែរាល់ការកែប្រែទាំងអស់មានសុពលភាព លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំ និង ម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នកត្រូវបានធានារ៉ាប់រងនិងមានចែងក្នុងបដិលេខ។ក្នុងករណីមានការខកខានមិនបានជូនដំណឹងអំពីការកែប្រែដូចបានរៀបរាប់ខាងលើលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដើមនឹងត្រូវបានអនុវត្ត ឬបណ្តឹងទាមទារសំណងដែលកើត ឡើងដោយសារការកែប្រែនោះអាចនឹងត្រូវបានបដិសេដ។

Any amendment or additional to any condition on the original policy requires both parties to notify us in writing of such amendment or additional via electronic communication or by sending a written notice to the requesting party. There are amendments or additions to this. All amendments or additions will be valid only with the written consent of The Company and the underwriter/ insurer and stated in the endorsement.
In case of failure to notify the amendment as mentioned above, the terms of the original insurance contract will apply and the claim for damages arising from the amendment may be rejected.

ANGKOR
GENERAL INSURANCE

10 ការបន្តកិច្ចសន្យាធានារ៉ាប់រង
Renewal Policy

កិច្ចសន្យាធានារ៉ាប់រងនេះអាចបន្តឡើងវិញបានយោងតាមការសម្រេចចិត្តរបស់ក្រុមហ៊ុនធានា រ៉ាប់រងដោយផ្អែកលើការបំពេញតាមលក្ខខណ្ឌក្នុងការវាយតម្លៃហានិភ័យ ហើយផ្អែកលើអត្រាបង់បុព្វលាភធានារ៉ាប់រងដែលបានសម្រេចដោយក្រុមហ៊ុនធានារ៉ាប់រង។ នៅពេលមានការស្នើ សុំឱ្យមានការបន្តការធានារ៉ាប់រងជាបណ្តោះអាសន្នរយៈពេលអតិបរមាដែលអាចបន្តបានគឺរយៈពេល៣០ថ្ងៃ។ប្រសិនបើនៅថ្ងៃចុងក្រោយនៃរយៈពេលបន្តនេះ កិច្ចសន្យាធានារ៉ាប់រងត្រូវ បានលុបចោល ឬ ខកខានមិនបន្តដោយហេតុផលផ្សេងៗ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភសម្រាប់រយៈពេល៣០ថ្ងៃដែលបានបន្តជាបណ្តោះអាសន្ននោះតាមអត្រាចំនួនថ្ងៃជាក់(pro-rata premium)។

This Policy is renewable at our option or not invited for a renewal which we will send to the Insured for a renewal notification 30 days before the renewal expiry, subject to underwriting requirements being fulfilled and at the premium rates determined at that time by Us.
Where a request is made to hold cover at renewal, the maximum period that cover can be held will be thirty (30) days. If at the end of this period, the Policy is cancelled or lapses for any reason whatsoever, you must pay us a premium for the number of days the cover was held which will be calculated on pro-rata basis at the renewal premium.

11 ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង
Termination

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានបំណងបញ្ចប់នូវកិច្ចសន្យាធានារ៉ាប់រងនេះ អ្នកត្រូវបាន ធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនក្នុងអំឡុងពេល១០(ដប់)ថ្ងៃមុនពេលដល់កាលកំណត់នៃការលុបចោល។ ក្នុងករណីនេះដែរ ក្រុមហ៊ុននឹងបង្វិលត្រលប់ជូន នូវចំនួន៩០(កៅសិប)ភាគរយនៃបុព្វលាភដែលនៅសល់។សម្រាប់សំណើរនៃការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះប្រសិនបើមានការទាមទារសំណងណាមួយកើតឡើងហើយខាងក្រុមហ៊ុនបានបង់នូវសំណងនោះរួចរាល់នោះក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចក្នុងការបង្វិលសងនូវបុព្វលាភសម្រាប់រយៈពេលដែលនៅសល់នោះទេ។

A 10-days' notice shall be given to The Company in advance if the insured wishes to terminate the insurance before expiry date. Based on reasonable grounds, the insurance Company will refund the insured ninety percent (90%) of the remaining premium.
In case of requesting to terminate the insurance after the risk occurred and The Company has already paid the claim, the insurance Company shall not refund the insurance premium for the remaining period.

12 ការលុបចោលកិច្ចសន្យាធានារ៉ាប់រង
Cancellation

ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលកិច្ចសន្យាធានារ៉ាប់រងតាមរយៈការជូនដំណឹងជា លាយលក្ខណ៍អក្សរទៅកាន់អ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្នុងករណីដូចខាងក្រោម៖

- **បុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់ក្រោយរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងមានសុពលភាព។**
- **ក្រុមហ៊ុនរកឃើញថាម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានការលាក់បាំង ក្លែងបន្លំ និង/ឬ មិនបានបង្ហាញព័ត៌មានពិត។**

The Company also has reserved the rights to cancel this policy by sending thirty (30) days noticed inform you as the following causes:

- Unpaid insurance premium after 30 (thirty) days after the insurance contract is valid.
- We find cases of concealment, fraud and/ or misrepresentation by the policyholder or the insured.

13 ការទាមទារសំណង
Claim

លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង
Qualification Of Claim Proposer

អ្នកដែលអាចបញ្ជូនការទាមទារសំណងសម្រាប់ការបាត់បង់ឬការខូចខាតដែលកើតឡើងអាចជាអ្នកត្រូវបានធានារ៉ាប់រងឬអ្នកតំណាងស្របច្បាប់ចំណែកឯអ្នកទទួលការទូទាត់សំណងគឺ ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកតំណាងស្របច្បាប់។

The one who can submit a claim for an incurred loss can be a Claimant, the Insured or a Legal Representative; the one who receives claim payment/reimbursement is the Policyholder or a Legal Representative.

ការរាយការណ៍ពីគ្រោះថ្នាក់ក្នុងរយៈពេល ២៤ម៉ោង
24 Hours Reporting of Accident

ក្រុមហ៊ុនអាចបដិសេធមិនធ្វើសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនបានរាយការណ៍អំពីគ្រោះថ្នាក់ក្នុងរយៈពេល ២៤ម៉ោងពីពេលកើតហេតុ លើកលែងអ្នកត្រូវបានធានារ៉ាប់រងមានហេតុផលសមស្រប។

The Company may reject claims if the Insured fails to report / notify claims to us within 24 hours from the time of the accident unless the Insured is able to provide Us with acceptable reasons.

នីតិវិធីនៃការផ្តល់ព័ត៌មាន
Procedure of Providing Information

ក. **ក្នុងករណីគ្រោះថ្នាក់ទៅលើយានយន្តរបស់លោកអ្នក ដោយមិនគិតដល់ថាវានឹងមានការទាមទារសំណងកើតឡើង លោកអ្នកតម្រូវឱ្យទាក់ទងមកកាន់ នាយកដ្ឋានទាមទារសំណង យើងខ្ញុំ និងរាយការណ៍អំពីគ្រោះថ្នាក់ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីគ្រោះថ្នាក់។**

In the event of an accident involving your vehicle, regardless of whether a claim will be made, you are required to contact our Claims Department and report the accident within 24 hours of the accident.

ខ. **ក្នុងករណីចោរកម្ម ឬបទល្មើសព្រហ្មទណ្ឌដែលអាចនាំឱ្យមានការទាមទារសំណង ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ លោកអ្នកតម្រូវឱ្យរាយការណ៍មកកាន់ក្រុមហ៊ុន និងប៉ូលីសភ្លាមៗអំពី ការកើតហេតុនិងសហការជាមួយក្រុមហ៊ុនក្នុងការស្វែងអ្នកប្រព្រឹត្តបទល្មើស។**

In the event of theft or criminal offenses that may result in a claim under this insurance contract, you are required to immediately report the incident to the Company and the police and cooperate with the Company in finding the perpetrator.

គ. **រាល់លិខិត ការទាមទារសំណង ដីកាតុលាការ ការកោះឱ្យចូលខ្លួនរបស់តុលាការ និងដីកាបង្គាប់ ឬកោះហៅ ត្រូវជូនដំណឹងមកកាន់ក្រុមហ៊ុនភ្លាមៗ នៅពេលដែលលោកអ្នកបានទទួល។ លោកអ្នកក៏តម្រូវឱ្យជូនដំណឹងមកកាន់ក្រុមហ៊ុនភ្លាមៗដែរបន្ទាប់ពីលោកអ្នក ឬបុគ្គលដែលមានសិទ្ធិក្នុងការទាម ទារសំណង ទទួលបានដំណឹងអំពីការចោទប្រកាន់ ការស៊ើបអង្កេត ការសាកសួរ ឬសំណើណាមួយទាក់ទងនឹងគ្រោះថ្នាក់។**

All letters, demands, court orders, court subpoenas, and orders or summonses must be notified to the company immediately when you get it. You are also required to notify the Company immediately after you or a person entitled to claim compensation becomes aware of any allegation, investigation, inquiry or request relating to the accident.

លក្ខខណ្ឌទាំងនេះគឺជាលក្ខខណ្ឌបឋមមុនការទទួលខុសត្រូវរបស់ក្រុមហ៊ុននិងការមិនគោរពទៅតាមលក្ខខណ្ឌទាំងនេះនឹងបណ្តាលឱ្យអ្នកត្រូវបានធានារ៉ាប់រងបាត់បង់សិទ្ធិក្នុងការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

These conditions are preliminary conditions prior to the liability of the Company and failure to comply with these conditions will result in the insured losing the right to claim compensation under this insurance policy.

ការផ្តល់ឯកសារ ឬភស្តុតាងក្នុងការដោះស្រាយសំណង
Providing Document or Evidence to Support the Claim Process

នៅពេលដាក់ពាក្យទាមទារសំណងមកក្រុមហ៊ុនធានារ៉ាប់រងអ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រងនូវឯកសារដូចជា:

When filing a claim with an insurance company, the Insured must provide the insurance company with the following documents:

ក. **ទម្រង់ទាមទារសំណងដែលបានបំពេញ**
Completed claim form

ខ. **ច្បាប់ចម្លងបណ្ណបើកបររបស់អ្នកបើកបរដែលមានសុពលភាពនៅពេលមានគ្រោះថ្នាក់**
Copy of driver's license valid at the time of the accident

គ. **ច្បាប់ចម្លងបណ្ណសម្គាល់យានយន្ត**
Copy of vehicle registration

ឃ. **ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ**
Copy of identification card

ង. **កិច្ចព្រមព្រៀងច្បាប់ដើមរបស់ក្រុមហ៊ុនធានារ៉ាប់រង(ក្នុងករណីដែលមានសំណងលើភាគីទី ៣)**
Original insurance company agreement (in case of third-party compensation)

ច. ច្បាប់ចម្លងនៃរបាយការណ៍ប៉ូលីស ឬ គំនូសព្រៀងចរាចរណ៍ (ប្រសិនបើមាន)
Copy of police report or traffic ticket (if available)

ឆ. ច្បាប់ចម្លងនៃកិច្ចសន្យាជួល/ បញ្ចាំ (ប្រសិនបើមាន)
Copy of lease/mortgage agreement (if available)

ជ. សោរយានយន្ត និងបណ្ណសម្គាល់យានយន្តច្បាប់ដើម (ក្នុងករណីបាត់ ឬ ករណីយាន យន្តត្រូវបានធានារ៉ាប់រងការខូចខាតទាំងស្រុង)
Original vehicle keys and vehicle registration (in case of loss or if the vehicle is insured for total damage)

ឈ. ទម្រង់វាយតម្លៃនៃការជួសជុល
Repair evaluation form

ញ. ឯកសារព្យាបាលវេជ្ជសាស្ត្រ និងវិក្កយបត្រច្បាប់ដើម (ក្នុងករណីមានរបួសស្នាម)
Original medical records and bills (in case of injury)

ញ. ឯកសារព្យាបាលវេជ្ជសាស្ត្រ និងវិក្កយបត្រច្បាប់ដើម (ក្នុងករណីមានរបួសស្នាម)
Original medical records and bills (in case of injury)

ដ. សៀវភៅគ្រួសារ ឬ សំបុត្រអាពាហ៍ពិពាហ៍ ឬ ឯកសារដែលអាចបញ្ជាក់ពីទំនាក់ទំនង (ក្នុងករណីមរណភាព ឬ របួសស្នាម)
Family book or marriage certificate or documents that can prove relationship (in case of death or injury)

ថ. ឯកសារពាក់ព័ន្ធផ្សេងៗ (ក្នុងករណីចាំបាច់)។
Other relevant documents (if necessary).

រយៈពេលអតិបរមា នៃការទូទាត់សំណងជូនអតិថិជន
Maximum Duration Of Claim Settlement

ក្រុមហ៊ុនធានារ៉ាប់រង នឹងចេញការទូទាត់សំណងធានារ៉ាប់រងជូនអ្នកទាមទារសំណងធានារ៉ាប់រងតាមការកំណត់ដូចខាងក្រោម៖
Insurance companies will issue insurance compensation payments to insurance claimants according to the following criteria:

ក. ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីអ្នកទាមទារសំណងធានារ៉ាប់ងឯកភាពទទួលយកសំណងធានារ៉ាប់រង ចំពោះការទូទាត់ទាត់សំណងទាំងស្រុង ឬ
Within 3 (three) business days after the claimant agrees to accept the insurance claim for full payment of the claim or

ខ. ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទទួលយកសំណងធានារ៉ាប់រង រវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកទាមទារសំណងធានារ៉ាប់រង ចំពោះការទូទាត់សំណងធានារ៉ាប់រង ជាដំណាក់កាល។
Within the period specified in the insurance claim acceptance agreement between the insurance company and the insurance claimant for the payment of insurance claims in stages.

របៀបទូទាត់សំណង
Method Of Claim Payment

ការទូទាត់សំណងគឺធ្វើឡើងតាមរយៈមូលប្បទានបត្រ និង/ឬ ក៏ផ្ទេរពីគណនីធនាគារ។
Payment is made via check and/or transfer from the bank account.

14 ការរក្សាព័ត៌មានសម្ងាត់
Confidentiality

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឲ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឲ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។
The information in which is provided to the insurer shall be kept confidentially, and no any personal information will be provided to any third parties without prior agreement, except it is required or allowed by any law or provision.

15 នីតិវិធីនៃការផ្សះផ្សាវិវាទ
Dispute Resolution

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រងភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជាដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

For any dispute arising in relation to the conduct of insurance business, the disputing parties may bring the case to Insurance Regulator of Cambodia for mediation before filing a lawsuit to arbitration or a competent court, except a criminal case.

16 ច្បាប់ និងយុត្តាធិការ
Law And Jurisdiction

បណ្ណសន្យារ៉ាប់រងនេះត្រូវស្ថិតក្រោម និងបកស្រាយតាមច្បាប់នៃព្រះរាជាណាក្រកម្ពុជា។ ដែនយុត្តាធិការគឺស្របតាមច្បាប់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

The Policy shall be governed by and interpreted in accordance with the Law of the Kingdom of Cambodia. The jurisdiction is the competent court in the Kingdom of Cambodia.

17 លក្ខខណ្ឌនានាអនុវត្តគ្រប់ចំណុចធានាទាំងអស់
Conditions Applicable To All Sections

លក្ខខណ្ឌមុនការទទួលខុសត្រូវរបស់ក្រុមហ៊ុន
Conditions Precedent To The Company's Liability

ការបំពេញនិងគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះដោយលោកអ្នកឬបុគ្គលណាមួយមានសិទ្ធិក្នុងការទាមទារសំណងនិងការពិតនៃសេចក្តីថ្លែងការ និងចំលើយនៅក្នុងបែបបទស្នើសុំធានារ៉ាប់រង គឺជាលក្ខខណ្ឌអាទិភាពជំបូងមុននឹងមានការ ទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការទូទាត់សំណងណាមួយ។

The due observance and fulfillment of the Terms and Conditions of this Policy insofar as they relate to anything to be done or not to be done by you or any person claiming to be indemnified and the truth of the statements and answers in the proposal form shall be conditions precedent to any liability of the Company to make any payment under this Policy.

កាតព្វកិច្ចក្នុងការធ្វើប្រតិវេទ និងការអនុវត្តតាម
Duty Of Disclosure And Compliance

លោកអ្នកតម្រូវឱ្យប្រាប់មកខាងក្រុមហ៊ុននៅហេតុការណ៍ដែលលោកអ្នកដឹងឬគួរតែដឹងដែលប៉ះពាល់ដល់ការសម្រេចចិត្តរបស់យើងខ្ញុំក្នុងការធានាលោកអ្នក។លោកអ្នកតម្រូវឱ្យប្រាប់មកខាងក្រុមហ៊ុនភ្លាមៗប្រសិនបើព័ត៌មានដែលលោកអ្នកបានផ្តល់មកឱ្យខាងក្រុមហ៊ុនមានការផ្លាស់ប្តូរឬលែងត្រឹមត្រូវ។ បើមិនដូច្នោះទេ លោកអ្នកនឹងមិនទទួលបានផលប្រយោជន៍ណាមួយពីកិច្ចសន្យាធានារ៉ាប់រងនេះទេ និង/ឬក្រុមហ៊ុនអាចបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នក។

You must tell us all the facts you know or ought to know which may affect our decision on whether to insure you and on what terms. You must also inform us immediately if any of the information you have given us changes or is no longer accurate. Otherwise you may not receive any benefits under this Policy on any claim and/or we may cancel the Policy.

ការជូនដំណឹងជាលាយលក្ខណ៍អក្សរ
Written Notice

រាល់ការជូនដំណឹង ឬការទាក់ទងគ្នាក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវធ្វើឡើងជា លាយលក្ខណ៍អក្សរ។
Every notice or communication to be made under this Policy shall be given in writing to us.

ការថែទាំយានយន្តរបស់លោកអ្នក
Care of Your Motor Vehicle

លោកអ្នកចាំបាច់ត្រូវថែរក្សាយានយន្តរបស់លោកអ្នកនៅក្នុងលក្ខខណ្ឌល្អនិងដែលអាចបើកបរលើផ្លូវបាន។ក្រុមហ៊ុនមានសិទ្ធិក្នុងការចុះត្រួតពិនិត្យយានយន្តរបស់លោកអ្នកបាន គ្រប់ពេលវេលា និងសាកសួរព័ត៌មានជាមួយអ្នកដែលមានសិទ្ធិបើកបរ។ លោកអ្នកតម្រូវ ឱ្យចាត់ចែងរាល់វិធានការសមរម្យដើម្បីការពារយានយន្តរបស់លោកអ្នកពីការបាត់បង់ ឬខូចខាត។
ក្នុងករណីមានគ្រោះថ្នាក់កើតឡើង យានយន្តរបស់លោកអ្នកមិនត្រូវទុកចោល ដោយគ្មានការមើលថែឱ្យបានត្រឹមត្រូវដើម្បីបង្ការនូវការបាត់បង់ឬខូចខាតថែមទៀតនោះទេ។ ប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានបើកបរមុនពេលដែលមានការជួសជុល ដែលចាំបាច់ ការខូចខាតបន្ថែមទៅលើយានយន្តរបស់លោកអ្នកនឹងមិនត្រូវបានធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះទេ។

You must maintain your Vehicle in an efficient and roadworthy condition. We shall at all times have free and full access to examine your motor vehicle or any part of it and interview any of your Authorized Drivers. You must take all reasonable steps to safeguard your motor vehicle from loss or damage.
In the event of an accident or breakdown, your vehicle must not be left unattended without proper precautions being taken to prevent further loss or damage. If your vehicle is driven before the necessary repairs are made, any extension of the damage or any further damage caused to your vehicle will be excluded from the scope of cover under this Policy.

ការចាត់ចែងដំណើរការរឿងក្តី
Conduct of Proceedings

ក្រុមហ៊ុនមានសិទ្ធិក្នុងការ៖
We are entitled at our option to:

ក. **ចាត់ចែងក្នុងនាមរបស់អ្នកត្រូវបានធានារ៉ាប់រងឬបុគ្គលដែលដែលមានសិទ្ធិទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះដើម្បីការពារក្តី ឬដោះស្រាយសំណង។**
Take over and conduct in your name or the name of any other person claiming for cover under this Policy, the defense or settlement of any claim against you or such person;

ខ. **បន្តក្នុងនាមរបស់អ្នកត្រូវបានធានារ៉ាប់រងឬបុគ្គលដែលមានសិទ្ធិទាមទារសំណងក្នុងការទាមទារសំណងពីបុគ្គលដែលទទួលខុសត្រូវក្នុងការខូចខាត ឬការបាត់បង់ បុគ្គលណាដែលធ្វើការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងត្រូវផ្តល់ឱ្យក្រុមហ៊ុននូវ រាល់ព័ត៌មាន និងកិច្ចសហការតាមការស្នើសុំរបស់ក្រុមហ៊ុន។**
Pursue in your name or the name of such person for our benefit any claim for loss or damage against any person responsible for the loss or damage. Any one claiming for cover under this Policy shall give us all information and assistance as we may require.

ក្រុមហ៊ុនមានសិទ្ធិសម្រេចពេញលេញក្នុងការចាត់ចែងដំណើរការរឿង និងធ្វើការដោះស្រាយសំណង។
We shall have full discretion in the conduct of any proceedings and/or how a claim is settled.

ធានារ៉ាប់រងផ្សេងទៀត
Other Insurances

ប្រសិនបើលោកអ្នកបានធ្វើការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះក្រុមហ៊ុននឹងចូលរួមទទួលខុសត្រូវតាមកម្រិតសមាមាត្រក្នុងករណីដែលអ្នកមានធានារ៉ាប់រងផ្សេងៗ ទៀតធានាលើការខូចខាត ឬការបាត់បង់ ឬការទទួលខុសត្រូវដូចគ្នា។ ក្រុមហ៊ុននឹងមិនធ្វើការធានារ៉ាប់រងចំពោះបុគ្គលណាដែលទទួលបានការធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងផ្សេងទៀតនោះទេ។
If you make a valid claim under this Policy, we are liable to contribute only a pro-rata amount if you have other insurance covering the same damage or loss or liability.
The Policy does not provide cover for any other persons if they have cover under any other insurance policy.

រូបិយវត្ថុ
Currency

បុព្វលាភដែលត្រូវបង់មកឱ្យក្រុមហ៊ុន គឺដុល្លារអាមេរិក។
រាល់សំណងដែលត្រូវបង់ឱ្យអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ជាដុល្លារអាមេរិកលើកលែងមានការព្រមព្រៀងជាមុនប្រសិនបើត្រូវបង់ជារូបិយវត្ថុផ្សេងក្រៅពីដុល្លារអាមេរិក។
រាល់ផលប្រយោជន៍ដែលត្រូវបង់ជារូបិយវត្ថុក្នុងស្រុក (ខ្មែររៀល) ត្រូវប្តូរតាមអត្រាប្តូរប្រាក់ ជាក់ស្តែងនៅពេលមានការទាមទារសំណង។
ប្រការនេះនៅតែមានសុពលភាពរហូតដល់មាននិយ័តកម្មគ្រប់គ្រងការប្រើប្រាស់រូបិយវត្ថុ។

All Premium payable to Us shall be in United States Dollar (USD) currency.
All Claims reimbursement amounts shall be paid in USD unless we have previously agreed otherwise in writing. Benefits paid in a local currency will be converted using the spot rates prevailing at the time We assess the claims.
This Provision remain applicable unless there is a regulation to control the use of currency.

សិទ្ធិក្នុងការជួសជុល
Authority To Repair

ប្រសិនបើយានយន្តរបស់លោកអ្នកទទួលរងការខូចខាតដែលត្រូវបានធានារ៉ាប់រងក្រោមផ្នែកនេះលោកអ្នកអាចមានសិទ្ធិក្នុងការជួសជុលយានយន្តរបស់អ្នកដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖
If your vehicle is damaged and the damage is covered under this Section II, may authorize to repair your vehicle but only if:

ក. **តម្លៃប៉ាន់ស្មាននៃការជួសជុលមិនលើសពី ២០០ ដុល្លាអាមេរិក។**
The estimated cost of the repair does not exceed USD 200;

ខ. **លោកអ្នកត្រូវផ្ញើរមកឱ្យក្រុមហ៊ុននូវតារាងតម្លៃនៃការជួសជុលនិងត្រូវមានការយល់ព្រមពីក្រុមហ៊ុនជាមុនដើម្បីអាចចាប់ផ្តើមជួសជុលបាន។**
You need to send us a quotation of the cost of repair as soon as possible and get our prior consent before you can start repairing your damaged vehicle.

18 នីតិវិធីប្តឹងតវ៉ា
Complaint Procedure

អនុវត្តចំពោះគ្រប់ចំណុចធានាទាំងអស់
Applicable To All Sections

ក្រុមហ៊ុនប្តេជ្ញាក្នុងការផ្តល់សេវាកម្មដ៏ប្រសើរបំផុត ប្រសិនបើអតិថិជនមានការមិនពេញចិត្ត ក្រុមហ៊ុននឹងខិតខំស្វែងរកដំណោះស្រាយភ្លាម ប៉ុន្តែប្រសិនបើក្រុមហ៊ុនមិនអាចដោះស្រាយ បញ្ហាបាន ក្រុមហ៊ុននឹងជូនដំណឹងទៅអតិថិជនក្នុងអំឡុងពេល ៤៨ ម៉ោង ហើយនឹងខិតខំប្រឹង ប្រែងរកដំណោះស្រាយឱ្យអតិថិជនក្នុងអំឡុងពេល៤សប្តាហ៍ប្រសិនបើក្រុមហ៊ុននៅតែមិនអាចផ្តល់ដំណោះស្រាយជូនអតិថិជនក្រុមហ៊ុននឹងជូនដំណឹងដល់អតិថិជននូវរយៈពេលជាក់លាក់មួយដែលក្រុមហ៊ុនអាចរកដំណោះស្រាយជូនអតិថិជនបាន។
Our commitment is to provide an excellent service. If you have a complaint, we will try to resolve it straight away but if we are unable to we will confirm we have received your complaint within forty-eight hours (48 hours) and do our best to resolve the problem within four weeks. If we cannot, we will let you know when an answer may be expected.

ប្រសិនបើអតិថិជនត្រូវការប្តឹងតវ៉ាមិនពេញចិត្ត សូមធ្វើការទំនាក់ទំនងតាមរយៈ:
ក្រុមការងារបម្រើសេវាកម្មអតិថិជនរបស់ក្រុមហ៊ុន៖
If you have a complaint, please contact us at:
Customer satisfaction team

ការិយាល័យកណ្តាល អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក អគារដីឡូតិ៍C ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Head Office of Angkor General Insurance Plc., Building Land Lot C, St. 169, Phum 12, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia

ទូរស័ព្ទលេខ / Tel: +855 78 24 24 24 / +855 87 24 24 24
អ៊ីម៉ែល / Email: complaint-insurance@agi.com.kh

ប្រសិនបើក្រុមហ៊ុនមិនអាចរកដំណោះស្រាយលើបណ្តឹងតវ៉ា ក្នុងរយៈពេល ១២សប្តាហ៍ អ្នកត្រូវបានធានារ៉ាប់រងអាចបន្តប្តឹងទៅ៖
និយ័តករធានារ៉ាប់រងកម្ពុជា អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

If we have not resolved the problem within twelve (12) weeks, You have the right to refer your complaint to:
INSURANCE REGULATOR OF CAMBODIA, MINISTRY OF ECONOMY AND FINANCE
Building # 168 F (6th Floor), Street 598 Sangkat Chraing Chamres 1, Khan Russey Keo Phnom Penh, Kingdom of Cambodia

19 ព័ត៌មានទំនាក់ទំនង
Contact Information

សូមទំនាក់ទំនងក្រុមហ៊ុនតាមរយៈ៖
អង្គរ ជេនេរ៉ាល់ អ៊ិនស្សួរេន ម.ក ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Please contact us at:
ANGKOR GENERAL INSURANCE PLC., Khan 7 Makara, Phnom Penh, Cambodia

ទូរស័ព្ទលេខ / Tel: **+855 78 24 24 24 / +855 87 24 24 24**
អ៊ីម៉ែល / Email: **complaint-insurance@agi.com.kh**

នាយកដ្ឋានវាយតម្លៃហានិភ័យ
Underwriting Department
ទូរស័ព្ទលេខ / Tel: **+855 12 31 63 83**
អ៊ីម៉ែល / Email: **under-writting@agi.com.kh**

នាយកដ្ឋានដោះស្រាយសំណង (ដំណើរការ២៤ម៉ោង ៧ថ្ងៃក្នុង១សប្តាហ៍)
Claims Department (24/7 Claims Service)
ទូរស័ព្ទលេខ / Tel: **1800 20 24 24 (Toll-Free)**
អ៊ីម៉ែល / Email: **claims@agi.com.kh**

ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន ជម្រាបសួរ!

吴哥大众保险，您好！

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្នុងការជ្រើសរើស ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន ម.ក ជាដៃគូការពារប្រកបដោយទំនុកចិត្តរបស់លោកអ្នក។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ចំពោះទំនុកចិត្តរបស់លោកអ្នកមកលើសេវាកម្មធានារ៉ាប់រងរបស់យើងខ្ញុំហើយយើងខ្ញុំនៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់ជូននូវបទដ្ឋានខ្ពស់បំផុតនៃសេវាកម្មថែទាំ ភាពជឿជាក់ និងសុវត្ថិភាពសម្រាប់រាល់អ្វីៗដែលមានតម្លៃបំផុតចំពោះលោកអ្នក។

感谢您选择吴哥大众保险作为您值得信赖的保障伙伴。我们衷心感谢您对我们的信任，并将始终致力于为您最珍视的事物提供最高标准的服务、可靠性与安全保障。

អតិថិជននឹងទទួលបានព័ត៌មានគ្រប់យ៉ាងអំពីបណ្ណសន្យារ៉ាប់រងយានយន្តឯកជនរបស់ក្រុមហ៊ុន អង្គរ ជេនេរ៉ែល អ៊ិនសួរេន មានដូចជា៖

1. តារាងសង្ខេបបណ្ណសន្យារ៉ាប់រង
2. លក្ខខណ្ឌបណ្ណសន្យារ៉ាប់រង
3. នីតិវិធីទាមទារសំណង
4. វិញ្ញាបនបត្រធានារ៉ាប់រង
5. លតាបត្រ
6. ស្ទីកគ័ធានារ៉ាប់រង
7. វិក្កយបត្រ

ចំពោះលតាបត្រ លោកអ្នកត្រូវបិទនៅក្នុងកញ្ចក់មុខខាងស្តាំនៃរថយន្ត។ រីឯស្ទីកគ័ធានារ៉ាប់រង លោកអ្នកអាចបិទនៅខាងក្រោយយានយន្ត ដើម្បីមានភាពងាយស្រួលក្នុងការទំនាក់ទំនងពេលមានអាសន្នណាមួយកើតឡើង។

尊敬的保险客户，您可以在吴哥大众保险的机动车辆保险保单中找到所有与保障范围相关的重要信息，包括：

1. 保单明细
2. 保单条款
3. 理赔流程
4. 保险贴纸
5. 保险凭证
6. 黄色标签
7. 发票

请将黄色标签粘贴于车辆挡风玻璃的右侧，并将保险贴纸粘贴于车辆后方，以便您在紧急情况下更方便地使用相关保障服务。

ពេលមានគ្រោះថ្នាក់សូមទំនាក់ទំនងមកកាន់ក្រុមការងារដោះស្រាយសំណង២៤ម៉ោងដោយឥតគិតថ្លៃពីគ្រប់ប្រព័ន្ធ៖ ១៨០០ ២០ ២៤ ២៤

សម្រាប់ព័ត៌មានផ្សេងៗសូមទំនាក់ទំនងផ្នែកសេវាកម្មអតិថិជនតាមរយៈលេខទូរស័ព្ទ ០៧៨ ២៤ ២៤ ២៤ ឬ ០៨៧ ២៤ ២៤ ២៤
អ៊ីម៉ែល customerservice@agi.com.kh
ក្នុងម៉ោងធ្វើការ ថ្ងៃច័ន្ទ-អាទិត្យ ពីម៉ោង ៩:០០ ព្រឹក ដល់ ៥:៣០ ល្ងាច។

如有与事故相关的事项
请拨打我们的24/7理赔免费热线：1800 20 24 24

一般咨询：
请拨打我们的客户服务中心电话 078 24 24 24 / 087 24 24 24，或发送邮件至 customerservice@agi.com.kh 联系我们（服务时间：周一至周六，上午 8:30 至下午 5:30）。

ANGKOR
GENERAL INSURANCE

មាតិកា
目录

1	និយមន័យ 定义	3
2	កម្មវត្ថុនៃការធានា 受保利益	8
3	វិសាលភាពធានារ៉ាប់រង 保障范围	12
4	អត្ថប្រយោជន៍នៃការធានា 保单利益	14
5	ការបង់បុព្វលាភធានារ៉ាប់រង 保费支付	15
6	ករណីមិនធានា 除外责任	16
7	ទីតាំងភូមិសាស្ត្រនៃការធានា 地域限制	17
8	លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង 索赔人资格	18
9	ការកែប្រែកិច្ចសន្យាធានារ៉ាប់រង 修改	19
10	ការបន្តកិច្ចសន្យាធានារ៉ាប់រង 续保保单	23
11	ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង 终止	24
12	ការលុបចោលកិច្ចសន្យាធានារ៉ាប់រង 取消	25
13	ការទាមទារសំណង 理赔	26
14	ការរក្សាព័ត៌មានសម្ងាត់ 保密性	27
15	នីតិវិធីនៃការផ្សះផ្សាវិវាទ 争议解决	28
16	ច្បាប់និងយុត្តាធិការ 法律与管辖权	29
17	លក្ខខណ្ឌនានាអនុវត្តគ្រប់ចំណុចធានាទាំងអស់ 适用于所有章节的条件	30
18	នីតិវិធីប្តឹងតវ៉ា 投诉处理流程	31
19	ព័ត៌មានទំនាក់ទំនង 联系信息	32

បណ្ណសន្យាធានារ៉ាប់រងយានយន្ត
机动车辆保险条款

ដោយហេតុថាលោកអ្នក (ដែលហៅថា "អ្នកធានារ៉ាប់រង") បានដាក់ពាក្យសុំដើម្បីធានារ៉ាប់រងលើយានយន្តរបស់លោកអ្នកមកកាន់ ក្រុមហ៊ុន អង្គរ ជេនឺរ៉ល អ៊ិនស៊ួរេន(ដែលបន្តបន្ទាប់ទៅនេះហៅថា "ក្រុមហ៊ុន") តាមរយៈទម្រង់បែបបទស្នើសុំធានារ៉ាប់រង និងការអះអាងរបស់លោកអ្នក ដែលត្រូវក្លាយជាមូលដ្ឋាននៃបណ្ណសន្យារ៉ាប់រងនេះ និងដោយហេតុថាលោកអ្នកបានបង់ឬយល់ព្រមបង់នូវបុព្វលាភធានារ៉ាប់រងដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ស្របតាមបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
អាស្រ័យហេតុនេះ បណ្ណសន្យារ៉ាប់រងនេះបញ្ជាក់ថា ផ្អែកទៅលើលក្ខខណ្ឌ ការលើកលែង បញ្ញត្តិ និងការធានាអះអាងទាំងឡាយ ដែលមានចែងនៅក្នុង ឬត្រូវបានកែសម្រួលបន្ថែមលើបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងជូនលោកអ្នក ចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវតាមផ្លូវច្បាប់ ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះដែលកើតឡើងនៅក្នុងអំឡុងពេលនៃការធានារ៉ាប់រង និងនៅក្នុងតំបន់ភូមិសាស្ត្រដែលបានកំណត់។

鉴于被保险人已向吴哥大众保险（以下简称“本公司”）提交投保申请及声明，该申请及声明将作为本保险合同的依据，并视为已纳入本保险合同的一部分；同时，被保险人已支付或同意支付保单明细中所规定的保费，作为本公司根据柬埔寨王国适用法律及法规提供本保险保障的对价；

因此，根据上述内容，并受本保险合同所载或附加的条款、条件、除外责任、限制及批单约定的约束，本公司同意在保险期间内，并在保单明细所规定的地域范围内，就本保单所承保的损失、损害或法律责任向被保险人提供赔偿保障。

1 និយមន័យ
定义

គ្រឿងបន្ទាប់បន្សំ
配件

រាល់ឧបករណ៍សំឡេងវីដេអូនិងឧបករណ៍បន្ទាប់បន្សំតាមស្តង់ដាដើមនៃយានយន្តផ្សេងៗ ដែលបំពាក់ជាប់ជាមួយយានយន្តពីរោងចក្រផលិតយានយន្តតាំងពីមុនពេលដែល យានយន្តត្រូវបានដាក់លក់ជាលើកដំបូង។ គ្រឿងបន្ទាប់បន្សំតាមស្តង់ដាទាំងនេះ ត្រូវបានធានាក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។ ក្រុមហ៊ុននឹងមិនធានាទៅលើគ្រឿងបន្ទាប់បន្សំផ្សេងបន្ថែមទៀតដែលមិនមែនជាគ្រឿងបន្ទាប់បន្សំដើមរបស់យានយន្តទេ លើកលែងតែអ្នកត្រូវបានធានារ៉ាប់រងបានប្រាប់ជាព័ត៌មានទៅក្រុមហ៊ុន ហើយក្រុមហ៊ុនបានយល់ព្រម។
លោកអ្នកអាចនឹងត្រូវបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់គ្រឿងបន្ទាប់បន្សំទាំងនេះ។
本保险涵盖车辆出厂时由车辆制造商安装的所有音响、视频及其他标准配件。这些标准配件均在本保险合同的承保范围内。除非投保人已告知本公司并获得本公司同意，否则本公司不承保任何非原厂配件。您可能需要为这些配件支付额外保费。

គ្រោះថ្នាក់
事故

សំដៅទៅលើព្រឹត្តិការណ៍ភ្លាមៗដែលមិនបានឃើញទុកជាមុន និងដោយចៃដន្យ។
指突然发生、无法预见且属于意外的事件。

ការស្លាប់ដោយចៃដន្យ / ការស្លាប់
意外死亡 / 死亡

មានន័យថា ការស្លាប់ដោយសារគ្រោះថ្នាក់។
指因意外事故导致的死亡。

អ្នកវាយតម្លៃហានិភ័យធានារ៉ាប់រង
理赔查勘员

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករធានារ៉ាប់រងកម្ពុជា (IRC) ហើយត្រូវបានចាត់តាំងដោយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីស៊ើបអង្កេតអំពីមូលហេតុ និងកាលៈទេសៈនៃការខាតបង់ ក៏ដូចជាវាយតម្លៃលើទំហំនៃទឹកប្រាក់នៃការខាតបង់។
由柬埔寨保险监管机构（IRC）许可的个人或机构，并由本公司指定，负责调查损失的原因及相关情况，并评估损失金额。

អ្នកបើកបរដែលមានការអនុញ្ញាត
授权驾驶人

បុគ្គលណាម្នាក់ដែលបើកបរយានយន្តរបស់អ្នក តាមការបញ្ជារបស់អ្នក ឬដោយមានការអនុញ្ញាតពីអ្នក ប៉ុន្តែបុគ្គលនោះចាំបាច់ត្រូវមានបណ្ណបើកបរដែលមានសុពលភាពបើកបរនៅក្នុងប្រទេសកម្ពុជាហើយមិនស្ថិតនៅក្រោមការតាមដាន ឬដកហូតសិទ្ធិក្នុងការបើកបរទេ។
任何在您的指示或经您许可驾驶您车辆的人员，但前提是该人员持有在柬埔寨有效的驾驶执照，且未被吊销或取消驾驶资格。

យានយន្តអាជីវកម្ម
商用车辆

សំដៅដល់យានយន្តដែលត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពអាជីវកម្ម ដូចជា ដឹកជញ្ជូនទំនិញ ឬដឹកជញ្ជូនមនុស្សដើម្បីទទួលបានប្រាក់កម្រៃ ការជួល ដែលប្រភេទការប្រើប្រាស់របស់វាត្រូវបានក្រសួងសាធារណការ និងដឹកជញ្ជូនបានចែងក្នុងបណ្ណសម្គាល់យានយន្តថាជាប្រភេទយានយន្តដឹកអ្នកដំណើរ ឬប្រភេទយានយន្តដឹកទំនិញ។
指任何用于商业活动的车辆，例如以收取费用、租赁或报酬为目的运输货物或人员，并且其使用类型已由公共工程与运输部登记为客运车辆或货运车辆。

កំណត់សំអាង
临时保单

សំដៅដល់ឯកសារបណ្តោះអាសន្នដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឬ អន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់បណ្ណធានារ៉ាប់រងជំនួសបណ្ណសន្យារ៉ាប់រងនៅក្នុងករណីចាំបាច់និងបន្ទាន់ដែលក្រុមហ៊ុនធានារ៉ាប់រង ឬអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់មិនអាចចុះកិច្ចសន្យា និងចេញបណ្ណសន្យារ៉ាប់រងបាន។
指由保险公司或经授权销售保险产品的保险中介机构出具的临时性文件。在必要且紧急的情况下，当保险公司或授权保险中介无法签署合同并签发保险单时，该文件可替代保险单使用。

បទល្មើសរំលោភលើទំនុកចិត្ត
刑事背信

ត្រូវបានបកស្រាយដោយយោងតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឬមានន័យថាៈជនណាមួយដែលត្រូវបានគេធ្វើទំនុកចិត្តឲ្យមើលថែទ្រព្យអ្វីមួយ ទោះតាមរបៀបណាក៏ដោយ ឬដែលមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមួយ ទោះបីជាតែម្នាក់ឯង ឬរួមគ្នាជាមួយបុគ្គលផ្សេងក៏ដោយ បន្លំយកដោយទុច្ចរិតនូវទ្រព្យនោះ ឬបង្ខែទ្រព្យនោះមកជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ចាត់ចែងទ្រព្យនោះដោយទុច្ចរិត ដោយរំលោភលើវិធានច្បាប់ ដែលបញ្ញត្តិពីរបៀបដោះបន្ទុកលើការធ្វើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ឬដោយតុណ្ហភាពដែលអនុញ្ញាតឲ្យខ្លួនរួចបន្ទុកពីការធ្វើទុកនោះ ឬដោយចេតនាបង្កឲ្យបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្ត។
其含义应依据柬埔寨王国刑法第391条的规定，或如下所述：任何人在以任何方式受托持有财产，或单独或与他人共同对财产拥有控制权的情况下，若以不诚实方式侵占或将该财产据为己有，或违反法律规定的信托履行方式，或违反其就该信托履行所订立的明示或默示合同，而不诚实地使用或处分该财产，或故意允许他人如此行为，即构成“刑事背信”。

ការឆបោក
欺骗

ត្រូវបានបកស្រាយដោយយោងតាមមាត្រា៣៧៧នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឬមានន័យថាៈ បុគ្គលណាមួយដែលបោកប្រាស់អ្នកដទៃទៅជាការបោកប្រាស់នោះជាកត្តាតែមួយគត់ឬកត្តាចម្ងាប់ដែលបណ្តាលឱ្យៈ

ក. ជនរងគ្រោះដោយការបោកប្រាស់ប្រគល់ទ្រព្យសម្បត្តិណាមួយឱ្យបុគ្គលណាមួយ ឬយល់ព្រម ឱ្យបុគ្គលណាមួយកាន់កាប់ទ្រព្យសម្បត្តិណាមួយដោយចេតនាឆបោក ឬមិនស្មោះត្រង់ ឬ

ខ. ជនរងគ្រោះដោយការបោកប្រាស់ធ្វើសកម្មភាព ឬ អសកម្មដែលបុគ្គលនោះនឹងមិនធ្វើ ឬមិនធ្វើ ប្រសិនបើមិនត្រូវបានបោកប្រាស់ ហើយសកម្មភាព ឬអសកម្មនោះបណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានការខូចខាតដល់ប្រយោជន៍ផ្លូវចិត្តកិត្តិយស ឬទ្រព្យសម្បត្តិរបស់បុគ្គលណាមួយ។ នោះគឺជា ការឆបោក។

其含义应根据柬埔寨王国刑法第377条的规定，或如下所述：

a. 以欺诈或不诚实手段，使被欺骗者交付任何财产给任何人，或同意由任何人保留任何财产；或

b. 故意使被欺骗者实施某种行为或不作为，而该行为或不作为在未受欺骗的情况下本不会发生，并且该行为或不作为对身体、精神、名誉或财产造成或可能造成损害的，即构成“欺骗”。

កម្រិតមិនធ្វើសំណង
免赔额

ជាចំនួនទឹកប្រាក់ដែលលោកអ្នកត្រូវបង់នៅពេលមានគ្រោះថ្នាក់ម្តងៗ។ កម្រិតមិនធ្វើសំណងត្រូវបានកំណត់ក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង ឬ វិញ្ញាបនបត្រធានារ៉ាប់រង។
您在每次事故中需自行承担的索赔金额。免赔额将载于您的保单明细或保险证明中。免赔额亦称为自负额。

ការទាមទារសំណងនីមួយៗ
每一宗索赔

សំដៅដល់ការទាមទារសំណងមួយ ឬសំណងជាបន្តបន្ទាប់ដែលបណ្តាលមកពីមូលហេតុដើមដូចគ្នា។
指因同一原始原因而产生的单一索赔或一系列索赔。

បដិលេខ
批单

សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនជូនលោកអ្នក ដើម្បីបញ្ជាក់នៅក្នុងបញ្ជីលក្ខខណ្ឌបណ្ណសន្យារ៉ាប់រង។
指由本公司向您出具的文件，用于确认对基本保单保障范围的任何变更或扩展。

ANGKOR
GENERAL INSURANCE

សមាជិកគ្រួសារ
家庭

សំដៅលើសមាជិកទាំងអស់នៃគ្រួសាររបស់អ្នក ឬអ្នកបើកបរដែលមានការអនុញ្ញាតរបស់អ្នក ពោលគឺ ប្តីប្រពន្ធ កូនរួមទាំងកូនចិញ្ចឹម ស្របច្បាប់ ឪពុកម្តាយ បងប្អូនប្រុសស្រី ដែលស្នាក់នៅក្រោមដំបូលតែមួយជាមួយអ្នក ក្នុងករណីគ្រួសារជិតស្និទ្ធរបស់អ្នក ឬជាមួយអ្នកបើកបរដែលមានការអនុញ្ញាតរបស់អ្នកក្នុងករណីគ្រួសារជិតស្និទ្ធរបស់គាត់។
指您或您的授权驾驶人的直系家庭成员，即配偶、子女（包括依法收养的子女）、父母、兄弟及姐妹。在您的直系家庭情况下，指与您共同居住在同一屋檐下的家庭成员；在授权驾驶人家庭情况下，指与其共同居住在同一屋檐下的直系家庭成员。

កិច្ចសន្យាធានារ៉ាប់រង
保险合同

សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលយកហានិភ័យជាក់លាក់ណាមួយដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកត្រូវបានធានារ៉ាប់រង។
指保险人与被保险人之间订立的书面协议，其中保险人同意承保特定风险，并作为对价收取被保险人支付的保费。

ឧប្បត្តិហេតុ
事件

សំដៅទៅលើព្រឹត្តិការណ៍ណាមួយដែលអាចនាំឱ្យមានការទាមទារសំណងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។
指任何可能导致本保单项下索赔的事件。

របួស
伤害

មានន័យថារបួសរាងកាយដែលបង្កឡើងដោយឧបទ្ទវហេតុនិងដោយផ្ទាល់ ដោយមិនគិតពីមូលហេតុផ្សេង ទៀត។
指仅由意外事故直接且单独导致的身体伤害，且不受任何其他原因影响。

សោរ
钥匙

សំដៅដល់សោរឬឧបករណ៍ណាមួយដែលផលិតដោយក្រុមហ៊ុនផលិតយានយន្ត សម្រាប់ចាក់សោរ បញ្ជោះ និងអនុញ្ញាតឱ្យយានយន្តដំណើរការ។
指由您车辆制造商所生产的任何钥匙或装置，用于锁定、进入车辆，并使车辆能够启动及行驶。

តម្លៃទីផ្សារ
市场价值

តម្លៃនៃការផ្លាស់ប្តូរយានយន្តរបស់លោកអ្នកជាមួយនឹងយានយន្តមួយទៀតដែលមានម៉ាក ឆ្នាំផលិត និងលក្ខខណ្ឌស្រដៀងគ្នាទៅនឹងយានយន្តរបស់លោកអ្នក និងអាចរកទិញបានមុនពេលកើតហេតុ។
以与您的机动车同品牌、同型号，且在事故或损失发生前一刻具有相似车况及使用年限、并可立即购得的车辆进行替换所需的成本。

ម្ចាស់បណ្ណសន្យារ៉ាប់រង
投保人

សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានកម្មសិទ្ធស្របច្បាប់ចំពោះបណ្ណសន្យារ៉ាប់រង។
指依法对保险单享有合法权利的自然人或法人。

បុព្វលាភធានារ៉ាប់រង
保险费

សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងតាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង។
指被保险人根据保险合同向保险人支付的金额，作为保险人承担保险责任的对价。

អ្នកត្រូវបានធានារ៉ាប់រង
被保险人

សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញបណ្ណធានារ៉ាប់រងហើយក្នុងករណីខ្លះ អ្នកត្រូវបានធានារ៉ាប់រងអាចជាម្ចាស់បណ្ណធានារ៉ាប់រងផង និងជាអ្នកត្រូវបានធានារ៉ាប់រងផងដែរ។
指购买保险单的自然人或法人，在某些情况下，被保险人也可以同时是投保人及被保险人。

សកម្មភាពភេរវកម្ម
恐怖行为

សំដៅដល់ រាល់សកម្មភាពហិង្សា ឬការប្រើកម្លាំងបាយ ឬការគំរាមកំហែងដោយប្រើអំពើហិង្សា ឬកម្លាំងបាយ ដែលប្រព្រឹត្តដោយបុគ្គលឬក្រុមណាមួយទោះជាធ្វើឡើងដោយឯករាជ្យឬក្នុងនាមឬមានទំនាក់ទំនងជាមួយអង្គការ ឬរដ្ឋាភិបាលណាមួយ ដោយមានគោលបំណងផ្នែកនយោបាយ សាសនា មនោគមវិជ្ជា ពូជសាសន៍ ឬគោលបំណងផ្សេងៗទៀតរួមទាំងការប៉ុនប៉ងធ្វើអោយមានឥទ្ធិពលលើសកម្មភាពរបស់រដ្ឋាភិបាល និង/ឬ បង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬផ្នែកណាមួយនៃសាធារណជន។
指任何个人或团体实施的任何暴力或武力行为，或暴力或武力威胁，无论是独立实施，还是代表或与任何组织或政府有关联而实施，且出于政治、宗教、意识形态、种族或其他动机，包括试图影响政府行为和/或使公众或部分公众感到恐惧的行为。

វិសាលភាពដែនដី
地理区域

សំដៅដល់ដែនកំណត់ភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រង។
指保单明细中所载明的柬埔寨王国境内地域范围。

យានដ្ឋានដៃគូរ
合作维修厂

សំដៅដល់យានដ្ឋានជួសជុលយានយន្តដែលបានអនុម័តដោយយើង ហើយអាចប្រើប្រាស់សម្រាប់ការទាមទារសំណង។
指由本公司认可用于理赔维修的汽车维修厂。

អ្នកដំណើរ
乘客

សំដៅដល់បុគ្គលណាមួយដែលស្ថិតនៅក្នុងយានយន្តរបស់លោកអ្នក កំពុងឡើងឬចុះឬកំពុងត្រូវបានដឹកជញ្ជូននៅក្នុងយានយន្តក្នុងពេលកើតមានព្រឹត្តិការណ៍។ លក្ខខណ្ឌនេះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌនៃប័ណ្ណ សន្យារ៉ាប់រងនេះ។
指在事故发生时正在车内、正在上下车或正在被您的车辆运输的任何人员，但须受本保单的条款及条件约束。

ការខូចខាតទាំងស្រុង/ ការខូចខាតស្ទើរទាំងស្រុង
全损 / 推定全损

ប្រសិនបើយានយន្តរបស់អ្នករងការខូចខាត ឬបំផ្លិចបំផ្លាញ រហូតដល់កម្រិតមួយដែលមិនអាចជួសជុលដោយដូចស្ថានភាពដើមវិញបាន នោះនឹងត្រូវបានចាត់ទុកថា ការខូចខាតទាំងស្រុង។ បើសិនជាការខូចខាតយានយន្តរបស់អ្នកអាចជួសជុលបានប៉ុន្តែការចំណាយការជួសជុលលើសពី ៨០% នៃតម្លៃទីផ្សារនៃយានយន្តរបស់អ្នកនៅពេលបាត់បង់ នោះនឹងត្រូវបានចាត់ទុកថា ការខូចខាតស្ទើរទាំងស្រុង។
如果您的车辆损坏或毁坏程度已无法修复或恢复至事故发生前的状态，则视为“全损”。如果车辆损坏仍可修复，但修理费用超过事故发生时车辆市场价值的80%，则视为“推定全损”。

បណ្ណសន្យារ៉ាប់រង
保单条款

សំដៅដល់ឯកសារមួយនៃ កិច្ចសន្យាធានារ៉ាប់រងជាក់លាក់ដើម្បីប្រើប្រាស់ជាតស្មុតាងសម្រាប់បង្កើតកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងត្រូវចុះហត្ថលេខា ឬប្រថាប់ត្រាដោយក្រុមហ៊ុនធានារ៉ាប់រង ឬដោយអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់ផលិតផលធានារ៉ាប់រង។
指由保险公司签发的具有法律约束力的文件，其中载明保险合同中保险人与被保险人双方所约定的主要内容及详细条款与条件。本保单应与保险证明及/或其他相关文件一并附带使用。

តារាងសង្ខេបបណ្ណសន្យារ៉ាប់រង
保单明细 / 保险证明

សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងលើសេចក្តីសង្ខេបពីខសន្យា លក្ខខណ្ឌនានា ករណីមិនធានា និងបុព្វលាភធារ៉ាប់រង ដែលត្រូវបានកំណត់ថ្លៃនិងផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រង។
由保险公司签发的文件，用于概述保险条款、条件、除外责任及所收取的保费，并提供给被保险人。

រយៈពេលនៃការធានារ៉ាប់រង
保险期间

រយៈពេលនៃការធានាដែលបង្ហាញនៅលើកាលវិភាគបណ្ណធានារ៉ាប់រងរបស់អ្នកនិងសម្រាប់រយៈពេលបន្ទាប់ណាមួយដែលការធានាត្រូវបានបន្តដោយកិច្ចព្រមព្រៀងទៅវិញទៅមក។
保单明细中所载明的保障期间，以及经双方共同同意延长保障的任何后续期间。

យានយន្តឯកជន
私家车辆

សំដៅដល់យានយន្តដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរធម្មតាសម្រាប់ទិសដៅសង្គម គ្រួសារសម្រាប់ប្រើប្រាស់ពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកដែលត្រូវបានធានារ៉ាប់រងដូចដែលត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង (មិនរាប់បញ្ចូលសម្ភពអាជីវកម្ម ឬការប្រើប្រាស់ណាមួយដែលទាក់ទងនឹងការជួល, ការដឹកជញ្ជូនមនុស្ស ឬទំនិញដើម្បីទទួលបានប្រាក់កំរៃ)។
指用于社交、家庭及休闲用途，以及与保险证明中所述的被保险业务相关用途的车辆（不包括以营运、租赁或报酬为目的的商业活动，例如运输货物或人员换取费用）。

កូដកម្ម កុប្បកម្ម និងការបះបោរ
罢工、暴乱、民众骚乱

ជាអំពើរបស់បុគ្គលណាមួយដែលបានចូលរួមក្នុងសកម្មភាពចលាចលសង្គមណាមួយទោះបីជាមានឬមិនមានការពាក់ព័ន្ធជាមួយនឹងសកម្មភាពកូដកម្ម ឬ LOCK-OUT (ការចាក់សោរមិនឱ្យកម្មករចូលក្នុងរោងចក្រ)។
任何人参与任何社会动乱的行为，无论是否与罢工或封锁（阻止工人进入工作场所）有关。

ទឹកប្រាក់ធានារ៉ាប់រង
保险金额

ទឹកប្រាក់អតិបរិមាដែលក្រុមហ៊ុននឹងត្រូវសងក្នុងការទាមទារសំណងចំពោះការបាត់បង់ ឬ ខូចខាតទៅលើយានយន្តរបស់លោកអ្នក។
对于您车辆的损失或损坏索赔，本公司所承担的最高赔付金额。

តតិយជន
第三方

ជាបុគ្គលដែលមិនមែនជាភាគីនៃកិច្ចសន្យាធានារ៉ាប់រងនេះ។
指除本保单相关各方之外的任何其他人员。

ការដឹកជញ្ជូន
运输

សំដៅដល់ការដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត(រួមបញ្ចូលទាំងអំឡុងពេលលើកដាក់ទំនិញ/យានយន្តឡើង និងចុះ) នៃយានយន្តរបស់លោកអ្នក ដោយស្ថិតក្រោមលក្ខខណ្ឌ និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រង។
指在符合本保单条款、条件及除外责任的前提下，对您的车辆从一个地点运送至另一个地点（包括装载及卸载过程）。

យើង / OURS / ក្រុមហ៊ុនធានារ៉ាប់រង
本公司 / 我们 / 本公司 / 保险公司 / 承保人

សំដៅដល់ក្រុមហ៊ុន អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក
指吴哥大众保险股份有限公司。

អ្នក / ខ្លួនអ្នក / របស់អ្នក
您 / 您本人 / 您的

សំដៅដល់អ្នកត្រូវបានធានារ៉ាប់រងឬម្ចាស់បណ្ណសន្យារ៉ាប់រងដែលបានកំណត់នៅក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រង។
指保单明细中所列的投保人及/或被保险人。

យានយន្តរបស់លោកអ្នក
您的车辆

សំដៅដល់យានយន្តដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងរួមបញ្ចូលគ្រឿងបន្សំដែលបំពាក់ចេញពីស្តង់ដាររបស់រោងចក្រផលិតនិងគ្រឿងបន្សំដែលបំពាក់បន្ថែមផ្សេងទៀតដូចដែលបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
指保单明细中所列明的机动车辆，包括原厂标准配件，以及保单明细中明确列出的任何附加配件。

2 កម្មវត្ថុនៃការធានា
保险利益

កម្មវត្ថុនៃការធានាដែលត្រូវយកមកអនុវត្តស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះមាន៖
本保单的保险利益包括：

- យានយន្តឯកជន
  私家车辆
- យានយន្តអាជីវកម្ម
  商业车辆

3 វិសាលភាពធានារ៉ាប់រង
保险保障范围

ចំណុចទី១៖ ការទំនួលខុសត្រូវចំពោះភាគីតតិយជន
第一部分：对第三方的责任保险

ក្រុមហ៊ុននឹងផ្តល់សំណងចំពោះការបាត់បង់អាយុជីវិត ឬរបួសរាងកាយ និង/ឬ ការខូចខាតទ្រព្យសម្បត្តិរបស់ភាគីតតិយជន ដែលបង្កឡើងដោយគ្រោះថ្នាក់ដែលកើតចេញពីការប្រើប្រាស់យានយន្តដែលត្រូវបានធានា ហើយដែលអ្នកត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចទទួលខុសត្រូវ។
本公司应就因使用被保险车辆所引起的事故，造成第三者死亡、身体伤害及/或财产损失，且被保险人依法应承担法律责任的部分予以赔偿。

ក្រុមហ៊ុននឹងផ្តល់សំណងដូចខាងក្រោម៖
本公司将予以赔偿：

- មរណភាព ឬរបួសរ៉ាងកាយលើបុគ្គលណាមួយ លើកលែងតែបុគ្គលដែលត្រូវបានដាក់បញ្ចូលក្នុងករណីមិនធានា ដូចមានចែងក្នុងករណីមិនធានាក្នុងចំណុចទីមួយ។
  任何人的死亡或严重身体伤害，但第一点中未投保人除外。
- ការខូចខាតទ្រព្យសម្បត្តិរបស់បុគ្គលណាមួយលើកលែងតែទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលត្រូវបានបញ្ចូលក្នុងករណីមិនធានាក្នុងចំណុចទីមួយ។
  任何人的财产损失，但不包括属于第一部分除外责任中明确排除的人员的财产。

ដោយត្រូវគោរពលក្ខខណ្ឌថា អ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកត្រូវអនុវត្ត និងគោរពតាមគ្រប់ខសន្យា និងលក្ខខណ្ឌនានានៃកិច្ចសន្យាធានារ៉ាប់រងនេះ ដូចដែលលោកអ្នកត្រូវគោរពតាម និងមិនត្រូវបានមានសិទ្ធិទទួលបានការធានាក្រោមកិច្ចសន្យាធានារ៉ាប់រងណាមួយផ្សេងក្រៅពីនេះទៀតទេ។

但前提是，您的授权驾驶员亦须遵守本保单的所有条款与条件，并且不得在其他任何保单项下享有保险保障权益。

ចំណុចទី២៖ ការធានារ៉ាប់រងយានយន្តរបស់អ្នក
第二部分：车辆保险

ក្នុងអំឡុងពេលធានារ៉ាប់រងប្រសិនបើយានយន្តរបស់លោកអ្នករងការខូចខាតឬបាត់បង់ដោយសារហេតុការណ៍ដូចខាងក្រោមនេះយើងនឹងទូទាត់សំណង៖

若您的车辆在保险期间内因以下情形发生损失或损坏，本公司将对您予以赔偿：

(ក) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់យានយន្តជាយថាហេតុ។
因意外碰撞或倾覆造成的损失，

(ខ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់ដែលបណ្តាលមកពីបញ្ហាម៉ាស៊ីន។
因机械故障导致的碰撞或倾覆，

(គ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់ដែលបណ្តាលមកពីការទ្រុឌទ្រោម និងចាស់។
因磨损导致的碰撞或倾覆，

(ឃ) ការខូចខាតដែលបណ្តាលមកពីការប៉ះទង្គិចដោយវត្តុដែលធ្លាក់មកពីលើប៉ុន្តែមិនរាប់បញ្ចូលការខូចខាតដែលរួមចំណែកបង្កដោយទឹកជំនន់ , ខ្យល់ព្យុះ, ព្យុះភ្លៀង, បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។
因坠落物体造成的冲击损坏，但不包括洪水、台风、飓风、风暴、暴风雨、火山喷发、地震、山崩、滑坡、地面沉降或地陷，或其他自然灾害引起的情形，

(ង) អគ្គិភ័យ, ការផ្ទុះ ឬរន្ទះ។
因火灾、爆炸或雷击造成的损失，

(ច) អំពើចោរកម្ម
因入室盗窃、破门盗窃或盗窃造成的损失，

(ឆ) ដោយសារអំពើព្យាបាទ
因恶意行为造成的损失，

(ជ) នៅពេលដែលយានយន្តរបស់លោកអ្នកត្រូវបានដឹកជញ្ជូន (រួមទាំងការលើកដាក់ទំនិញ/យានយន្តឡើង និង ចុះ) ដោយវិធីសាស្ត្រដូចខាងក្រោម៖
在运输过程中（包括装卸期间）因以下情形造成的损失：

- ការដឹកជញ្ជូនតាមផ្លូវគោក។
  道路
- ការដឹកជញ្ជូនតាមផ្លូវដែក។
  铁路
- ការដឹកជញ្ជូនតាមផ្លូវទឹក ដូចជាទន្លេ ប្រឡាយជាដើម
  内河水路，即通过河流或运河等水域运输。
- ការដឹកជញ្ជូនឆ្លងកាត់សមុទ្រតាមរយៈ ដូចជាសាឡាង, កប៉ាល់ ឬមធ្យោបាយដឹកជញ្ជូនតាមសមុទ្រផ្សេងទៀត។
  通过渡轮、船舶或任何海上航行船只等跨海运输。

ការខូចខាត ឬ បាត់បង់កើតឡើងក្នុងអំឡុងពេលធានារ៉ាប់រង ចំពោះយានយន្តដែលត្រូវបានធានា រួមទាំងគ្រឿងបន្លាស់ គ្រឿងតុបតែង ឬបរិក្ខារផ្សេងៗដែលជាស្តង់ដារចេញពីរោងចក្រ ក៏ដូចជាគ្រឿងបន្លាស់ ឬគ្រឿងតុបតែងបន្ថែមណាមួយដែលអ្នកត្រូវបានធានារ៉ាប់រងបានដាក់ធានា។

在保险期间内发生于被保险车辆的损失或损害，包括车辆原厂标准配置的设备、配件或固定装置，以及被保险人已申报的任何附加设备或配件。

នៅពេលដែលមានការខូចខាតទៅដល់យានយន្តដែលត្រូវបានធានានៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងផ្តល់សំណងសម្រាប់៖
当本保单项下被保险车辆发生承保范围内的损失时，本公司应予以赔偿：

- ការជួសជុលយានយន្តរបស់អ្នកត្រូវបានធានារ៉ាប់រង ឬធ្វើឲ្យដូចសភាពដើមវិញ ឬផ្លាស់ប្តូរយានយន្ត។
  修理、恢复原状或更换被保险车辆。
- ទូទាត់ជូនអ្នកត្រូវបានធានារ៉ាប់រងនូវថ្លៃចំណាយសមស្របសម្រាប់ការជួសជុលយានយន្ត ឬ
  向被保险人支付合理的修理费用，或
- ថ្លៃចំណាយការការពារ និងសណ្តោងយានយន្ត ចាប់ពីថ្ងៃកើតមានគ្រោះថ្នាក់រហូតដល់ការជួសជុលត្រូវបានបញ្ចប់ ឬសំណងត្រូវបានទូទាត់ប៉ុន្តែមិនលើសពី ៣០០ ដុល្លារអាមេរិកឡើយ។
  从事故发生之日起至维修完成或赔偿支付之日止，车辆保护和拖车费用，但不得超过 300 美元。

ការទទួលខុសត្រូវរបស់ក្រុមហ៊ុន មិនត្រូវលើសពីកម្រិតនៃទំហំទទួលខុសត្រូវ ដែលបានបញ្ជាក់នៅក្នុងតារាងអត្ថប្រយោជន៍នៃបណ្ណសន្យារ៉ាប់រងឡើយ។
本公司的责任不得超过利益表中规定的责任限额。

នៅពេលមានការបាត់បង់ ឬ ការខូចខាតកើតឡើង ប្រសិនបើចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងរបស់យានយន្តដែលត្រូវបានធានា មានតម្លៃតិចជាង ៨០% នៃតម្លៃទីផ្សារ នោះក្រុមហ៊ុននឹងទូទាត់សំណងតែតាមសមាមាត្រនៃតម្លៃជួសជុលរវាងចំនួនទឹកប្រាក់ធានារ៉ាប់រង បើធៀបនឹងតម្លៃទីផ្សារជាក់ស្តែងនៃយានយន្តនោះតែប៉ុណ្ណោះ។
在发生损失时，如被保险车辆的保险金额低于其市场价值的80%，则本公司仅按保险金额与车辆市场价值之比例，支付相应比例的修理费用。

ចំណុចទី៣៖ ធានារ៉ាប់រងបន្ថែមដោយស្វ័យប្រវត្តិ
第三部分：自动扩展保障

សេវាផ្នែកច្បាប់
法律费用

គឺជាការចំណាយសមស្របលើសេវាផ្នែកច្បាប់ដែលបានកើតឡើងប្រសិនបើអ្នកបើកបរនៃយានយន្តដែលត្រូវបានធានារ៉ាប់រងត្រូវបានចោទប្រកាន់ពីបទបើកបរដោយ ខ្វះការប្រុងប្រយ័ត្នដែលបណ្តាលឱ្យមានមនុស្សស្លាប់។ក្រុមហ៊ុននឹងមិនទូទាត់លើសពី ២,០០០ ដុល្លារអាមេរិកឡើយ សម្រាប់គ្រោះថ្នាក់នីមួយៗ។
如被保险车辆驾驶员因过失驾驶导致他人死亡而被起诉所产生的合理法律费用。本公司就任何一次事故的赔偿金额不超过2,000美元。

ការធានាលើកញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល
挡风玻璃、车窗及天窗保障

ក្រុមហ៊ុននឹងបន្ថែមការធានាដែលផ្តល់ជូននៅក្នុងចំណុចទី ២ នៃបណ្ណសន្យារ៉ាប់រងនេះ ចំពោះការទាមទារសំណងរបស់លោកអ្នក សម្រាប់ការ ចំណាយលើការជួសជុល ឬការផ្លាស់ប្តូរ កញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល នៃយានយន្តរបស់អ្នកបន្ទាប់ពីមានការប្រេះស្រាំ ឬបែកបាក់ (ក្នុងលក្ខខណ្ឌដែលមិនមានការខូចខាតផ្សេងទៀតដល់យានយន្តនោះឡើយ)។ លោកអ្នកអាចធ្វើការទាមទារសំណងមួយដងក្រោមអត្ថប្រយោជន៍នេះក្នុងអំឡុងពេលនៃការធានា ដោយមិនបាត់បង់នូវសិទ្ធិទទួលបានការបញ្ចុះតម្លៃក្នុងករណីមិនធ្លាប់ទាមទារសំណង ឬ ដោយត្រូវបង់កម្រិតមិនធ្វើសំណង។ក្រោយពីក្រុមហ៊ុនបានទូទាត់សំណងលើកទីមួយរួចហើយអត្ថប្រយោជន៍នេះនឹងត្រូវបញ្ចប់លើកលែងតែលោកអ្នកបន្តសុពលភាពវាឡើងវិញ និងបង់នូវបុព្វលាភធានារ៉ាប់រងបន្ថែម។
本公司将扩展第二部分项下的保障范围，涵盖您就车辆挡风玻璃或车窗玻璃因碎裂或破损而产生的修理或更换费用索赔（前提是车辆本身未发生其他损坏）。在保险期间内，您可就本项保障提出一次索赔，而不会影响无赔款折扣（NCD）或需支付免赔额。在本公司处理完首次索赔后，本项保障即终止，除非您选择重新投保并支付额外保费以恢复该保障。

ម៉ាស៊ីនត្រជាក់ ម៉ាញ៉េ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត
空调装置、汽车收音机、磁带播放机及CD播放机

ក្រុមហ៊ុននឹងបន្ថែមការធានាដែលផ្តល់ជូននៅក្នុងចំណុចទី ២ នៃបណ្ណសន្យារ៉ាប់រងនេះ។ ការប៉ាន់ស្មានតម្លៃទីផ្សាររបស់យានយន្តរបស់លោកអ្នករួមបញ្ចូលទាំងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំដូចដែលមានចែងក្នុងតារាងសង្ខេបបណ្ណសន្យារ៉ាប់រងនិងបូកបញ្ចូលនូវតម្លៃរបស់ម៉ាស៊ីនត្រជាក់, ម៉ាស៊ីនចាក់កាសែត ឬ ម៉ាស៊ីនចាក់ស៊ីឌី។ ចំពោះការបាត់បង់ ឬការខូចខាតទៅលើឧបករណ៍ទាំងអស់នេះ ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងជូននូវតម្លៃជួសជុល ឬតម្លៃផ្លាស់ប្តូរ។ លោកអ្នកអាចធ្វើការទាមទារសំណងមួយដងក្រោមអត្ថប្រយោជន៍នេះក្នុងអំឡុងពេលនៃការធានា ដោយមិន

បាត់បង់នូវសិទ្ធិទទួលបានការបញ្ចុះតម្លៃក្នុងករណីមិនធ្លាប់ទាមទារសំណង ឬដោយត្រូវបង់កម្រិតមិនធ្វើសំណង។ ក្រោយពីក្រុមហ៊ុនបានទូទាត់សំណងលើកទីមួយរួចហើយ អត្ថប្រយោជន៍នេះនឹងត្រូវបញ្ចប់ លើកលែងតែលោកអ្នកបន្តសុពលភាពវាឡើងវិញ និងបង់នូវបុព្វលាភធានារ៉ាប់រងបន្ថែម។
本公司将扩展本保单第二部分所提供的保障。您对车辆市场价值的估算（包括保单明细中列明的配件及零部件）将包括空调装置以及内置的收音机、磁带或CD播放机。对于上述设备的损失或损坏，本公司将赔偿实际修理费用或全额更换价值，以较低者为准。在任何一个保险期间内，您可就本项保障提出一次索赔，而不会影响无赔款折扣（NCD）或需支付免赔额。在本公司处理完首次索赔后，本项保障即终止，除非您选择重新投保并支付额外保费以恢复该保障。

សេវាស្ទូច និងដឹកជញ្ជូនដោយឥតគិតថ្លៃ
免费拖车和运输服务

ប្រសិនបើយានយន្តរបស់លោកអ្នកមិនអាចធ្វើដំណើរបានដោយសារមូលហេតុណាមួយដែលកើតឡើងក្នុងចំងាយ២០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ យើងនឹងទូទាត់នូវថ្លៃចំណាយសមស្របក្នុងការផ្លាស់ទីយានយន្តរបស់លោកអ្នក ទៅកាន់យានដ្ឋានដែលជាដៃគូសហការរបស់យើងដែលនៅជិតបំផុត។
如您的车辆因任何原因在金边市20公里范围内发生故障，本公司将承担将车辆拖移至距离最近的本公司指定维修厂/车身修理厂的合理费用。

សេវាកម្មអ្នកបើកបរជំនួសដោយឥតគិតថ្លៃ (១ ដង ក្នុងអំឡុងពេលសុពលភាពបណ្ណសន្យារ៉ាប់រង)
免费指定驾驶员服务（每一保险期间限一次）

ក្នុងរង្វង់ ១០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ក្នុងករណីដែលអ្នកធានារ៉ាប់រង ឬអ្នកបើកបររបស់អ្នក មិនមានលទ្ធភាពបើកបរយានយន្តដែលត្រូវបានធានាយើងនឹងផ្តល់ជូននូវសេវាកម្មអ្នកបើកបរជំនួស។យើងនឹងផ្តល់ជូនសេវាកម្មអ្នកបើកបរជំនួសដើម្បីបើកបរយានយន្តរបស់អ្នកទៅកាន់លំនៅដ្ឋានរបស់អ្នកត្រូវបានធានារ៉ាប់រង ឬ ទៅកាន់ទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ដោយមិនមានគិតកម្រៃសេវាឡើយ។
在金边市10公里范围内，如被保险人或授权驾驶员无法驾驶被保险车辆，本公司将提供指定驾驶员服务。指定驾驶员将免费将您的车辆驾驶至被保险人住所或指定的安全地点，无需支付任何服务费用。

ចំណុចទី៤៖ ជម្រើសធានារ៉ាប់រងបន្ថែម
第四部分：可选保障

ការរួមបញ្ចូលនៃហានិភ័យពិសេស
特别风险附加保障

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះ យើងយល់ព្រមផ្តល់ការធានាបន្ថែមនៃចំណុចទី២ នៃបណ្ណសន្យារ៉ាប់រងនេះក្រុមហ៊ុននឹងធ្វើសំណងចំពោះការបាត់បង់ឬខូចខាតយានយន្តរបស់អ្នកដែលបណ្តាលមកពីទឹកជំនន់,ខ្យល់ព្យុះ,ព្យុះភ្លៀង, បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។
鉴于您为本批单向本公司支付了额外保险费，本公司同意，本保单第二部分所提供的保险保障将扩展至因洪水、台风、飓风、风暴、暴风雨、火山喷发、地震、山崩、滑坡、地面沉降或地陷或其他自然灾害所导致的被保险车辆损失或损坏。

កូបកម្ម កុប្បកម្ម និង ការបះបោរ
罢工、暴乱及民众骚乱扩展保障

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះ យើងយល់ព្រមផ្តល់ការធានាបន្ថែមនៃចំណុចទី២ នៃបណ្ណសន្យារ៉ាប់រងនេះ ក្រុមហ៊ុននឹងធ្វើសំណងចំពោះការបាត់បង់ ឬខូចខាតដែលបណ្តាលមកពី៖
鉴于您为本批单向本公司支付了额外保险费，本公司同意，本保单第二部分所提供的保险保障将在本扩展保障项下，对因以下原因造成的损失或损坏予以赔付：

ក. កូដកម្ម កុប្បកម្ម និង ការបះបោរ ឬ
罢工、暴乱及民众骚乱；或

ខ. អំពើរបស់អាជ្ញាធរស្របច្បាប់ក្នុងការបង្ក្រាប ឬព្យាយាមបង្ក្រាបនូវការចលាចលទាំងនេះ។
任何合法当局为制止或试图制止该骚乱所采取的行动

ដោយយោងទៅលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែមសម្រាប់ខសន្យាធានារ៉ាប់រងបន្ថែមនេះក្រុមហ៊ុននឹងធ្វើសំណងជូនលោកអ្នកឬអ្នកដែលមានសិទ្ធិបើកបរ ឬ អ្នករួមដំណើរ ក្នុងករណី មរណភាព ឬ ការរងរបួសរូបរាងកាយ ឬ ពិការភាពអចិន្ត្រៃយ៍ ដូចដែលបានកំណត់នៅក្នុង តារាងនៃការទូទាត់សំណង ខាងក្រោមដែលបណ្តាលមកពីគ្រោះថ្នាក់ដោយសារយានយន្តរបស់លោកអ្នកដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖
鉴于您为本批单向本公司支付了额外保险费，本公司将就涉及您车辆的事故，向您、您的乘客或您的授权驾驶员支付下述赔偿标准所列明的死亡或身体伤害赔偿，但仅限于满足以下条件：

ក. មរណភាពឬការរងរបួសរូបរាងកាយឬពិការភាពអចិន្ត្រៃយ៍គឺបណ្តាលមកពីការគ្រោះថ្នាក់ខាងក្រៅដែលអាចមើលឃើញបានហើយដែលមិនទាក់ទងនឹងមូលហេតុផ្សេងទៀត (លើកលែងករណីដែលទាក់ទងនឹងការព្យាបាល និងការវះកាត់)។
死亡或身体伤害须由暴力、意外、外来且可见的原因直接造成，并且不受任何其他因素影响（但与之相关的医疗及外科治疗除外）；

ខ. មរណភាព ឬ ការរងរបួសរូបរាងកាយ ឬ ពិការភាពអចិន្ត្រៃយ៍ ដែលកើតឡើងក្នុងរយៈពេល៣០ថ្ងៃក្រោយពីគ្រោះថ្នាក់។
死亡或身体伤害须在事故发生后30日内发生；

គ. មរណភាព ឬការរងរបួសរូបរាងកាយ ឬពិការភាពអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពី អំពើបង្កុរបួសស្វាមដោយខ្លួនឯង, អំពើអត្តឃាតកម្ម ឬការប៉ុនប៉ងធ្វើអត្តឃាត, ការធ្វើឱ្យខូចខាតដល់រាងកាយ, ពិការភាព ទោះបីដោយផ្ទាល់ ឬមិនផ្ទាល់។
死亡或身体伤害不得直接或间接由故意自伤、自杀或企图自杀、身体缺陷或疾病所导致；

ឃ. គ្រោះថ្នាក់មិនត្រូវបានកើតឡើង នៅពេលដែលលោកអ្នកស្ថិតក្រោមឥទ្ធិពលនៃជាតិស្រវឹង ឬគ្រឿងញៀន។
事故不得发生在您受酒精或药物影响的情况下；

4 អត្ថប្រយោជន៍នៃការធានា
保单利益

ចំណុចទី១៖ ការទទួលខុសត្រូវចំពោះភាគីតតិយជន
第一部分：对第三方责任

ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើការធានារ៉ាប់រងជូនអ្នក លើគ្រោះថ្នាក់ដែលបណ្តាលមកពី ឬ កើតមាន ឡើងដោយការប្រើប្រាស់យានយន្តរបស់អ្នក ដែលរួមបញ្ចូលទាំងការទាមទារឱ្យបង់ និងចំណាយផ្សេងៗ ដែលអ្នកត្រូវសងស្របតាមច្បាប់សម្រាប់ ៖
本公司将为您提供保险保障，针对因使用您的机动车辆所引起或与之相关的事故，承保您依法须支付的全部金额，包括索赔人的费用及相关开支：

១. មរណភាព ឬ របួសលើរូបរាងកាយក្នុងកម្រិតអតិបរមាចំនួន ១០ ០០០ (ដប់ពាន់)ដុល្លារ អាម៉េរិកចំពោះបុគ្គលម្នាក់ក្នុងគ្រោះថ្នាក់មួយករណី។
每次事故中，每人死亡或身体伤害的最高赔偿限额为10,000美元（壹万美元）。

២. ការខូចខាតទ្រព្យសម្បត្តិ ក្នុងកម្រិតអតិបរមាចំនួន ១០ ០០០ (ដប់ពាន់)ដុល្លារអាម៉េរិក ចំពោះបុគ្គលម្នាក់ក្នុងគ្រោះថ្នាក់មួយករណី។
每次事故中，每人财产损失的最高赔偿限额为10,000美元（壹万美元）。

៣. ថ្លៃសេវាផ្នែកច្បាប់ យើងខ្ញុំនឹងបង់ថ្លៃសេវាផ្នែកច្បាប់ដោយកំណត់ក្នុងកម្រិតអតិបរមាចំនួន ២ ០០០(ពីរពាន់)ដុល្លារអាម៉េរិក ដើម្បីការពារពីការចោទប្រកាន់ណាមួយ ដោយរួមបញ្ចូលទាំងការចោទប្រកាន់ពីបទធ្វើឱ្យបាត់បង់ជីវិតដោយសារការបើកបរយានយន្ត (ប៉ុន្តែមិនរាប់បញ្ចូលពីបទមនុស្សឃាត)ប្រសិនបើទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីយើងខ្ញុំ។
法律费用：在事先取得本公司书面同意的前提下，本公司将支付最高不超过2,000美元（贰千美元）的法律费用，用于对任何指控的辩护，包括因驾驶机动车造成死亡的指控（不包括谋杀）。

គោលការណ៍នេះត្រូវបានកំណត់សម្រាប់ការទទួលខុសត្រូវសរុបរបស់ក្រុមហ៊ុនយើងខ្ញុំដែលមានកម្រិតអតិបរមាចំនួន១០០០០(មួយរយពាន់)ដុល្លារអាម៉េរិក ចំពោះគ្រោះថ្នាក់មួយ ឬ គ្រោះថ្នាក់បន្តបន្ទាប់គ្នាដែលកើតចេញពីហេតុការណ៍តែមួយ។
受限于每次事故或一系列事故的最高累计赔偿限额100,000美元（壹拾万美元）。

ចំណុចទី២៖ ការធានារ៉ាប់រងយានយន្តរបស់លោកអ្នក
第二部分：车辆保险

នេះជាជម្រើសរបស់អ្នកយើងខ្ញុំអាចធ្វើសំណងជាសាច់ប្រាក់សម្រាប់ការខូចខាតទាំងស្រុង ការខូចខាត ឬ អាចនឹងធ្វើការជួសជុលឱ្យដូចដើមវិញ ឬ ផ្លាស់ប្តូរយានយន្ត ឬ ផ្នែកណាមួយនៃយានយន្ត ឬ គ្រឿងបន្លាស់។
由您选择，我们可以提供全额现金赔偿，也可以维修或更换车辆、车辆的任何部件或配件。

ការទទួលខុសត្រូវរបស់យើងខ្ញុំមិនអាចលើសពីតម្លៃនៃផ្នែកណាមួយរបស់យានយន្តដែលបានបាត់បង់ឬខូចខាតជាមួយនឹងការសងត្រលប់ស្មើនឹងតម្លៃសមរម្យមួយដូចគ្នានឹងផ្នែកទាំងនោះ។ តម្លៃយានយន្តដែលបត្តុលត្រូវបានធានារ៉ាប់រង ធ្វើការប៉ាន់ស្មាន និងត្រូវបានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង គឺជាតម្លៃអតិបរមា សម្រាប់ការធ្វើសំណង របស់ក្រុមហ៊ុនយើងខ្ញុំ ក្នុងករណីបណ្តឹងទាមទារសំណងសម្រាប់ការខូចខាតទាំងស្រុង ឬ ការខូចខាតណាមួយ។
本公司的责任不超过所遗失或损坏零部件的价值以及安装该等零部件的合理费用。保险单所列明的被保险人估计价值应为本公司就任何一次推定全损或损坏索赔所支付的最高金额。

ក្នុងលក្ខខណ្ឌដែលតម្លៃនៃការជួសជុលមិនតិចជាង ៨០% នៃតម្លៃយានយន្តនៅក្នុងអំឡុង ពេលនៃការធានារ៉ាប់រង ក្រុមហ៊ុនយើងខ្ញុំនឹងចាត់ទុកករណីនោះ ជាករណី “យានយន្តខូចខាតទាំងស្រុង” ។ បុគ្គលត្រូវបានធានារ៉ាប់រងត្រូវធ្វើការផ្ទេរសិទ្ធិក្នុងភាពជាម្ចាស់នៃយានយន្ត ជូនមកក្រុមហ៊ុនយើងខ្ញុំជាបន្ទាន់ ហើយការធានារ៉ាប់រងចំពោះយានយន្តនេះត្រូវអស់សុពលភាព។
如机动车辆的修理费用在保险时车辆价值的80%或以上，本公司将该情况视为推定全损。被保险人应立即将该车辆的所有权转让予本公司，并视为该车辆的保险保障即告终止。

ចំណុចទី៣៖ ធានារ៉ាប់រងបន្ថែមដោយស្ម័យប្រវត្តិ
第三部分：自动扩展保障

សេវាផ្នែកច្បាប់
法律费用

គឺជាការចំណាយសមស្របលើសេវាផ្នែកច្បាប់ដែលបានកើតឡើងប្រសិនបើអ្នកបើកបរនៃយានយន្តដែលត្រូវបានធានារ៉ាប់រងត្រូវបានចោទប្រកាន់ពីបទបើកបរដោយខ្វះការប្រុងប្រយ័ត្នដែលបណ្តាលឱ្យមានមនុស្សស្លាប់។ ក្រុមហ៊ុននឹងមិនទូទាត់លើសពី ២,០០០ ដុល្លារអាមេរិកឡើយ សម្រាប់គ្រោះថ្នាក់នីមួយៗ។
如被保险车辆驾驶员因疏忽驾驶导致他人死亡而被指控所产生的合理法律费用。本公司对于任何一次事故的赔偿金额不超过2,000美元。

ការធានាលើកញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល
挡风玻璃、车窗及天窗保障

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុល ឬ តម្លៃផ្លាស់ប្តូរកញ្ចក់មុខក្រោយ កញ្ចក់បង្ហួច និងកញ្ចក់ដំបូល។
本公司将赔偿挡风玻璃、车窗及天窗的修理或更换费用。

ម៉ាស៊ីនត្រជាក់ ម៉ាញ៉េ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត
空调装置、汽车收音机、磁带播放机及CD播放机

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុល ឬ តម្លៃផ្លាស់ប្តូរម៉ាស៊ីនត្រជាក់ ម៉ាញ៉េ ម៉ាស៊ីនចាក់ការសែត និង ម៉ាស៊ីនចាក់ស៊ីឌីរបស់យានយន្ត ហេតុដល់តម្លៃជួសជុលជាក់ស្តែង ឬក៏តម្លៃនៃការផ្លាស់ប្តូរ។
本公司将赔偿空调装置及内置收音机、磁带或CD播放机的修理或更换费用，赔偿金额以实际修理费用或全额更换价值为限，以较低者为准。

សេវាសួច និងដឹកជញ្ជូនដោយឥតគិតថ្លៃ
免费拖车和运输服务

យើងនឹងទូទាត់នូវថ្លៃចំណាយសមស្របក្នុងការបម្លាស់ទីយានយន្តរបស់លោកអ្នកទៅកាន់យានដ្ឋានដែលជាដៃគូសហការរបស់យើងដែលនៅជិតបំផុត។
本公司将承担将您的车辆移至距离最近的本公司指定维修厂/车身修理厂的合理费用。

សេវាកម្មអ្នកបើកបរជំនួសដោយឥតគិតថ្លៃ (១ ដង ក្នុងអំឡុងពេលសុពលភាពបណ្ណសន្យារ៉ាប់រង)
免费指定驾驶员服务（每一保险期间限一次）

យើងនឹងផ្តល់ជូនសេវាកម្មអ្នកបើកបរជំនួស ដើម្បីបើកបរយានយន្តរបស់អ្នកទៅកាន់លំនៅដ្ឋានរបស់អ្នកត្រូវបានធានារ៉ាប់រង ឬទៅកាន់ទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ដោយមិនមានគិតកម្រៃសេវាឡើយ។
本公司将提供指定驾驶员服务，将您的车辆驾驶至被保险人住所或指定的安全地点，且不收取任何服务费用。

ចំណុចទី៤៖ ជម្រើសធានារ៉ាប់រងបន្ថែម
第四部分：可选保障

ការរួមបញ្ចូលនៃហានិភ័យពិសេស
特别风险附加保障

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុលឬតម្លៃផ្លាស់ប្តូរយានយន្តហើយកម្រិតអតិបរមាក្នុងការធ្វើសំណងផ្អែកលើតម្លៃយានយន្តដែលបានប្រកាសក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
本公司将赔偿车辆的修理或更换费用，并以保险单所列明的最高赔偿限额为限。

កូបកម្ម កុប្បកម្ម និងការបះបោរ
罢工、暴乱及民众骚乱扩展保障

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងលើកម្រៃសេវាជួសជុលឬតម្លៃផ្លាស់ប្តូរយានយន្តហើយកម្រិតអតិបរមាក្នុងការធ្វើសំណងផ្អែកលើតម្លៃយានយន្តដែលបានប្រកាសក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
本公司将赔偿车辆的修理或更换费用，并以保险单所列明的最高赔偿限额为限。

ផលប្រយោជន៍ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល
个人意外伤害保障

ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងក្នុងចំណោមចំណុចទី១រហូតដល់ចំណុចទី៧ដែលមានចែងក្នុងតារាងនៃការទូទាត់សំណងខាងក្រោមក្នុងរយៈពេលនៃការធានារ៉ាប់រង គឺមិនលើសពី ១០ ០០០ ដុល្លារអាម៉េរិកក្នុងម្នាក់នៅក្នុងគ្រោះថ្នាក់តែមួយ ឬ គ្រោះថ្នាក់តៗគ្នាក្តី ហើយចំនួន សរុបនៃទឹកប្រាក់ត្រូវផ្អែកតាមចំនួនកៅអីដែលបានបំពាក់តាមស្តង់ដារពីក្រុមហ៊ុនផលិតដើមដំបូងសម្រាប់អ្នកម្ចាស់រថយន្តដឹកអ្នកដំណើរ។ ទឹកប្រាក់អតិបរមាសម្រាប់អ្នកបើកបរគឺ ១០ ០០០ ដុល្លារអាម៉េរិក។
在保险期间内，根据下述赔偿标准第1）至第7）项所支付的总赔偿金额，每人每次事故或一系列事故的赔偿总额不超过10,000美元，并且总体赔偿限额以制造商原厂配置的座位数量为准（适用于乘客）。授权驾驶员的最高赔偿金额为10,000美元。

ល.រ / 编号	តារាងនៃការទូទាត់សំណង / 赔偿规模	ទឹកប្រាក់ទូទាត់សំណង / 赔偿金额（美元）
១	មរណភាព 死亡	១០០០០ ដុល្លារអាម៉េរិក 10,000 美元
២	ការបាត់បង់ទាំងស្រុងនៃការមើលឃើញរបស់ភ្នែកទាំងគូ 双眼视力完全且不可恢复的丧失	១០០០០ ដុល្លារអាម៉េរិក 10,000 美元
៣	ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃ ឬកជើងទាំងសងខាង ឬកដៃម្ខាង និងកជើងម្ខាង 双手或双足均在手腕或脚踝以上发生完全离断， 或一只手与一只脚在手腕或脚踝以上发生完全离断所导致的全部损失	១០០០០ ដុល្លារអាម៉េរិក 10,000 美元
៤	ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃនៃដៃម្ខាង ឬកជើងនៃជើងម្ខាង រួមគ្នាជាមួយនឹងការបាត់បង់ការមើលឃើញនៃភ្នែកម្ខាង 一只手或一只脚在手腕或脚踝以上发生完全离断， 并伴随一只眼睛视力完全且不可恢复的丧失所导致的全部损失	១០០០០ ដុល្លារអាម៉េរិក 10,000 美元

៥	ការបាត់បង់ទាំងស្រុងនៃការមើលឃើញរបស់ភ្នែកម្ខាង 一只眼睛视力完全且不可恢复的丧失	១០០០០ ដុល្លារអាមេរិក 10,000 美元
៦	ការបាត់បង់ទាំងស្រុងនៃអវយវៈកដៃនៃដៃម្ខាង ឬកជើងនៃជើង 一只手或一只脚在手腕或脚踝以上发生完全离断所导致的全部损失	១០០០០ ដុល្លារអាមេរិក 10,000 美元
៧	ចំណាយលើថ្លៃព្យាបាល 医疗费用	១០០០ ដុល្លារអាមេរិក 1,000 美元

5 ការបង់បុព្វលាភធានារ៉ាប់រង
保险费支付

របៀប និងមធ្យោបាយបង់បុព្វលាភ
保险费支付方式及模式

បុព្វលាភធានារ៉ាប់រងត្រូវបង់ជាលក្ខណៈប្រចាំឆ្នាំ (បង់សរុបសម្រាប់រយៈពេលមួយឆ្នាំ ឬ សម្រាប់រយៈពេលទាំងមូលនៃកិច្ចសន្យាធានារ៉ាប់រងនីមួយៗ) និងតាមរយៈមធ្យោបាយណាមួយដូចខាងក្រោម៖
保险费必须按年缴纳（一次性缴纳一年的保费或每份保险合同的整个期限），可通过以下任一方式缴纳：

ក. តាមរយៈមូលប្បទានប័ត្រទៅកាន់ «ANGKOR GENERAL INSURANCE PLC.»
以支票方式支付，支票抬头为 "ANGKOR GENERAL INSURANCE PLC."

ខ. ការផ្ទេរតាមធនាគារដែលមានព័ត៌មានដូចខាងក្រោម៖
银行转账：

ឈ្មោះគណនី៖ 账户名称：	ANGKOR GENERAL INSURANCE PLC.
លេខគណនី៖ 账户号码：	016-006-555
រូបិយបណ្ណ៖ 币种：	ដុល្លារអាមេរិក / 美元
ឈ្មោះធនាគារ៖ 银行名称：	ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ / 亚洲先进银行 (ABA Bank)

ការធានាអះអាងលើការបង់បុព្វលាភធានារ៉ាប់រង
保险费支付保证条款

ជាលក្ខខណ្ឌដាច់ខាតស្ថិតក្រោមបណ្ណសន្យារ៉ាប់រងនេះ តម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងក្នុងអំឡុងពេល៣០ថ្ងៃឬតាមចំនួនថ្ងៃកំណត់ក្នុងបណ្ណសន្យារ៉ាប់រងដោយរាប់ពីថ្ងៃដែលបណ្ណសន្យារ៉ាប់រង ការធ្វើបដិលេខបន្ថែម វិញ្ញាបនបត្របន្ត្រឡើងវិញចាប់ផ្តើមមានសុពលភាព។ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពតាមដូច្នេះបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបានលុបចោលដោយស្វ័យប្រវត្តិហើយក្រុមហ៊ុនមានសិទ្ធិទទួលបាននូវបុព្វលាភសមាមាត្រទៅតាមរយៈពេលដែលក្រុមហ៊ុនបានធ្វើការធានារ៉ាប់រងលើហានិភ័យ។នៅពេលដែលបុព្វលាភធានារ៉ាប់រងដែលបានបង់តាមលក្ខខណ្ឌមួយនេះត្រូវបានទទួលយកដោយអន្តរការីធានារ៉ាប់រងដែលត្រូវបានផ្តល់ជូនសិទ្ធិពីក្រុមហ៊ុនការបង់បុព្វលាភនេះត្រូវបាន ចាត់ទុកថាបានទទួលដោយក្រុមហ៊ុនតាមលក្ខខណ្ឌនេះ ហើយបន្ទុកក្នុងការបញ្ជាក់ថាបុព្វលាភ ដែលបានបង់នេះបានទទួលពីបុគ្គលម្នាក់រួមបញ្ចូលអន្តរការីធានារ៉ាប់រងដែលមិនត្រូវបានផ្តល់ជូនសិទ្ធិក្នុងការទទួលយកនូវបុព្វលាភនេះគឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន។យោងទៅតាមលក្ខខណ្ឌ និងខែឯនានាក្រោមបណ្ណសន្យារ៉ាប់រងនេះ។

根据保单条款，被保险人必须自续保证明之日起30天内或按照保单规定的天数缴纳保险费。
如果不满足此条件，则保单将自动取消，公司有权根据公司承保风险的时间长度按比例获得保费。从未经授权接受此保费的个人（包括保险中介）收到的付款由公司负责。根据本政策的条款和条件。

6 ករណីមិនធានា
除外责任

ករណីមិនធានាក្នុងចំណុចទី១
适用于第一部分的除外责任

យើងនឹងមិនទទួលខុសត្រូវចំពោះករណីដូចខាងក្រោម៖
本公司不承担任何以下责任：

ក. មរណភាព ឬរបួសរាងកាយ ទៅដល់អ្នករួមដំណើរ ដែលត្រូវបានដឹកក្នុងគោលបំណងទទួលបានប្រាក់កម្រៃ។
对任何以收费或报酬方式搭载的乘客所发生的死亡或身体伤害；

ខ. មរណភាព ឬរបួសរាងកាយ ទៅដល់បុគ្គលណាម្នាក់ ដែលមរណភាព ឬរបួសកើតឡើងក្នុងកំឡុងពេលនិងក្នុងពេលបំពេញការងារអោយអ្នក ឬអោយអ្នកបើកបររបស់អ្នក។
对任何人员的死亡或身体伤害，若该死亡或伤害是在其受雇于您或您的授权驾驶员期间及因该雇佣关系而发生；

ចំណាំ៖ ក្នុងពេលបំពេញការងារ ៖ សំដៅដល់បុគ្គលណាដែលរងរបួស ឬមរណភាព (ទោះជាអ្នករួមដំណើរ ឬក្នុងស្ថានភាពផ្សេងទៀត) ខណៈពេលកំពុងបំពេញការងារ ហើយស្ថិតក្នុងយានយន្ត ដែលជាផ្នែកនៃតួនាទីការងាររបស់គេ។
注： 在雇佣过程中，任何人员在工作期间受伤/死亡（无论作为乘客或其他身份），且作为其工作的一部分而在该车辆内或车上的情况。

គ. ការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិណាមួយដែលជាកម្មសិទ្ធិរបស់របស់លោកអ្នកស្ថិតក្រោមការគ្រប់គ្រងនិងមើលការខុសត្រូវដោយអ្នក ឬ អ្នកបើកបរដែលមានការអនុញ្ញាតិពីអ្នក ឬសមាជិកណាមួយនៃសមាជិកគ្រួសាររបស់អ្នក។
对属于您、您的授权驾驶员或您家庭成员所有，或由其保管、控制或代为保管的任何财产所造成的损失或损坏。

ឃ. ភារៈទទួលខុសត្រូវណាមួយដែលបង្កឡើងដោយ អ្នករួមដំណើរនៅក្នុងយានយន្ត ឬ កំពុងបើកបរយានយន្តរបស់អ្នក។
因您车辆内的乘客或驾驶员而产生的任何责任。

ង. រាល់ការទាមទារសំណងណាមួយប្រឆាំងនឹងអ្នក ដោយអ្នកបើកបរយានយន្តរបស់អ្នក ទោះបីជាអ្នកបើកបរនោះបានអនុញ្ញាត ឬមិនបានអនុញ្ញាតក៏ដោយ។
由任何驾驶您车辆的人员（无论是否获授权）向您提出的任何索赔；

ច. រាល់ការទាមទារសំណងណាមួយប្រឆាំងនឹងបុគ្គលណាម្នាក់ នៅក្នុងប្រទេសណាមួយ តាមរយៈតុលាការក្រៅប្រទេសកម្ពុជា។
在柬埔寨境外任何国家法院对任何人提出的任何索赔；

ឆ. រាល់ការចំណាយផ្នែកច្បាប់ទាំងឡាយណាដែលមិនបានកើតឡើងនៅក្នុងប្រទេសសកម្ពុជាឬមិនអាចទាមទារបាននៅក្នុងប្រទេសកម្ពុជា។
在柬埔寨境外产生或无法在柬埔寨追偿的所有法律费用及开支。

ករណីមិនធានាក្នុងចំណុចទី២
适用于第二部分的除外责任

យើងនឹងមិនទទួលខុសត្រូវចំពោះករណីដូចខាងក្រោម៖
本公司不承担任何以下责任：

ក. ការជួសជុលទាំងឡាយណាដែលត្រូវបានធ្វើឡើងក្រៅពីយានដ្ឋានដៃគូរបស់ក្រុមហ៊ុន ឬដោយមិនបានយល់ព្រមជាមុនពីខាងក្រុមហ៊ុន
在公司合作维修厂以外进行的任何维修，或未经公司事先批准的任何维修。

ខ. ការចុះតម្លៃ ការសឹករេចរឹល ការខូចខាតប្រព័ន្ធមេការនិច (ម៉ាស៊ីន) ការខូចខាតប្រព័ន្ធភ្លើង។
折旧、磨损、机械系统（发动机）损坏、电气系统损坏。

គ. ការខូចមេការនិច ឬអគ្គិសនី ការមិនដំណើរការ ឬការខូចខាតប្រព័ន្ធដែលបណ្តាលមកពីមេរោគ។
因机械或电气故障、失效或损坏（包括由恶意软件引起的情况）

ឃ. ការខូចមេការនិច ឬអគ្គិសនី ការមិនដំណើរការ ឬការខូចខាតប្រព័ន្ធដែលមិនបណ្តាលមកពីគ្រោះថ្នាក់។
非事故造成的机械或电气故障、失灵或系统损坏。

ង. ការខូចខាតទៅលើកង់យានយន្ត លើកលែងតែយានយន្តរបស់លោកអ្នកទទួលរងការខូចខាតនៅពេលជាមួយគ្នា។
轮胎或轮毂的损坏，但若在同一次事故中车辆其他部位亦受损则不在此限。

ច. ការមិនបានប្រើប្រាស់ ឬផលវិបាកផ្សេងៗដែលបណ្តាលមកពីគ្រោះថ្នាក់។
车辆使用损失或任何其他间接或后果性损失。

ឆ. ការបាត់បង់ឬខូចខាតទៅលើគ្រឿងបន្លាស់ឬគ្រឿងបន្ថាប់បន្សំដែលមិនស្ថិតនៅក្នុងឬបំពាក់ក្នុងយានយន្តក្នុងអំឡុងពេលមានគ្រោះថ្នាក់។
在事故发生时，车辆未安装或未放置于车内的配件发生的损失或损坏。

ជ. ការបាត់បង់ ឬខូចខាតទៅលើគ្រឿងបន្លាស់ ឬគ្រឿងបន្ថាប់បន្សំដោយសារអំពើចោរកម្ម ឬការគាស់ផ្ទះដោយមានការជួយ ឬផ្សំគំនិតពីសមាជិកណាមួយរបស់លោកអ្នកឬអ្នកដែលមានសិទ្ធិបើកបរ បុគ្គលិករបស់លោកអ្នក ឬសមាជិកគ្រួសាររបស់ម្ចាស់ផ្ទះ ឬអ្នកបំពីនៅផ្ទះ។
因入室盗窃、破门盗窃或偷窃而导致的车辆损失或损坏，且该损失直接或间接由您、您的授权驾驶员、业务员工、车主家庭成员或其雇员的任何成员串通或参与所造成。

ឈ. រាល់ការបាត់បង់តម្លៃនៃយានយន្តរបស់អ្នក ក្នុងពេលកំពុងរក្សាទុក ស្ថិតក្រោមការត្រួតពិនិត្យរបស់ប៉ូលីសចរាចរណ៍ មុនពេលជួសជុលខណៈពេលដែលការជួសជុលត្រូវបានអនុវត្ត ឬប្រសិនបើយានយន្តត្រូវបានចាត់ទុកថាជាការខូចខាតទាំងស្រុងមិនអាចជួសជុលបាន ឬបាត់បង់ទាំងស្រុង។
在车辆存放期间、由交通警察扣押期间、维修前、维修期间，或在车辆被认定为推定全损或全损的情况下，车辆的任何价值损失。

ញ. ការប្រព្រឹត្តមិនត្រឹមត្រូវដោយចេតនារបស់លោកអ្នក ឬ អ្នកដែលមានសិទ្ធិបើកបរ ឬបុគ្គលិករបស់លោកអ្នក ឬ អ្នកបំពីនៅផ្ទះ។
车主、授权驾驶员、任何雇员或车主家庭成员或其雇员的故意不当行为。

ដ. ការខូចខាត ឬបាត់បង់ ឬការលួចរបស់របរ ឬរបស់ផ្ទាល់ខ្លួនណាមួយនៅក្នុងយានយន្តរបស់អ្នក ដែលមិនមែនជាគ្រឿងបន្លាស់ មិនថានៅពេលមានគ្រោះថ្នាក់ ឬមិនមានក៏ដោយ។
对您车内任何物品或个人财物的损坏、损失或盗窃（无论是否在事故发生时发生），且该等物品不属于车辆配件的情形。

ឋ. ក្រុមហ៊ុននឹងមិនធ្វើសំណងចំពោះ កម្រិតមិនធ្វើសំណង ប្រសិនបើត្រូវបានអនុវត្ត និងមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
如果保险单（或保险凭证）中适用并载明了免赔额，公司将不对该免赔额部分承担赔偿责任。

ករណីមិនធានាអនុវត្តគ្រប់ចំណុចធានាទាំងអស់
适用于所有部分的除外责任

ដែនកំណត់ភូមិសាស្ត្រ និងដែនកំណត់ក្នុងការប្រើប្រាស់
地理范围及使用限制

ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះករណីគ្រោះថ្នាក់ការបាត់បង់,ការខូចខាត,ការរងរបួសឬការទទួលខុសត្រូវដែលបណ្តាលមកពីឬកើតឡើងដោយ៖
本公司对以下任何事故、损失、损坏、伤害或责任概不承担责任：

ក. ការប្រណាំងការប្រណាំងដើម្បីដាក់ទីឱ្យគេការសាកល្បងពីភាពអាចជឿទុកចិត្តបានរបស់យានយន្តការសាកល្បងល្បឿនរបស់យានយន្ត
比赛，排位赛，测试车辆的可靠性，测试车辆的速度

ខ. ក្រៅពីវិសាលភាពដែនដីនៃប្រទេសកម្ពុជា
在柬埔寨地理范围之外使用。

គ. នៅពេលដែលយានយន្តរបស់លោកអ្នកត្រូវបាន៖
当您的车辆处于以下情况时：

i. បើកបរដោយបុគ្គលដែលមិនត្រូវបានអនុញ្ញាតឱ្យ បើកបរ
由任何非授权驾驶员驾驶；

ii. បើកបរដោយបុគ្គលដែលស្ថិតក្រោមក្នុងឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន។ ការកំណត់ពីបទល្មើសរបស់បុគ្គលនេះនឹងត្រូវផ្អែកទៅតាមមាត្រា៧៧នៃច្បាប់ចរាចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧។ ការកំណត់របស់ច្បាប់នេះគឺជាមូលដ្ឋានក្នុងការអនុវត្តការលើកលែងមិនធ្វើសំណងនៅពេលដែលបុគ្គលនោះបានប្រព្រឹត្តបទល្មើសនៅពេលគ្រោះថ្នាក់ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលបង្កឱ្យមានការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

由任何受酒精或毒品影响的人员驾驶。本条款所述人员如因违反2017年1月26日修订之柬埔寨交通法第77条而被定罪，则在该违法行为发生于事故或引发本保单索赔的其他事件发生时，该定罪将作为适用本除外责任的确凿证据。

ii. ត្រូវបានប្រើឬបើកបរយានយន្តកែច្នៃដោយមិនមានការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា ដោយយោងទៅតាមច្បាប់ចរាចរណ៍នៃ ព្រះរាជាណាចក្រកម្ពុជា ឬពេលដែលការចុះបញ្ជីរបស់យានយន្តក្រោមច្បាប់ចរាចរណ៍ នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានលុបចោល។

在未经柬埔寨公共工程与运输部根据柬埔寨交通法批准改装的情况下使用或驾驶，或其根据柬埔寨交通法的登记已被取消时使用或驾驶。

*ការយោងទៅតាមបទប្បញ្ញត្តិនៃច្បាប់មួយនឹងត្រូវរាប់បញ្ចូលទាំងការធ្វើវិសោធនកម្មនច្បាប់នេះ ឬច្បាប់ជំនួសរបស់វា។
对任何法律的引用，应视为包括其任何修订内容或任何替代法律中的相应条款。

ឃ. អ្នកបើកបរដែលមិនមានអាជ្ញាប័ណ្ណ មិនត្រូវបានធានានៅក្រោមធានារ៉ាប់រងនេះទេ ប្រសិនបើអ្នក ឬអ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកមិនមានប័ណ្ណបើកបរដែលមានសុពលភាព (រួមទាំងថ្នាក់ដែលពាក់ព័ន្ធ) ដើម្បីឱ្យអ្នកបើកបរយានយន្តរបស់អ្នកស្ថិតនៅក្រោម ច្បាប់អាជ្ញាប័ណ្ណ ឬបទប្បញ្ញត្តិដែលមានស្រាប់ណាមួយ។ នេះក៏នឹងអនុវត្តផងដែរចំពោះអ្នក ឬអ្នកបើកបរដែលមានការអនុញ្ញាតពីអ្នកស្ថិតនៅក្រោមការណែនាំ ឬ ដកសិទ្ធិក្នុងការបើកបរ។

无驾照驾驶员：如您或您的授权驾驶员未持有根据现行法律、许可或法规有效驾驶本车辆所需的有效驾驶执照（包括相应类别），本保单不提供任何保障。若您或您的授权驾驶员的驾驶资格被暂停或吊销，本条款同样适用。

ការក្លែងបន្លំ ឬការទាមទារសំណងហួសពីការពិត
欺诈及夸大索赔

ប្រសិនបើការទាមទារសំណងណាមួយមានលក្ខណៈបន្លំឬត្រូវបានធ្វើឱ្យលើសពីការពិតឬប្រសិនបើអ្នកឬបុគ្គលណាម្នាក់ដែលធ្វើសកម្មភាពក្នុងនាមអ្នកប្រើប្រាស់មធ្យោបាយក្លែងបន្លំដើម្បីទទួលបានអត្ថប្រយោជន៍ណាមួយក្រោមបណ្ណសន្យានេះនោះរាល់ការទាមទារសំណងទាំងមូលនឹងមិនត្រូវបានទូទាត់ឡើយ។ ប្រសិនបើយើង ត្រូវបានតម្រូវអោយទូទាត់សំណងទៅកាន់ភាគីតតិយជន យើងមានសិទ្ធិក្នុងការទាមទារសំណងមកវិញ នូវចំនួនទឹកប្រាក់ដែលបានបង់ និងរួមទាំងការចំណាយនានាដែលបានកើតឡើងពីអ្នក។

如任何索赔在任何部分存在欺诈或夸大，或您或任何代表您行事的人以欺诈手段获取本保单项下任何利益，则该全部索赔将不予支付或不构成应付责任。如本公司因该等索赔而被要求向第三方支付任何款项，本公司有权向您追偿已支付的款项及所产生的任何费用。

គោលបំណងខុសច្បាប់
非法目的

មិនមានការធានា នៅក្រោមបណ្ណសន្យានេះទេ ប្រសិនបើអ្នក ឬអ្នកបើកបរដែលទទួលបានការអនុញ្ញាតពីអ្នក ប្រើប្រាស់យានយន្តរបស់អ្នកក្នុងគោលបំណងខុសច្បាប់ ឬការរួមគំនិតគ្នា ឬការប្រើប្រាស់ ការកាន់កាប់ ឬការដឹកជញ្ជូនសារធាតុវិទ្យុសកម្ម។

如果您或您的授权驾驶员将车辆用于非法或融合用途，或用于放射性物质的使用、处理或运输，则本保单不提供任何保障。

គ្រោះធម្មជាតិ
自然灾害

មិនមានការធានា (លើកលែងតែត្រូវបានទិញបន្ថែម) ចំពោះរាល់ការខាតបង់ ការខូចខាត ឬការទទួលខុសត្រូវដែលបង្កឡើងដោយសារ ទឹកជំនន់ , ខ្យល់ព្យុះ, ព្យុះភ្លៀង, បន្ទុះភ្នំភ្លើង, រញ្ជួយដី, ការបាក់ដី, ការស្រុតដី, ការធ្លាក់ចុះ ឬលិចដី ឬគ្រោះធម្មជាតិផ្សេងៗទៀត។

除非另有特别投保，否则对于因洪水、台风、飓风、风暴、暴风雨、火山喷发、地震、山体滑坡、地层滑动、地面沉降或下陷或其他自然灾害所造成的任何损失、损坏或责任，本公司不提供保障。

ការទទួលខុសត្រូវតាមកិច្ចសន្យា
合同责任

យើងនឹងមិនផ្តល់សំណងចំពោះរាល់ការៈទទួលខុសត្រូវណាមួយដែលកើតឡើងដោយសារឥទ្ធិពលនៃកិច្ចព្រមព្រៀងប៉ុន្តែជាករណីដែលយើងនឹងមិនជាប់កាតព្វកិច្ចទទួលខុសត្រូវឡើយ ប្រសិនបើគ្មានកិច្ចព្រមព្រៀងបែបនោះ។

对于因协议而产生的任何责任，若在不存在该协议的情况下本公司本不承担该责任，则本公司不予赔偿。

ប្រាក់ពិន័យការផាក
罚款及处罚

យើងនឹងមិនផ្តល់សំណងចំពោះ ប្រាក់ពិន័យការផាក ឬការសងជំងឺចិត្តដែលត្រូវបានបង្គាប់ឱ្យអនុវត្តលើអ្នក ឬលើអ្នកបើកបរដែលទទួលបានការអនុញ្ញាតពីអ្នកឡើយ។

本公司不承担对您或您的授权驾驶员所施加的任何罚款、处罚或加重性、惩罚性或惩戒性赔偿金。

ករណីមិនធានាលើសង្គ្រាមនិងសង្គ្រាមស៊ីវិល (LIRMA G51)
战争及内战除外责任（LIRMA G51）

កិច្ចសន្យាធានារ៉ាប់រងនេះមិនធានាលើទំនួលខុសត្រូវដែលត្រូវទទួលដោយអ្នកត្រូវបាន ធានារ៉ាប់រងសម្រាប់ការបាត់បង់ ឬខូចខាតដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដែលកើត ឡើងដោយ ឬតាមរយៈ ឬជាផលវិបាកនៃសង្គ្រាម ការលុកលុយ ការឈ្លានពានពីសត្រូវ បរទេស ការវាយប្រយុទ្ធ ឬរាល់សកម្មភាពដែលស្រដៀងនឹងសង្គ្រាម(ទោះបីជាសង្គ្រាមនោះត្រូវបានប្រកាសក្តីឬមិនបានប្រកាសក្តី)។សង្គ្រាមស៊ីវិល,សង្គបកម្ម,ការចលាចលស៊ីវិលដែលមានការរើបម្រះ,ការបះបោរយោធា,ចលនាបះបោរបដិវត្តន៍,អំណាចយោធាឬការដណ្តើមអំណាចច្បាប់អាជ្ញាសឹក,ការព័ទ្ធចាប់ចលនាជាតិនិយម, ការឡោមព័ទ្ធ, ការបំផ្លាញទ្រព្យសម្បត្តិដោយសារ ឬក្រោមការបញ្ជារបស់រដ្ឋាភិបាល ឬសាធារណៈ ឬអាជ្ញាធរមូលដ្ឋាន។

本保单不承保被保险人所承担的任何责任，该等损失或损坏无论直接或间接因战争、入侵、外敌行为、敌对行动或战争行为（无论是否宣战）、内战、叛乱、规模达到或相当于民众起义的骚乱、军事起义、暴动、反叛、革命、军事或篡权政权、戒严、任何政府或公共或地方当局的没收、国有化、征用，或依其命令对财产进行的毁坏或损坏而引起、发生或作为其后果（以上定义以原保单为准）。

ការវាយប្រហារតាមអិនធឺណែត (CL380)
网络攻击除外条款（CL380）

ក. **យោងតាមចំណុច "ខ" ខាងក្រោម គ្មានករណីណាមួយដែលការធានារ៉ាប់រងនេះត្រូវផ្តល់សំណងលើការបាត់បង់ ការខូចខាត ទំនួលខុសត្រូវ ឬការចំណាយដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តីដោយសារ ឬចូលរួមដោយ ឬកើតឡើងពី ការប្រើឬប្រតិបត្តិការ ដែលជាមធ្យោបាយធ្វើឱ្យមានផលប៉ះពាល់ចេញពីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ, កម្មវិធីសូហ្វវ៉ារកុំព្យូទ័រ, កូដដែលធ្វើឱ្យខូចប្រព័ន្ធ មេរោគកុំព្យូទ័រ ឬដំណើរការឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀត។**

除以下第b款另有规定外，在任何情况下，本保险均不承保因使用或操作任何计算机、计算机系统、计算机软件程序、恶意代码、计算机病毒或程序或任何其他电子系统作为造成伤害的手段，而直接或间接导致、促成或引起的任何损失、损坏、责任或费用。

ខ. **នៅពេលដែលចំណុចនេះត្រូវបានកែប្រែលើកិច្ចសន្យាធានារ៉ាប់រងដើម្បីធានាលើហានិភ័យសង្គ្រាម, សង្គ្រាមស៊ីវិល, បដិវត្តន៍, ចលនាបះបោរ, ការរើបម្រះ, ជម្លោះស៊ីវិល, អំពើអរិភាពដោយប្រើអំណាច ឬ ភេរវកម្ម ឬសកម្មភាពរបស់បុគ្គលណាមួយដើម្បីនយោបាយ ដោយសកម្មភាពទាំងនោះកើតចេញពីការប្រើកុំព្យូទ័រ,ប្រព័ន្ធកុំព្យូទ័រ,កម្មវិធីសូហ្វវ៉ារកុំព្យូទ័រ ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងទៀតនៅក្នុងប្រព័ន្ធបើកដំណើរការ និង/ឬ ប្រព័ន្ធ ណែនាំ និង/ឬយន្តការនៃការបាញ់អាវុធ ឬមីស៊ីល។**

如本条款批注于承保战争、内战、革命、叛乱、暴动或由此引起的内乱风险，或任何交战方的敌对行为，或恐怖主义，或任何出于政治动机的人员行为之保单上，则第1.1条不得适用于排除因使用任何计算机、计算机系统、计算机软件程序或任何其他电子系统于任何武器或导弹的发射及/或制导系统及/或击发装置所造成的（原本应属承保范围内的）损失。

ករណីមិនធានាលើភេរវកម្ម (NMA 2921)
恐怖主义除外条款（NMA 2921）

ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិវេលខណាមួយក៏ដោយ ក៏ការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាម លក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នាឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ។ ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះឬបដិវេលខណាមួយក៏ដោយក៏ការធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាម លក្ខណៈណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើភេរវកម្ម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេង ទៀតដែលចូលរួមក្នុងពេលដំណាលគ្នាឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ។

尽管本保险或其任何批单中另有相反规定，双方同意：本保险不承保任何因恐怖主义行为直接或间接引起、导致或与之相关的任何性质的损失、损坏、费用或开支，无论是否存在任何其他原因或事件同时或以任何其他顺序共同促成该损失的发生。

ក្នុងគោលបំណងនៃបដិលេខនេះ អំពើភេរវកម្មសំដៅដល់ការប្រើកម្លាំង ឬហិង្សា និង/ឬ ការគំរាមកំហែងពីបុគ្គលណាម្នាក់ ឬក្រុមណាមួយ មិនថាធ្វើតែឯង ឬក្នុងនាមជាតំណាង ឬពាក់ព័ន្ធនឹងស្ថាប័ន ឬរដ្ឋាភិបាលក្តី ដែលធ្វើឡើងក្នុងគោលបំណង នយោបាយ, សាសនា , មនោគម ឬគោលបំណងដែលស្រដៀងនេះ រួមទាំងចេតនាដើម្បីមានឥទ្ធិពលលើរដ្ឋាភិបាលនិង/ឬធ្វើឱ្យសាធារណជនឬផ្នែកណាមួយនៃសាធារណៈ ឱ្យមានការភ័យខ្លាច។

就本批单而言，“恐怖主义行为”是指任何个人或团体（无论是单独行动，还是代表或与任何组织或政府有关联）所实施的行为，包括但不限于使用武力或暴力及/或威胁使用武力或暴力，且出于政治、宗教、意识形态或类似目的，包括意图影响任何政府及/或使公众或部分公众产生恐惧的行为。

បដិលេខនេះក៏មិនធានាលើការបាត់បង់ ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬ ពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រង ការពារ បង្ក្រាប ឬវិធីណាមួយទាក់ទងនឹង អំពើភេរវកម្ម Edison។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងត្រូវបានចោទប្រកាន់ដោយហេតុផល បដិលេខនេះ ការបាត់បង់ ការខូចខាត ថ្លៃចំណាយមិនត្រូវបានធានាដោយបណ្ណសន្យា រ៉ាប់រងនេះទេ នោះបន្ទុកនៃការអះអាងផ្ទុយពីនេះត្រូវធ្លាក់លើអ្នកត្រូវបានធានារ៉ាប់រង។ក្នុងករណីដែលផ្នែកណាមួយនៃបដិលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន នោះផ្នែកដែលនៅសល់នៅតែមានសុពលភាព និងមានប្រសិទ្ធភាព។

本批单亦不承保任何因采取控制、预防、制止或以任何方式与恐怖主义行为相关的措施而直接或间接导致、引起或产生的任何性质的损失、损坏、费用或开支。如保险人依据本除外条款主张任何损失、损坏、费用或开支不属于本保险责任范围，则证明该损失仍属承保范围的举证责任应由被保险人承担。如本批单的任何部分被认定为无效或不可执行，其余部分仍应完全有效并具有法律效力。

ករណីមិនធានាលើនយោបាយ
政治风险除外条款

ទោះបីជាមានប្រការណាមួយផ្ទុយនឹងការធានារ៉ាប់រងនេះ ឬបដិលេខណាមួយក៏ដោយ ការ ធានារ៉ាប់រងនេះមិនផ្តល់សំណងទៅលើការបាត់បង់ ការខូចខាត ថ្លៃចំណាយតាមលក្ខណៈ ណាក៏ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬ ពាក់ព័ន្ធនឹងអំពើឬសកម្មភាពដូចខាងក្រោម ដោយមិនគិតពីបុព្វហេតុឬព្រឹត្តិការណ៍ផ្សេងទៀតដែលចូលរួមក្នុងពេលដំណាលគ្នា ឬលំដាប់ផ្សេងគ្នាចំពោះការបាត់បង់ឡើយ៖

尽管本保险或其任何批单中另有相反规定，双方同意：本保险不承保任何因以下情形直接或间接导致、引起或与之相关的任何性质的损失、损坏、费用或开支，无论是否存在任何其他原因或事件同时或以任何其他顺序共同促成该损失的发生：

“ការរឹបអូស ការដកហូត ជាតិនិយម ការបញ្ជាពីមេបញ្ជាការ ការឡោមព័ទ្ធ ការបំផ្លាញ ឬ ការខូចខាតដល់ទ្រព្យសម្បត្តិដោយសារការបញ្ជារបស់រដ្ឋាភិបាល ឬសិទ្ធិអំណាច ឬសាធារណៈ អាជ្ញាធរក្រុង ឬមូលដ្ឋានដែលទ្រព្យសម្បត្តិនោះស្ថិតនៅក្នុងតំបន់នោះ ការចាប់ឬការ បំផ្លាញក្រោមបទបញ្ជាគយ ឬការដាក់ឱ្យនៅដាច់ដោយឡែកពីគេ”។

“因该财产所在国家或地区的政府（无论为事实政府或法律政府）或任何公共、市政或地方当局的命令而对财产进行的没收、征用、国有化、强行接管、征调或毁坏或损坏；或因检疫或海关规定下的扣押或毁坏。”

បដិលេខនេះក៏មិនធានាលើការបាត់បង់ ការខូចខាតថ្លៃចំណាយតាមលក្ខណៈណាក៏ ដោយ មិនថាដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតឡើងដោយសារ កើតចេញពី ឬពាក់ព័ន្ធនឹងអំពើធ្វើឡើងក្នុងការគ្រប់គ្រង ការពារ បង្ក្រាប ឬវិធីណាមួយទាក់ទងនឹងអំពើខាងលើ។

本批单亦不承保任何因采取控制、预防、制止或以任何方式与上述事项相关的措施而直接或间接导致、引起或产生的任何性质的损失、损坏、费用或开支。

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងត្រូវបានចោទប្រកាន់ដោយហេតុផលនៃបដិលេខនេះការបាត់បង់ការខូចខាតថ្លៃចំណាយមិនត្រូវបានធានាដោយបណ្ណសន្យារ៉ាប់រងនេះទេនោះបន្ទុកនៃការអះអាងផ្ទុយពីនេះត្រូវធ្លាក់លើអ្នកត្រូវបានធានារ៉ាប់រង។
ក្នុងករណីដែលផ្នែកណាមួយនៃបដិលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាពឬមិនអាចអនុវត្តបាននោះផ្នែកដែលនៅសល់នៅតែមានសុពលភាព និងមានប្រសិទ្ធភាព។

如果根据本条款，有人声称保险人遭受了本保单未承保的损失、损害或费用，则由被保险人承担相反的举证责任。
如果本条款的任何部分被认定为无效或不可执行，其余部分仍应完全有效。

ការបញ្ជាក់អំពីគ្រោះថ្នាក់នៃព័ត៌មានវិទ្យា (NMA2912)
信息技术风险说明条款（NMA2912）

ការបាត់បង់ដោយផ្ទាល់ក្តី ឬប្រយោលក្តី ដែលកើតចេញពី៖

- ការបាត់បង់ ឬការខូចខាត ឬ ការលុបទិន្នន័យនៃប្រព័ន្ធកុំព្យូទ័រ។

因以下情况直接或间接引起的损失：

- **计算机系统的丢失、变更、损坏，或其功能、可用性或运行能力的降低或中断**

- ការកាត់បន្ថយមុខងារ ភាពអាចរកបាន ឬប្រតិបត្តិការនៃប្រព័ន្ធកុំព្យូទ័រ ផ្នែករឹង កម្មវិធី សូហ្វវែរ ទិន្នន័យ ឃ្លាំងព័ត៌មានមិត្រឈឺប សៀគ្វីរួមបញ្ចូលគ្នា ឬឧបករណ៍ស្រដៀងគ្នា ក្នុងឧបករណ៍ កុំព្យូទ័រ ឬឧបករណ៍មិនមែនកុំព្យូទ័រ ទោះបីជាទ្រព្យសម្បត្តិរបស់អ្នកកាន់ បណ្ណសន្យារ៉ាប់រងក្តី មិននៅក្នុង និងខ្លួនឯងបង្កើតជាហេតុការណ៍មួយ លុះ ត្រាតែកើតចេញពីហានិភ័យមួយ ឬច្រើនដូចតទៅ៖ អគ្គិភ័យ, រន្ទះ, ការផ្ទុះ,ការធ្លាក់យន្តហោះឬការប៉ះទង្គិចដោយយានយន្តការធ្លាក់របស់លើ ខ្យល់ព្យុះ, ភ្លៀងទឹកកក, ព្យុះកំបុតត្បូង, ព្យុះស៊ីក្លូន, ព្យុះហ៊ើរីយេន រញ្ជួយផែនដី, ផ្ទុះភ្នំភ្លើង, សូណាមិ, ទឹកជំនន់, ទឹកកក ឬធ្លាក់ព្រិល។

- **计算机设备或非计算机设备中的硬件、程序、软件、数据、信息存储库、微芯片、集成电路或类似装置（无论是否为投保人或保险人所有），其本身不构成保险事故，除非该等情况源于以下一种或多种风险：火灾、雷击、爆炸、飞机或车辆冲击、坠落物、风暴、冰雹、龙卷风、气旋、飓风、地震、火山爆发、海啸、洪水、冰冻或积雪重量。**

ការមិនរាប់បញ្ចូលហានិភ័យថាមពលនុយក្លេអ៊ែរ
核能风险除外条款

រាល់ការខាតបង់ ការខូចខាត ឬការទទួលខុសត្រូវក្នុងរូបភាពណាក៏ដោយ ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ឬមានចំណែកបង្កដោយ ឬកើតចេញពីៈ អាវុធ និងសម្ភារៈនុយក្លេអ៊ែរ, កាំរស្មីអ៊ីយ៉ូដ ឬការបំពុលដោយវិទ្យុសកម្មពីឥន្ធនៈនុយក្លេអ៊ែរណាមួយ ឬពីសំណល់នុយក្លេអ៊ែរណាមួយ ដែលកើតចេញពីការឆេះ (រួមទាំងដំណើរការស្ងួយបំភាយនៃប្រតិកម្មបំបែកនុយក្លេអ៊ែរ) នៃឥន្ធនៈនុយក្លេអ៊ែរ។

如果任何性质的损失、损坏或责任直接或间接由核武器及核材料、电离辐射，或由任何核燃料或核燃料燃烧（包括任何自持核裂变过程）所产生的核废料的放射性污染所导致、促成或引起。

ការដាក់ទណ្ឌកម្ម ការដាក់កំហិត និងករណីមិនធានា (LMA3100)
制裁限制及除外条款（LMA3100）

ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានសន្មត់មិនផ្តល់ការធានានិងមិនធ្វើសំណងដល់ការទាមទារ ឬ ផ្តល់អត្ថប្រយោជន៍ ប្រសិនបើជាការផ្តល់ការធានានេះ ការធ្វើសំណងនេះ ឬការផ្តល់អត្ថប្រយោជន៍នេះ នឹងបណ្តាលឱ្យក្រុមហ៊ុនធានារ៉ាប់រងប្រឈមនឹងការដាក់ទណ្ឌកម្ម ការហាមឃាត់ ការរឹតត្បិតក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬទណ្ឌកម្មសេដ្ឋកិច្ច ឬ ពាណិជ្ជកម្ម ច្បាប់ ឬបញ្ញត្តិកម្មរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

在任何情况下，如提供本保险保障、支付任何索赔或提供任何利益将使保险人违反联合国决议，或违反欧盟、英国或美利坚合众国的贸易或经济制裁、法律或法规项下的任何制裁、禁令或限制，则在该范围内，本公司不应被视为提供保险保障，亦不承担支付任何索赔或提供任何利益的责任。

ករណីមិនធានាលើជំងឺរាតត្បាត / កូវីដ១៩
传染病 / 新冠肺炎除外条款

ទោះបីជាមានប្រការណាមួយចែងផ្ទុយពីការធានារ៉ាប់រងនេះក៏ដោយ ការធានារ៉ាប់រងនេះមិនផ្តល់សំណងលើការបាត់បង់ការខូចខាតទំនួលខុសត្រូវ ថ្លៃចំណាយ ប្រាក់ពិន័យ ការផាក ឬចំនួនណាមួយដែលបណ្តាលមកពីជាប់ពាក់ព័ន្ធនឹងឬទាក់ទងជាមួយឬកើតចេញដោយផ្ទាល់ឬដោយប្រយោលក្តីពីករណីណាមួយខាងក្រោមរួមបញ្ចូលទាំងការភ័យ ខ្លាចណាមួយ ឬទទួលគំរាមកំហែងពីការឆ្លងនោះ មិនថាឆ្លងពិតមែនក្តី ឬជាការយល់ ឃើញក្តី)៖

- ជំងឺឆ្លងរាតត្បាត មេរោគ បាក់តេរី ឬសារពាង្គកាយផ្សេងឬបម្រែបម្រួលណាមួយមិនថា វាមានជីវិតក្តី ឬគ្មានក្តី និងអតិសុខុមប្រាណ (មិនថាគ្មានរោគសញ្ញា ឬមានក្តី) ឬ
- មេរោគកូវីដ១៩ រួមទាំងការបំប្លែងខ្លួន ឬបម្រែបម្រួលរបរាងថ្មីរបស់វា ឬ
- ជំងឺរាតត្បាតដែលប្រកាសដោយអង្គការសុខភាពពិភពលោក ឬអាជ្ញាធររដ្ឋាភិបាល។

尽管本保险中有任何相反规定，本保险不承保任何因以下任何情形直接或间接导致、引起、相关或以任何方式涉及或产生的任何损失、损坏、责任、费用、罚款、处罚或其他任何金额——包括任何实际或被认为存在的恐惧或威胁：

- **任何传染性疾病、病毒、细菌或其他微生物（无论是否无症状）；或**
- **冠状病毒（COVID-19）及其任何变种或变异；或**
- **由世界卫生组织或任何政府主管机关宣布的流行病或大流行病。**

ករណីមិនធានាលើការផ្ទុកលើសចំនួនអ្នករួមដំណើរ
座位数

បណ្ណសន្យារ៉ាប់រងមិនធានាសម្រាប់គ្រោះថ្នាក់ណាមួយ ការបាត់បង់ ការខូចខាត របួស ឬ ការទទួលខុសត្រូវផ្លូវច្បាប់ ប្រសិនបើចំនួនមនុស្ស (រួមទាំងអ្នកបើកបរ) នៅក្នុងយានយន្ត របស់អ្នកនៅពេលមានឧបទ្ទេវហេតុផ្ទុកលើសពីចំនួនកំណត់សម្រាប់អង្គុយដែលត្រូវបាន អនុញ្ញាតនៅក្រោមច្បាប់ អាជ្ញាប័ណ្ណ ឬបទប្បញ្ញត្តិដែលមានស្រាប់។

如在事故发生时，车内（包括驾驶员）乘坐人数超过根据现行法律、许可或法规所允许的法定座位数，则对于任何事故、损失、损坏、人身伤害或法律责任，本公司不予承担责任。

ករណីមិនធានាលើខ្វះការប្រុងប្រយ័ត្ន
未采取预防措施

ក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះការចំណាយបន្ថែមលើការខូចខាត ដែលបណ្តាលមកពីអ្នកត្រូវបានធានារ៉ាប់រង និងអ្នកដែលមានសិទ្ធិបើកបរយានយន្តរបស់អ្នកបន្ទាប់ពីមាន គ្រោះថ្នាក់ដោយហេតុថា៖

- ទុកចោលដោយគ្មានការមើលថែឱ្យបានត្រឹមត្រូវ
- ការខកខានក្នុងការប្រុងប្រយ័ត្ន ដើម្បីការពារការបាត់បង់ឬការខូចខាតបន្ថែមទៀត
- បន្តការបើកបរយានយន្តរបស់អ្នកដែលកំពុងស្ថិតក្នុងស្ថានមិនសក្តិសមមុនពេលទទួលបានការ ជួសជុល
- ទាក់ទងនឹងការខូចខាត ការខាតបង់ ឬការចំណាយដែលកើនឡើងពីការខកខានរបស់អ្នកក្នុងការថែរក្សាសមហេតុផលដើម្បីរក្សាសុវត្ថិភាព និងសុវត្ថិភាពយានយន្តរបស់អ្នក។នេះក៏នឹងរួមបញ្ចូលផងដែរប៉ុន្តែមិនកំណត់ចំពោះការទុកយានយន្តរបស់អ្នកដោយមិន មានការប្រុងប្រយ័ត្ន ឬដោះសោរ និង/ឬទុករថយន្តរបស់អ្នកក្នុងរបៀបបើកបរ ឬការបើកបរបញ្ជាស់។

对于事故发生后因您或您的授权驾驶员以下行为而造成的任何额外损坏，本公司不予赔偿：

- **将您的车辆无人看管**
- **未采取预防措施以防止进一步损失或损坏**
- **在车辆未修复前继续驾驶处于不适合上路状态的车辆**
- **因您未合理谨慎地保护车辆安全而产生的任何损坏、损失或费用上述情况还包括但不限于将车辆无人看管或未上锁，及/或将车辆置于前进或倒车档位状态下离开车辆。**

7 ទីតាំងភូមិសាស្ត្រនៃការធានា
地理范围限制

ទីតាំងភូមិសាស្ត្រនៃការធានានៃកិច្ចសន្យាធានារ៉ាប់រងនេះគឺនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
本保单的地理范围为柬埔寨王国。

8 លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង
索赔人资格

អ្នកទទួលផល ឬអ្នកទទួលសំណងធានារ៉ាប់រងអាចជាម្ចាស់បណ្ណសន្យារ៉ាប់រង និង/ ឬ ភាគី ម្ចាស់បំណុលដែលជាស្ថាប័នហិរញ្ញវត្ថុស្របច្បាប់ក្នុងករណីយានយន្តដែលបានដាក់ធានារ៉ាប់រងពាក់ព័ន្ធកម្ចីតែប៉ុណ្ណោះដែលមានសិទ្ធិក្នុងការទទួលផលឬសំណងពីក្រុមហ៊ុនយើងខ្ញុំដោយគោរពតាមបញ្ញត្តិ និងលក្ខខណ្ឌនានា ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។ សម្រាប់ករណីមានការបង្កគ្រោះថ្នាក់ដល់តតិយជន ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងជូនដល់តតិយជនផ្ទាល់ ដោយត្រូវមានការព្រមព្រៀងគ្នាផងដែរពីភាគីពាក់ព័ន្ធ ក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។

仅您本人及/或任何作为合法金融机构的贷款方（与本保单项下投保车辆有关的抵押权人）有权根据本保单的所有条款与条件从本公司获得任何赔偿。对于任何索赔事项，如相关方达成协议，本公司可直接向第三方支付赔偿金。

ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ តតិយជនបាត់បង់អាយុជីវិត ក្រុមហ៊ុនយើងនឹង ខ្ញុំផ្តល់សំណងទៅឱ្យក្រុមគ្រួសាររបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ភាគីតតិយជន និង/ឬ ទៅឱ្យអ្នកទទួលផលណាម្នាក់ដែលមានសិទ្ធិទទួលស្របច្បាប់តាមរយៈឯកសារបញ្ជាក់ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។

如被保险人及/或第三方发生任何死亡情况，本公司将根据相关正式文件，向被保险人、第三方的亲属及/或任何获授权的受益人支付赔偿金。

9 ការកែប្រែកិច្ចសន្យាធានារ៉ាប់រង
修正条款

ក្នុងករណីដែលកិច្ចសន្យាធានារ៉ាប់រងមានការកែប្រែឬមានការបន្ថែមលើបណ្ណសន្យារ៉ាប់រងដើមក្នុងលក្ខខណ្ឌណាមួយគឺតម្រូវឱ្យមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគី ទាំងសងខាង (ក្រុមហ៊ុនធានារ៉ាប់រង និងម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នកត្រូវបានធានារ៉ាប់រង) ដោយធ្វើការជូនដំណឹងអំពីការកែប្រែនេះតាមរយៈប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិច ឬ ធ្វើជាលិខិតជូនដំណឹងទៅកាន់ភាគីដែលត្រូវបានស្នើឱ្យមានការកែប្រែរាល់ការកែប្រែទាំងអស់មានសុពលភាព លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំ និង ម្ចាស់បណ្ណសន្យារ៉ាប់រង/អ្នកត្រូវបានធានារ៉ាប់រងនិងមានចែងក្នុងបដិលេខ។ក្នុងករណីមានការខកខានមិនបានជូនដំណឹងអំពីការកែប្រែដូចបានរៀបរាប់ខាងលើលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដើមនឹងត្រូវបានអនុវត្ត ឬបណ្តឹងទាមទារសំណងដែលកើត ឡើងដោយសារការកែប្រែនោះអាចនឹងត្រូវបានបដិសេដ។

对原保单任何条款的任何修订或补充，均需双方以书面形式通知本公司该等修订或补充事项，可通过电子通讯或向申请方发送书面通知的方式进行。任何修订或补充均须经本公司及承保人/保险人的书面同意，并载明于批单中方为有效。
如未按上述要求通知相关修订事项，则应适用原保险合同条款，并且因该等修订所产生的任何索赔可能被拒绝。

10 ការបន្តកិច្ចសន្យាធានារ៉ាប់រង
保单续保

កិច្ចសន្យាធានារ៉ាប់រងនេះអាចបន្តឡើងវិញបានយោងតាមការសម្រេចចិត្តរបស់ក្រុមហ៊ុនធានា រ៉ាប់រងដោយផ្អែកលើការបំពេញតាមលក្ខខណ្ឌក្នុងការវាយតម្លៃហានិភ័យ ហើយផ្អែកលើអត្រាបង់បុព្វលាភធានារ៉ាប់រងដែលបានសម្រេចដោយក្រុមហ៊ុនធានារ៉ាប់រង។ នៅពេលមានការស្នើ សុំឱ្យមានការបន្តការធានារ៉ាប់រងជាបណ្តោះអាសន្នរយៈពេលអតិបរមាដែលអាចបន្តបានគឺរយៈពេល៣០ថ្ងៃ។ប្រសិនបើនៅថ្ងៃចុងក្រោយនៃរយៈពេលបន្តនេះ កិច្ចសន្យាធានារ៉ាប់រងត្រូវ បានលុបចោល ឬ ខកខានមិនបន្តដោយហេតុផលផ្សេងៗ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភសម្រាប់រយៈពេល៣០ថ្ងៃដែលបានបន្តជាបណ្តោះអាសន្ននោះតាមអត្រាចំនួនថ្ងៃជាក់(pro-rata premium)។

本保单是否续保由本公司自行决定，或可能不予续保。本公司将在续保到期日前30天向被保险人发送续保通知，前提是符合核保要求，并适用本公司届时确定的保险费率。
如提出在续保时维持保障的申请，则最长可维持保障30天。如在该期间结束时，本保单因任何原因被取消或失效，则您须按续保保险费的比例（按天数计算）向本公司支付该期间所维持保障的保险费。

11 ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង
保单终止

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានបំណងបញ្ចប់នូវកិច្ចសន្យាធានារ៉ាប់រងនេះ អ្នកត្រូវបាន ធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនក្នុងអំឡុងពេល១០(ដប់)ថ្ងៃមុនពេលដល់កាលកំណត់នៃការលុបចោល។ ក្នុងករណីនេះដែរ ក្រុមហ៊ុននឹងបង្វិលត្រលប់ជូន នូវចំនួន៩០(កៅសិប)ភាគរយនៃបុព្វលាភដែលនៅសល់។សម្រាប់សំណើរនៃការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះប្រសិនបើមានការទាមទារសំណងណាមួយកើតឡើងហើយខាងក្រុមហ៊ុនបានបង់នូវសំណងនោះរួចរាល់នោះក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចក្នុងការបង្វិលសងនូវបុព្វលាភសម្រាប់រយៈពេលដែលនៅសល់នោះទេ។

如被保险人希望在到期日前终止保险，须提前10天通知本公司。在合理理由成立的情况下，保险公司将向被保险人退还剩余保费的百分之九十（90%）。
如在风险事故发生后提出终止保险申请，且本公司已支付赔偿金，则保险公司不予退还剩余保险期间的保险费。

12 ការលុបចោលកិច្ចសន្យាធានារ៉ាប់រង
取消

ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលកិច្ចសន្យាធានារ៉ាប់រងតាមរយៈការជូនដំណឹងជា លាយលក្ខណ៍អក្សរទៅកាន់អ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្នុងករណីដូចខាងក្រោម៖

- បុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់ក្រោយរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងមានសុពលភាព។
- ក្រុមហ៊ុនរកឃើញថាម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានការលាក់បាំង ក្លែងបន្លំ និង/ឬ មិនបានបង្ហាញព័ត៌មានពិត។

本公司亦保留权利，在提前30（三十）天通知您的情况下取消本保单，具体原因如下：

- **保险合同生效后30（三十）天内未支付保险费。**
- **发现投保人或被保险人存在隐瞒、欺诈和/或虚假陈述的情况。**

13 ការទាមទារសំណង
索赔

លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង
索赔申请人资格

អ្នកដែលអាចបញ្ជូនការទាមទារសំណងសម្រាប់ការបាត់បង់ឬការខូចខាតដែលកើតឡើងអាចជាអ្នកត្រូវបានធានារ៉ាប់រងឬអ្នកតំណាងស្របច្បាប់ចំណែកឯអ្នកទទួលការទូទាត់សំណងគឺ ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកតំណាងស្របច្បាប់។

就已发生的损失提出索赔申请的人可以是索赔人、被保险人或法定代理人；而接收赔款/补偿金的人为保单持有人或法定代理人。

ការរាយការណ៍ពីគ្រោះថ្នាក់ក្នុងរយៈពេល ២៤ម៉ោង
24小时事故报案

ក្រុមហ៊ុនអាចបដិសេធមិនធ្វើសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនបានរាយការណ៍អំពីគ្រោះថ្នាក់ក្នុងរយៈពេល ២៤ម៉ោងពីពេលកើតហេតុ លើកលែងអ្នកត្រូវបានធានារ៉ាប់រងមានហេតុផលសមស្រប។

除非被保险人能够向本公司提供合理且可接受的理由，否则如被保险人未在事故发生后24小时内向本公司报案/通知索赔事项，本公司有权拒绝赔偿申请。

នីតិវិធីនៃការផ្តល់ព័ត៌មាន
信息提供程序

ក. ក្នុងករណីគ្រោះថ្នាក់ទៅលើយានយន្តរបស់លោកអ្នក ដោយមិនគិតដល់ថាវានឹងមានការទាមទារសំណងកើតឡើង លោកអ្នកតម្រូវឱ្យទាក់ទងមកកាន់ នាយកដ្ឋានទាមទារសំណង យើងខ្ញុំ និងរាយការណ៍អំពីគ្រោះថ្នាក់ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីគ្រោះថ្នាក់។

如发生涉及您车辆的事故，无论是否提出索赔，您均须在事故发生后24小时内联系我司理赔部门并报告该事故。

ខ. ក្នុងករណីចោរកម្ម ឬបទល្មើសព្រហ្មទណ្ឌដែលអាចនាំឱ្យមានការទាមទារសំណង ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ លោកអ្នកតម្រូវឱ្យរាយការណ៍មកកាន់ក្រុមហ៊ុន និងប៉ូលីសភ្លាមៗអំពី ការកើតហេតុនិងសហការជាមួយក្រុមហ៊ុនក្នុងការស្វែងអ្នកប្រព្រឹត្តបទល្មើស។

如发生盗窃或刑事犯罪事件，并可能依据本保险合同提出索赔，您须立即向本公司及警方报案，并配合本公司寻找犯罪嫌疑人。

គ. រាល់លិខិត ការទាមទារសំណង ដីកាតុលាការ ការកោះឱ្យចូលខ្លួនរបស់តុលាការ និងដីកាបង្គាប់ ឬកោះហៅ ត្រូវជូនដំណឹងមកកាន់ក្រុមហ៊ុនភ្លាមៗ នៅពេលដែលលោកអ្នកបានទទួល។ លោកអ្នកក៏តម្រូវឱ្យជូនដំណឹងមកកាន់ក្រុមហ៊ុនភ្លាមៗដែរបន្ទាប់ពីលោកអ្នក ឬបុគ្គលដែលមានសិទ្ធិក្នុងការទាម ទារសំណង ទទួលបានដំណឹងអំពីការចោទប្រកាន់ ការស៊ើបអង្កេត ការសាកសួរ ឬសំណើណាមួយទាក់ទងនឹងគ្រោះថ្នាក់។

所有信函、索赔要求、法院命令、法院传票以及任何指令或传唤，在您收到后均须立即通知本公司。您或有权获得赔偿的人一旦获悉与该事故有关的任何指控、调查、询问或要求，也须立即通知本公司。

លក្ខខណ្ឌទាំងនេះគឺជាលក្ខខណ្ឌបឋមមុនការទទួលខុសត្រូវរបស់ក្រុមហ៊ុននិងការមិនគោរពទៅតាមលក្ខខណ្ឌទាំងនេះនឹងបណ្តាលឱ្យអ្នកត្រូវបានធានារ៉ាប់រងបាត់បង់សិទ្ធិក្នុងការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។
这些条件为保险公司承担责任之前的前置条件，如未遵守该等条件，被保险人将丧失根据本保险单提出赔偿的权利。

ការផ្តល់ឯកសារ ឬភស្តុតាងក្នុងការដោះស្រាយសំណង
提供支持索赔流程的文件或证据

នៅពេលដាក់ពាក្យទាមទារសំណងមកក្រុមហ៊ុនធានារ៉ាប់រងអ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រងនូវឯកសារដូចជា៖
向保险公司提出索赔时，被保险人必须向保险公司提供以下文件：

ក. ទម្រង់ទាមទារសំណងដែលបានបំពេញ
已填写的索赔申请表

ខ. ច្បាប់ចម្លងបណ្ណបើកបររបស់អ្នកបើកបរដែលមានសុពលភាពនៅពេលមានគ្រោះថ្នាក់
事故发生时有效的驾驶执照复印件

គ. ច្បាប់ចម្លងបណ្ណសម្គាល់យានយន្ត
车辆登记证复印件

ឃ. ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ
身份证复印件

ង. កិច្ចព្រមព្រៀងច្បាប់ដើមរបស់ក្រុមហ៊ុនធានារ៉ាប់រង(ក្នុងករណីដែលមានសំណងលើភាគីទី ៣)
保险公司协议原件（涉及第三方赔偿的情况）

ច. ច្បាប់ចម្លងនៃរបាយការណ៍ប៉ូលីស ឬ គំនូសព្រៀងចរាចរណ៍ (ប្រសិនបើមាន)
警方报告或交通罚单复印件（如有）

ឆ. ច្បាប់ចម្លងនៃកិច្ចសន្យាជួល/ បញ្ចាំ (ប្រសិនបើមាន)
租赁/按揭协议复印件（如有）

ជ. សោរយានយន្ត និងបណ្ណសម្គាល់យានយន្តច្បាប់ដើម (ក្នុងករណីបាត់ ឬ ករណីយាន យន្តត្រូវបានធានារ៉ាប់រងរងការខូចខាតទាំងស្រុង)
车辆钥匙原件及车辆登记证（适用于车辆丢失或车辆被认定为全损保险的情况）

ឈ. ទម្រង់វាយតម្លៃនៃការជួសជុល
维修评估表

ញ. ឯកសារព្យាបាលវេជ្ជសាស្ត្រ និងវិក្កយបត្រច្បាប់ដើម (ក្នុងករណីមានរបួសស្នាម)
医疗记录及账单原件（如涉及人身伤害）

ញ. ឯកសារព្យាបាលវេជ្ជសាស្ត្រ និងវិក្កយបត្រច្បាប់ដើម (ក្នុងករណីមានរបួសស្នាម)
医疗记录及账单原件（如涉及人身伤害）

ដ. សៀវភៅគ្រួសារ ឬ សំបុត្រអាពាហ៍ពិពាហ៍ ឬ ឯកសារដែលអាចបញ្ជាក់ពីទំនាក់ទំនង (ក្នុងករណីមរណភាព ឬ របួសស្នាម)
家庭户口簿或结婚证或可证明关系的文件（如涉及死亡或受伤情况）

ថ. ឯកសារពាក់ព័ន្ធផ្សេងៗ (ក្នុងករណីចាំបាច់)។
其他相关文件（如有需要）。

រយៈពេលអតិបរមា នៃការទូទាត់សំណងជូនអតិថិជន
索赔结案的最长期限

ក្រុមហ៊ុនធានារ៉ាប់រង នឹងចេញការទូទាត់សំណងធានារ៉ាប់រងជូនអ្នកទាមទារសំណងធានារ៉ាប់រងតាមការកំណត់ដូចខាងក្រោម៖
保险公司将根据以下标准向保险索赔人支付保险赔偿金：

ក. ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីអ្នកទាមទារសំណងធានារ៉ាប់រងឯកភាពទទួលយកសំណងធានារ៉ាប់រង ចំពោះការទូទាត់ទាត់សំណងទាំងស្រុង ឬ
在索赔人同意接受保险理赔并接受对该索赔的全额赔付之日起3（三）个工作日内，或

ខ. ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទទួលយកសំណងធានារ៉ាប់រង រវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកទាមទារសំណងធានារ៉ាប់រង ចំពោះការទូទាត់សំណងធានារ៉ាប់រង ជាដំណាក់កាល។
在保险公司与索赔申请人签订的索赔受理协议中所规定的期限内，以分期方式支付保险赔款。

របៀបទូទាត់សំណង
赔款支付方式

ការទូទាត់សំណងគឺធ្វើឡើងតាមរយៈមូលប្បទានបត្រ និង/ឬ ក៏ផ្ទេរពីគណនីធនាគារ។
赔款通过支票和/或银行账户转账方式支付。

14 ការរក្សាព័ត៌មានសម្ងាត់
保密条款

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឲ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឲ្យដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។
向保险人提供的信息应予以保密，未经事先同意，不得向任何第三方提供任何个人信息，除非法律或相关规定要求或允许。

15 នីតិវិធីនៃការផ្សះផ្សាវិវាទ
争议解决

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រងភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជាដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។
凡因保险业务经营而产生的任何争议，争议双方可在向仲裁机构或有管辖权的法院提起诉讼之前，将案件提交柬埔寨保险监管机构进行调解，但刑事案件除外。

16 ច្បាប់ និងយុត្តាធិការ
适用法律与管辖权

បណ្ណសន្យារ៉ាប់រងនេះត្រូវស្ថិតក្រោម និងបកស្រាយតាមច្បាប់នៃព្រះរាជាណាក្រកម្ពុជា។ ដែនយុត្តាធិការគឺស្របតាមច្បាប់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។
本保单应受柬埔寨王国法律管辖并据其解释。管辖法院为柬埔寨王国有管辖权的法院。

17 លក្ខខណ្ឌនានាអនុវត្តគ្រប់ចំណុចធានាទាំងអស់
适用于所有部分的条款

លក្ខខណ្ឌមុនការទទួលខុសត្រូវរបស់ក្រុមហ៊ុន
公司责任的先决条件

ការបំពេញនិងគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះដោយលោកអ្នកឬបុគ្គលណាមួយមានសិទ្ធិក្នុងការទាមទារសំណងនិងការពិតនៃសេចក្តីថ្លែងការ និងចំលើយនៅក្នុងបែបបទស្នើសុំធានារ៉ាប់រង គឺជាលក្ខខណ្ឌអាទិភាពដំបូងមុននឹងមានការ ទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការទូទាត់សំណងណាមួយ។
在您或任何主张获得赔偿的人须履行或不得履行本保单条款与条件的范围内，严格遵守并履行本保单的所有条款与条件，以及投保申请表中所作陈述与回答的真实性，均构成本公司在本保单项下承担任何赔付责任的先决条件。

កាតព្វកិច្ចក្នុងការធ្វើប្រតិវេទ និងការអនុវត្តតាម
如实告知与合规义务

លោកអ្នកតម្រូវឱ្យប្រាប់មកខាងក្រុមហ៊ុននៅហេតុការណ៍ដែលលោកអ្នកដឹងឬគួរតែដឹងដែលប៉ះពាល់ដល់ការសម្រេចចិត្តរបស់យើងខ្ញុំក្នុងការធានាលោកអ្នក។លោកអ្នកតម្រូវឱ្យប្រាប់មកខាងក្រុមហ៊ុនភ្លាមៗប្រសិនបើព័ត៌មានដែលលោកអ្នកបានផ្តល់មកឱ្យខាងក្រុមហ៊ុនមានការផ្លាស់ប្តូរឬលែងត្រឹមត្រូវ។ បើមិនដូច្នោះទេ លោកអ្នកនឹងមិនទទួលបានផលប្រយោជន៍ណាមួយពីកិច្ចសន្យាធានារ៉ាប់រងនេះទេ និង/ឬក្រុមហ៊ុនអាចបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នក។

您必须如实告知所有您已知或应当知悉、可能影响本公司决定是否承保及承保条件的事实。如您所提供的任何信息发生变化或不再准确，您也必须立即通知本公司。否则，在发生索赔时，您可能无法获得本保单项下的任何保障利益，且/或本公司有权取消本保单。

ការជូនដំណឹងជាលាយលក្ខណ៍អក្សរ
书面通知

រាល់ការជូនដំណឹង ឬការទាក់ទងគ្នាក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវធ្វើឡើងជា លាយលក្ខណ៍អក្សរ។
根据本保单所作的任何通知或沟通均须以书面形式提交给本公司。

ការថែទាំយានយន្តរបស់លោកអ្នក
车辆保管与维护

លោកអ្នកចាំបាច់ត្រូវថែរក្សាយានយន្តរបស់លោកអ្នកនៅក្នុងលក្ខខណ្ឌល្អនិងដែលអាចបើកបរលើផ្លូវបាន។ក្រុមហ៊ុនមានសិទ្ធិក្នុងការចុះត្រួតពិនិត្យយានយន្តរបស់លោកអ្នកបាន គ្រប់ពេលវេលា និងសាកសួរព័ត៌មានជាមួយអ្នកដែលមានសិទ្ធិបើកបរ។ លោកអ្នកតម្រូវ ឱ្យចាត់ចែងរាល់វិធានការសមរម្យដើម្បីការពារយានយន្តរបស់លោកអ្នកពីការបាត់បង់ ឬខូចខាត។
ក្នុងករណីមានគ្រោះថ្នាក់កើតឡើង យានយន្តរបស់លោកអ្នកមិនត្រូវទុកចោល ដោយគ្មានការមើលថែឱ្យបានត្រឹមត្រូវដើម្បីបង្ការនូវការបាត់បង់ឬខូចខាតថែមទៀតនោះទេ។ប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានបើកបរមុនពេលដែលមានការជួសជុល ដែលចាំបាច់ ការខូចខាតបន្ថែមទៅលើយានយន្តរបស់លោកអ្នកនឹងមិនត្រូវបានធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះទេ។

您必须使您的车辆保持良好且适合上路行驶的状态。本公司有权随时对您的机动车或其任何部分进行检查，并有权与您的任何授权驾驶员进行面谈。您必须采取一切合理措施以防止车辆发生损失或损坏。
在发生事故或故障时，您的车辆不得在未采取适当防护措施以防止进一步损失或损坏的情况下被无人看管。如在必要维修完成之前继续驾驶车辆，任何损坏的扩大或由此造成的进一步损坏，将不在本保单的承保范围内。

ការចាត់ចែងដំណើរការក្តឹង
诉讼程序的处理

ក្រុមហ៊ុនមានសិទ្ធិក្នុងការ៖
本公司有权自行选择：

ក. ចាត់ចែងក្នុងនាមរបស់អ្នកត្រូវបានធានារ៉ាប់រងឬបុគ្គលដែលដែលមានសិទ្ធិទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះដើម្បីការពារក្តី ឬដោះស្រាយសំណង។
以您或任何依据本保单主张获得保障的其他人的名义，接管并进行对您或该等人员所提出的任何索赔的抗辩或和解；

ខ. បន្តក្នុងនាមរបស់អ្នកត្រូវបានធានារ៉ាប់រងឬបុគ្គលដែលមានសិទ្ធិទាមទារសំណងក្នុងការទាមទារសំណងពីបុគ្គលដែលទទួលខុសត្រូវក្នុងការខូចខាត ឬការបាត់បង់ បុគ្គលណាដែលធ្វើការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងត្រូវផ្តល់ឱ្យក្រុមហ៊ុននូវ រាល់ព័ត៌មាន និងកិច្ចសហការតាមការស្នើសុំរបស់ក្រុមហ៊ុន។
以您或该等人员的名义，为本公司利益向任何对损失或损坏负有责任的人员追偿任何损失或损坏索赔。任何依据本保单主张保障的人均应向本公司提供所需的全部信息及协助。

ក្រុមហ៊ុនមានសិទ្ធិសម្រេចពេញលេញក្នុងការចាត់ចែងដំណើរការក្តឹង និងធ្វើការដោះស្រាយសំណង។
本公司在任何诉讼程序的处理及/或索赔的解决方式方面拥有完全的裁量权。

ធានារ៉ាប់រងផ្សេងទៀត
其他保险

ប្រសិនបើលោកអ្នកបានធ្វើការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះក្រុមហ៊ុននឹងចូលរួមទទួលខុសត្រូវតាមកម្រិតសមាមាត្រក្នុងករណីដែលអ្នកមានធានារ៉ាប់រងផ្សេងៗ ទៀតធានាលើការខូចខាត ឬការបាត់បង់ ឬការទទួលខុសត្រូវដូចគ្នា។ ក្រុមហ៊ុននឹងមិនធ្វើការធានារ៉ាប់រងចំពោះបុគ្គលណាដែលទទួលបានការធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងផ្សេងទៀតនោះទេ។
如果您依据本保单提出有效索赔，当您已拥有其他保险承保同一损失、损坏或责任时，本公司仅按比例承担应付部分。如其他人员已受其他保险保单保障，本保单不向该等人员提供任何保障。

រូបិយវត្ថុ
货币

បុព្វលាភដែលត្រូវបង់មកឱ្យក្រុមហ៊ុន គឺដុល្លារអាមេរិក។
រាល់សំណងដែលត្រូវបង់ឱ្យអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ជាដុល្លារអាមេរិកលើកលែងមានការព្រមព្រៀងជាមុនប្រសិនបើត្រូវបង់ជារូបិយវត្ថុផ្សេងក្រៅពីដុល្លារអាមេរិក។
រាល់ផលប្រយោជន៍ដែលត្រូវបង់ជារូបិយវត្ថុក្នុងស្រុក (ខ្មែររៀល) ត្រូវប្តូរតាមអត្រាប្តូរប្រាក់ ជាក់ស្តែងនៅពេលមានការទាមទារសំណង។
ប្រការនេះនៅតែមានសុពលភាពរហូតដល់មាននិយ័តកម្មគ្រប់គ្រងការប្រើប្រាស់រូបិយវត្ថុ។

所有应付给本公司的保费均应以美元（USD）支付。
除非我们事先以书面形式另有约定，否则所有理赔赔偿金额均以美元支付。
以本地货币支付的赔付金额，将按照本公司评估索赔时的现行即期汇率进行兑换。
除非有关于货币使用的管制规定，本条款始终适用。

សិទ្ធិក្នុងការជួសជុល
维修授权

ប្រសិនបើយានយន្តរបស់លោកអ្នកទទួលរងការខូចខាតដែលត្រូវបានធានារ៉ាប់រងក្រោមផ្នែកនេះលោកអ្នកអាចមានសិទ្ធិក្នុងការជួសជុលយានយន្តរបស់អ្នកដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖
如果您的车辆遭受了本节涵盖的损坏，您可能有权在满足以下条件的情况下获得车辆维修：

ក. តម្លៃប៉ាន់ស្មាននៃការជួសជុលមិនលើសពី ២០០ ដុល្លារអាមេរិក។
维修估算费用不超过200美元；

ខ. លោកអ្នកត្រូវផ្ញើរមកឱ្យក្រុមហ៊ុននូវតារាងតម្លៃនៃការជួសជុលនិងត្រូវមានការយល់ព្រមពីក្រុមហ៊ុនជាមុនដើម្បីអាចចាប់ផ្តើមជួសជុលបាន។
您需尽快向我们提交维修费用报价，并在开始修理受损车辆之前获得我们的事先同意。

18 នីតិវិធីប្តឹងតវ៉ា
投诉程序

អនុវត្តចំពោះគ្រប់ចំណុចធានាទាំងអស់
适用于所有部分

ក្រុមហ៊ុនប្តេជ្ញាក្នុងការផ្តល់សេវាកម្មដ៏ប្រសើរបំផុត ប្រសិនបើអតិថិជនមានការមិនពេញចិត្ត ក្រុមហ៊ុននឹងខិតខំស្វែងរកដំណោះស្រាយភ្លាម ប៉ុន្តែប្រសិនបើក្រុមហ៊ុនមិនអាចដោះស្រាយ បញ្ហាបាន ក្រុមហ៊ុននឹងជូនដំណឹងទៅអតិថិជនក្នុងអំឡុងពេល ៤៨ ម៉ោង ហើយនឹងខិតខំប្រឹង ប្រែងរកដំណោះស្រាយឱ្យអតិថិជនក្នុងអំឡុងពេល៤សប្តាហ៍ប្រសិនបើក្រុមហ៊ុននៅតែមិនអាចផ្តល់ដំណោះស្រាយជូនអតិថិជនក្រុមហ៊ុននឹងជូនដំណឹងដល់អតិថិជននូវរយៈពេលជាក់លាក់មួយដែលក្រុមហ៊ុនអាចរកដំណោះស្រាយជូនអតិថិជនបាន។
我们的承诺是提供优质服务。如您有投诉，我们将尽力立即解决；如无法立即解决，我们将在四十八（48）小时内确认已收到您的投诉，并尽力在四周内解决问题。如无法在该期限内解决，我们将告知您预计何时可以得到答复。

ប្រសិនបើអតិថិជនត្រូវការប្តឹងតវ៉ាមិនពេញចិត្ត សូមធ្វើការទំនាក់ទំនងតាមរយៈ:
ក្រុមការងារបម្រើសេវាកម្មអតិថិជនរបស់ក្រុមហ៊ុន៖

如您有任何投诉，请通过以下方式联系我们：
客户满意度团队

ការិយាល័យកណ្តាល អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក អគារដីឡូតិ៍C ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

吴哥大众保险有限公司总部，C地块大楼，169街，第12村，Veal Vong分区，7 Makara区，柬埔寨金边

ទូរស័ព្ទលេខ / 电话: +855 78 24 24 24 / +855 87 24 24 24
អ៊ីម៉ែល / 电子邮箱: complaint-insurance@agi.com.kh

ប្រសិនបើក្រុមហ៊ុនមិនអាចរកដំណោះស្រាយលើបណ្តឹងតវ៉ា ក្នុងរយៈពេល ១២សប្តាហ៍ អ្នកត្រូវបានធានារ៉ាប់រងអាចបន្តប្តឹងទៅ៖
និយ័តករធានារ៉ាប់រងកម្ពុជា អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

如果我们在十二（12）周内仍未解决该问题，您有权将投诉提交至：
柬埔寨保险监管机构，经济与财政部
地址：柬埔寨王国金边市Russey Keo区Chraing Chamres 1分区598街168F号大楼（第6层）

19 ព័ត៌មានទំនាក់ទំនង
联系方式

សូមទំនាក់ទំនងក្រុមហ៊ុនតាមរយៈ៖
អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
请通过以下方式联系我们：
吴哥大众保险有限公司，柬埔寨金边市7 Makara区

ទូរស័ព្ទលេខ / 电话: +855 78 24 24 24 / +855 87 24 24 24
អ៊ីម៉ែល / 电子邮箱: complaint-insurance@agi.com.kh

នាយកដ្ឋានវាយតម្លៃហានិភ័យ
核保部
ទូរស័ព្ទលេខ / 电话: +855 12 31 63 83
អ៊ីម៉ែល / 电子邮箱: under-writting@agi.com.kh

នាយកដ្ឋានដោះស្រាយសំណង (ដំណើរការ២៤ម៉ោង ៧ថ្ងៃក្នុង១សប្តាហ៍)
理赔部（24小时/7天理赔服务）
ទូរស័ព្ទលេខ / 电话: 1800 20 24 24 (免费电话)
អ៊ីម៉ែល / 电子邮箱: claims@agi.com.kh

ANGKOR GENERAL INSURANCE

ANGKOR GENERAL INSURANCE, BUILT ON TRUST.

24/7 CLAIMS SERVICE

24/7 ឥតគិតថ្លៃ
免费拨打 | TOLL-FREE

1800 20 24 24

FOR MORE INFORMATION

+855 78 24 24 24 | +855 87 24 24 24

Our Head Office

Building # Land Lot C, St. 169, Phum 12, Sangkat Veal Vong,
Khan 7 Makara, Phnom Penh, Kingdom Of Cambodia

Info@agi.com.kh

Connecting with us

Angkor General Insurance Plc

www.agi.com.kh